សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុ ក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ដល់ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **មឿន សិលា** | លោក **ឃឹម ឧត្តម** |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី ២១ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទឈ្មោះ **មឿន សិលា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្រ្ត ជំនាន់ទី២១ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០២១។ សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងទ្វេះ

លោកឪពុក **ម៉ែន សាមឿន** និង អ្នកម្តាយ **ម៉ិញ ម៉េងឡុង** ដែលលោកបានផ្តល់កំណើត និង បាន ទំនុកបម្រុងគ្រប់បែបគ្រប់យ៉ាងទាំងស្មារតី និងសម្ភារៈ ជាពិសេស លោកទាំងពីរបានផ្តល់ឱកាសដ៏មានតម្លៃឲ្យ ខ្ញុំបាទ បានសិក្សារៀនសូត្រ រហូតមកដល់ពេលនេះ។

លោកតា **ស៊ី ហ៊្គិចម៉ិញ** និង លោកយាយ **ជួង គែចគុន** ដែលលោកទាំងពីរបានចិញ្ចឹមបីបាច់ ដោយក្តីស្រលាញ់ និង ផ្តល់នូវដំបូន្មានល្អៗដែលជាគតិអប់រំដ៏មានតម្លៃសម្រាប់ខ្ញុំបាទ។

ខ្ញុំបាទក៏សូមគោរព និង សម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ គ្រប់រូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបាន យកចិត្តទុកដាក់លើការសិក្សារបស់និស្សិត ដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ ដោយលោក ពុំគិតពីបញ្ហាដែល ជួបការលំបាក ហើយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបណ្តុះបណ្តាលរូបខ្ញុំបាទ រួមទាំង និស្សិតដទៃទៀតផងដែរ ។

ខ្ញុំបានក៏សូមគោរព និង សម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកគ្រូសាស្រ្តាចារ្យ **ឃីម ឧត្តម** ដែលជាសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្ត សេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំខ្ញុំបាទក្នុងការសិក្សាស្រាវជ្រាវនិងចងក្រងកិច្ច ការនេះឡើងសម្រាប់ជា ប្រយោជន៍ដល់រូបខ្ញុំបាទ និងបានផ្តល់ទស្សនៈល្អៗគន្លឹះទ្រឹស្តី និងការអនុវត្ត យ៉ាង ច្រើនដែលដល់រូបខ្ញុំបាទ ដើម្បីឱ្យមានការយល់ច្បាស់និង ការបញ្ចប់ការស្រាវជ្រាវនេះដោយជោគជ័យគួរជាទីមោទនៈ។

ជាចុងបញ្ចប់នេះខ្ញុំបាទក៏សូមគោរពជូនពរ ៖ មាតា បិតា ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្រ្តចារ្យ គ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ទាំងអស់ ជួបតែសេចក្តីសុខ សុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូម ប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការចូលមានដល់ លោក លោកស្រី ទាំងអស់គ្នាឲ្យជួបប្រទះ នូវពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សខុៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

កម្ពុជាក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានបញ្ចប់ការកាន់កាប់របស់វៀតណាមមកលើកម្ពុជាបន្ទាប់ការរលំរលាយនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងបានបង្កើតឱ្យមានរបបសេដ្ឋកិច្ចទីផ្សារដែលនាំឱ្យមានការស្តារបេបកម្មសិទ្ធិឯកជនលើដីធ្លីមកវិញ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ នេះក៏ដោយសាតែសមិទ្ធផលនៃការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទើបកម្ពុជាអាចមានសន្តិភាពនិងស្ថេរភាពក្នុងប្រទេសទាំងមូលដែលអនុញ្ញាតឱ្យពលរដ្ឋកម្ពុជាអាចប្រកបរបរកស៊ី ក៏ដូចជាការបើកអាជីវកម្មផ្សេងៗបានជាទីមោទនៈ និងមានការអភិវឌ្ឍន៍អាចទទួលបានផលសម្រេចដ៏ច្រើនសន្ធិកសន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។

ស្របពេលជាមួយគ្នានេះដែរ ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសិក្សាស្រាវជ្រាវ និងចងក្រងបានជាអត្ថបទសារណាស្តីពី "របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា" ក្រោមការដឹកនាំរបស់លោកគ្រូសាស្ត្រាចារ្យ **ឃឹម ឧត្តម** ដែលជាសាស្ត្រាចារ្យ មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដោយសាតែមើលឃើញពីសារៈប្រយោជន៍ទាក់ទងនឹងការធ្វើអាជីវកម្មបញ្ចាំអចលនវត្ថុដែលបាននឹងកំពុងមានប្រជាប្រិយភាពសម្រាប់ពលរដ្ឋកម្ពុជា ទើបខ្ញុំបាទធ្វើការសិក្សាស្រាវជ្រាវ និង ចងក្រងអត្ថបទសារណាបញ្ចប់ការសិក្សានេះឡើង សម្រាប់ជាធនធានមួយក្នុងការចូលរួមចំណែកលើកកម្ពស់ការយល់ដឹងនិងសិក្សាស្រាវជ្រាវទៅលើនីតិវិធីច្បាប់និងភាពជាសារវន្តនៃនីតិដែលជាធាតុសំខាន់ៗនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុនៅក្នុងប្រទេសកម្ពុជាឱ្យមានភាពត្រឹមត្រូវនិងស្របតាមស្មារតីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំបាទ បានខិតខំស្វះស្វែងក្នុងការសិក្សាស្រាវជ្រាវលើច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗទៀត ព្រមទាំងសៀវភៅរបស់សាស្ត្រាចារ្យ និង អត្ថបទជាច្រើនផ្សេងទៀត ដើម្បីចងក្រង និងរៀបចំឱ្យបានជាអត្ថបទសារណាដែលរំពឹងថាជាសមិទ្ធផលមួយដ៏ប្រសើរសម្រាប់ការខិតខំសិក្សាស្រាវជ្រាវនិងតាក់តែងដ៏លំបាកមួយនេះ។

ជាចុងក្រោយនេះខ្ញុំបាទនឹងទទួលយកនូវការទិតៀន មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា សាស្ត្រាចារ្យ សិស្ស និស្សិត និង មិត្តអ្នកអានទាំងអស់ដើម្បីជាការកែលម្អដល់ខ្ញុំបាទ។ ខ្ញុំបាទ នឹងរង់ចាំទទួលស្វាគមន៍ដោយក្តីសោមនស្សរីករាយ។ ខ្ញុំបាទ សូមប្តេជ្ញាថា និងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស ពិសេសគឺពង្រឹងវិស័យច្បាប់ដើម្បីឱ្យប្រទេសកម្ពុជាក្លាយជានីតិរដ្ឋយ៉ាងពិតប្រាកដ ទៅតាមសមត្ថភាព និងលទ្ធភាពខ្ញុំបាទ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ..... ១

## ជំពូកទី១៖
## និន្នាការទូទៅនៃសិទ្ធិលើការបញ្ចាំនៅកម្ពុជា

**ផ្នែកទី១៖ អត្ថន័យ និងកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ** ..... ៣

កថាខណ្ឌទី១៖ អត្ថន័យនៃសិទ្ធិលើការបញ្ចាំ ..... ៣

កថាខណ្ឌទី២៖ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ ..... ៤

**ផ្នែកទី២៖ មូលហេតុ និងទម្រង់នៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅកម្ពុជា** ..... ៥

កថាខណ្ឌទី១៖ មូលហេតុនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅកម្ពុជា ..... ៥

កថាខណ្ឌទី២៖ ទម្រង់នៃការបង្កើតសិទ្ធិលើការបញ្ចាំនៅកម្ពុជា ..... ៧

**ផ្នែកទី៣៖ ភាគីក្នុងទំនាក់ទំនងនៃសិទ្ធិលើការបញ្ចាំ** ..... ៨

កថាខណ្ឌទី១៖ ភាគីនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ ..... ៨

កថាខណ្ឌទី២៖ ភាគីនៃសិទ្ធិលើបំណុល ..... ៩

## ជំពូកទី២៖
## សិទ្ធិលើការបញ្ចាំអចលនវត្ថុ

**ផ្នែកទី១៖ ការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ** ..... ១០

កថាខណ្ឌទី១៖ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ ..... ១០

- ១.១. ការព្រមព្រៀងរវាងគូភាគី ..... ១០
- ១.២. ការបង្ហាញឆន្ទៈដោយពិតប្រាកដ និងដោយសេរី ..... ១១
- ១.៣. ការផ្ទេរការកាន់កាប់ ..... ១២
  - ១.៣.១. ការប្រគល់ជាក់ស្ដែង ..... ១២
  - ១.៣.២. ការប្រគល់ដោយសង្ខេប ..... ១២
  - ១.៣.៣. ការប្រគល់ដោយបញ្ជា ..... ១៣
- ១.៤. ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់ ..... ១៣
- ១.៥. អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ ..... ១៤

កថាខណ្ឌទី២៖ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ........................................................ ១៥
កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីសិទ្ធិលើការបញ្ចាំអចលនវត្ថុ ..................................................... ១៦
**ផ្នែកទី២៖ ការអនុវត្តសិទ្ធិលើការបញ្ចាំអចលនវត្ថុ** ............................................................. ១៨
កថាខណ្ឌទី១៖ សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ......................................១៩
កថាខណ្ឌទី២៖ សិទ្ធិនិងករណីយកិច្ចរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ..............................២០
កថាខណ្ឌទី៣៖ ការបញ្ចាំបន្ត ................................................................................................ ២១
**ផ្នែកទី៣ ការបញ្ចប់សិទ្ធិលើការបញ្ចាំអចលនវត្ថុ**..................................................................២២
កថាខណ្ឌទី១៖ ការសងបំណុល និងការលុបការចុះបញ្ជីសិទ្ធិលើការបញ្ចាំ .......................................២២
កថាខណ្ឌទី២៖ ការអនុវត្តកាតព្វកិច្ចតាមប្រព័ន្ធតុលាការ ..............................................................២៥
២.១. ស្ថាប័ននៃការអនុវត្ត............................................................................................ ២៧
២.២. នីតិវិធីនៃការរឹបអូសអចលនវត្ថុ ...............................................................................២៨
២.៣. នីតិវិធីនៃការលក់អចលនវត្ថុដោយបង្ខំ ...................................................................... ៣១
២.៤. នីតិវិធីចែកចំណែក...............................................................................................៣៣
**សេចក្តីសន្និដ្ឋាន**.................................................................................................................៣៦
**អនុសាសន៍**.......................................................................................................................៣៨
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងបានប្រកាន់យកនូវរបបសេដ្ឋកិច្ចទីផ្សារសេរី ដោយផ្តល់លទ្ធភាពខ្ពស់និងជម្រុញឱ្យមានការប្រកួតប្រជែងស្មើរគ្រប់វិស័យ។ ចំពោះវិស័យអចលនវត្ថុ ក៏ជាវិស័យអាទិភាពមួយនៅក្នុងចំណោមវិស័យអាទិភាពផ្សេងទៀតដែរ។ វិស័យអចលនវត្ថុត្រូវបានប្រជាពលរដ្ឋកម្ពុជាយកទៅធ្វើការចាត់ចែងយ៉ាងពេញទំហឹង សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ ជាការពិតណាស់នាពេលបច្ចុប្បន្ននេះ ការលក់ទិញ ការជួល ការបង់រម្លស់ និងការបញ្ចាំគឺជាសកម្មដែលបាន និងកំពុងមានសកម្មភាពយ៉ាងគគ្រឹកគគ្រេងពីសំណាក់ប្រជាពលរដ្ឋកម្ពុជាដែលបញ្ជាក់ឱ្យឃើញថា វិស័យអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជាកំពុងមានការចាប់អារម្មណ៍ខ្លាំង។ ជាការពិតជាក់ស្តែងក្នុងសង្គម ក្នុងករណីដែលបុគ្គលណាម្នាក់ខ្វះថវិកា ជម្រើសមួយក្នុងជម្រើសផ្សេងៗទៀតពួកគេអាចនឹងទៅខ្ចីបុលពីបុគ្គលដទៃដែលអាចជា ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ឬហាងបញ្ចាំជាអាទិ៍។ ប៉ុន្តែដើម្បីជាថ្នូរនឹងប្រាក់កម្ចី កូនបំណុលអាចនឹងមានការតម្រូវឱ្យដាក់វត្ថុបញ្ចាំ ដើម្បីធានានូវកាតព្វកិច្ចនោះតាមរយៈកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ។ ដូច្នេះប្រសិនបើកម្មវត្ថុនៃការបញ្ចាំជាអចលនវត្ថុ នោះកិច្ចសន្យាដែលនឹងត្រូវបង្កើតគឺជាកិច្ចបញ្ចាំអចលនវត្ថុដែលជាភាសាគតិយុត្តហៅថា សិទ្ធិលើការបញ្ចាំអចលនវត្ថុ។ ការបញ្ចាំមិនមែនជាសញ្ញាណដែលថ្មីស្រឡាងទេសម្រាប់ប្រទេសកម្ពុជា ដោយយើងសង្កេតឃើញថាវាមានវត្តមានតាំងពីក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ ច្បាប់ភូមិបាលឆ្នាំ២០០១ រហូតដល់បច្ចុប្បន្នគឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ នៅពេលដែលយើងនិយាយដល់សិទ្ធិលើការបញ្ចាំ នោះយើងនឹងអាចនឹកឃើញដល់សិទ្ធិប្រាតិភោគប្រត្យក្ស ដែលជាផ្នែកមួយនៃសិទ្ធិប្រត្យក្ស។[1] សិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ មានន័យថាជាសិទ្ធិផ្តាច់មុខរបស់បុគ្គលក្នុងការគ្រប់គ្រង និងដាច់ខាតចំពោះបុគ្គលនោះ។[2] ការបញ្ចាំនាពេលកន្លងមករហូតមកដល់បច្ចុប្បន្នប្រជាពលរដ្ឋកម្ពុជាជាច្រើនបានអនុវត្តអាជីវកម្មនេះក្លាយទៅជារឿងធម្មតាទៅហើយ ប៉ុន្តែមិនមែនបានន័យថាអ្នកដែលប្រកបរបរមួយនេះសុទ្ធតែយល់ច្បាស់អំពីនីតិវិធីផ្លូវច្បាប់នៃការបញ្ចាំ ឬសិទ្ធិលើការបញ្ចាំបានគ្រប់ជ្រុងជ្រោយនោះទេ។ ដោយកន្លងមកមានវិវាទជាច្រើនបានកើតឡើងក្នុងសង្គមកម្ពុជាដែលជាប់ទាក់ទងនឹងការបញ្ចាំ។ បញ្ហាទាំងនោះកើតឡើងក៏ព្រោះតែការដែលមិនដឹងច្បាស់អំពីច្បាប់ ក៏ដូចជារបបគតិយុត្តនៃប្រទេសកម្ពុជា ដែលអ្នកបើកអាជីវកម្មបញ្ចាំមួយចំនួនគ្រាន់តែបើកអាជីវកម្មដឹងពីច្បាប់បន្តិចបន្តួចនិងធ្វើតាមតែទម្លាប់ប៉ុណ្ណោះ ដូច្នេះហើយទើបមានអត្ថបទស្រាវជ្រាវស្តីពីរបបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលវត្ថុ

---

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ (ឃ-សិទ្ធិប្រតិភោគប្រត្យក្ស)។

[2] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ "សេចក្តីពន្យល់ក្រមដ្ឋប្បវេណី" ភាគី១, ឆ្នាំ ២០១៣។

ក្របខ័ណ្ឌច្បាប់កម្ពុជានេះឡើង ដើម្បីជាជំនួយដល់មិត្តអ្នកអាននិងអ្នកដែលបាននិងកំពុងអនុវត្តសិទ្ធិលើការបញ្ចាំនេះ។

ស្របតាមស្មារតីនៃច្បាប់ ជាគោលការណ៍បើយើងធ្វើការពិនិត្យឱ្យច្បាស់ទៅឃើញថាសិទ្ធិលើការបញ្ចាំគឺមានបីប្រភេទធំៗគឺ ការបញ្ចាំចលនវត្ថុ[3] ការបញ្ចាំអចលនវត្ថុ[4] និងការបញ្ចាំសិទ្ធិ[5]។ ដោយឡែកនៅក្នុងអត្ថបទសារណាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រមួយនេះ យើងនឹងធ្វើការបកស្រាយអំពីរបបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលវត្ថុតែប៉ុណ្ណោះ ដែលរួមមាននីតិវិធីនៃការបង្កើត ការអនុវត្ត និងការបញ្ចប់នៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុក្នុងក្របខ័ណ្ឌច្បាប់កម្ពុជាតែប៉ុណ្ណោះ ដោយយើងមិនធ្វើការបកស្រាយអំពីសិទ្ធិលើការបញ្ចាំចលនវត្ថុ និងសិទ្ធិលើការបញ្ចាំសិទ្ធិដែលវាមានភាពទាក់ទងនឹងសិទ្ធិលើការបញ្ចាំនោះទេ។

ជុំវិញបញ្ហានេះមានមតិមហាជនមួយចំនួនតែងតែលើកឡើងថា ការយកទ្រព្យទៅដាក់បញ្ចាំនៅពេលដែលផុតកាលកំណត់ដែលបានកំណត់នៅក្នុងកិច្ចសន្យាហើយ នោះទ្រព្យរបស់ពួកគេនឹងត្រូវបានរឹបអូសដោយម្ចាស់បំណុលដែលជាអ្នកទទួលបញ្ចាំនូវទ្រព្យនោះមិនខាន។ ដូច្នេះហើយទើបមានជាចម្ងល់ពីសំណាក់សាធារណជនថា តើទ្រព្យដែលបានដាក់បញ្ចាំ នៅពេលផុតកំណត់ហើយតើអាចទទួលបានទ្រព្យនោះមកវិញបានដែរឬទេ? ហើយការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមាននីតិវិធីបែបណាខ្លះ? តើមានការអនុវត្តបែបណាខ្លះ? និងអាចបញ្ចប់ទៅវិញបានដោយនីតិវិធីយ៉ាងដូចម្តេចខ្លះ?

នៅក្នុងអត្ថបទសារណាមួយនេះយើងបានបែងចែកជាពីរជំពូក គឺ **ជំពូកទី១ ទិដ្ឋភាពទូទៅនៃសិទ្ធិលើការបញ្ចាំនៅកម្ពុជា** និង **ជំពូកទី២ សិទ្ធិលើការបញ្ចាំអចលនវត្ថុ**។

[3] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨២៩។
[4] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨៣៥។
[5] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ,មាត្រា ៨៤០។

# ជំពូកទី១៖
# ទិដ្ឋភាពទូទៅនៃសិទ្ធិលើការបញ្ចាំនៅកម្ពុជា

កម្ពុជាជាបានអនុវត្តសិទ្ធិលើការបញ្ចាំជាច្រើនឆ្នាំមកហើយ។ ដោយឡែកអ្វីដែលយើងគួរស្វែងយល់នោះគឺថាតើមូលហេតុអ្វីបានជាកម្ពុជាទទួលយកការបញ្ចាំមកអនុវត្តនៅ និងមានទម្រង់យ៉ាងណាខ្លះ? មួយវិញទៀតចំពោះសិទ្ធិលើការបញ្ចាំមានអត្ថន័យដូចម្តេច? និងមានភាគីណាខ្លះដែលអាចមានវត្តមាននៅក្នុងកិច្ចសន្យា?

ជាការឆ្លើយតបទៅនឹងសំណួរខាងលើ យើងនឹងធ្វើការបែងចែកជាបីផ្នែក គឺ អត្ថន័យនិងកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ(ផ្នែកទី១) មូលហេតុ និងទម្រង់នៃការបញ្ចាំអចលនវត្ថុនៅកម្ពុជា(ផ្នែកទី២) និង ភាគីក្នុងទំនាក់ទំនងនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ(ផ្នែកទី៣)។

## ផ្នែកទី១៖ អត្ថន័យ និងកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ

នៅពេលដែលនិយាយអំពីសិទ្ធិលើការបញ្ចាំ អ្វីដែលគួរគប្បីពិនិត្យមុនគេបង្អស់នោះគឺ អត្ថន័យ និងកម្មវត្ថុនៃកិច្ចសន្យាដែលត្រូវបានបង្កើតឡើង ។ បើមិនដូច្នេះទេអាចនឹងមានការស្រពិចស្រពិលជាក់ជាមិនខានឡើយ។ មកដល់ទីនេះយើងនឹងធ្វើការសិក្សាទៅលើពីរចំណុចសំខាន់ៗដែលជាចំណុចគោលនៃផ្នែកទី២នេះ គឺ អត្ថន័យនៃសិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី១) និងកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

សិទ្ធិលើការបញ្ចាំ គឺជាផ្នែកមួយនៃសិទ្ធិប្រាតិភោគប្រត្យក្ស។[6] សិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ មានន័យថាគឺជាសិទ្ធិផ្តាច់មុខរបស់បុគ្គលក្នុងការគ្រប់គ្រង និងដាច់ខាតចំពោះបុគ្គលនោះ។ បើយោងតាមមាត្រា៨១៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តអំពីអត្ថន័យនៃសិទ្ធិលើការបញ្ចាំថា ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុលឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ម្ចាស់បំណុលផ្សេងទៀត គឺសំដៅទៅដល់ម្ចាស់បំណុលធម្មតាដែលគ្មានសិទ្ធិប្រាតិភោគ និងម្ចាស់បំណុលមានសិទ្ធិប្រាតិភោគដែលនៅលំដាប់បន្ទាប់។ ជាក់ស្តែងកូនបំណុលអាចនឹងមានម្ចាស់បំណុលច្រើន ហេតុនេះហើយនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ឬ អនុវត្តមិនបានពេញលេញដោយសារអលទ្ធភាពក្នុងការសងនោះអាចជាមូលហេតុនាំឱ្យមានការអនុវត្តលក់ដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃដាក់បញ្ចាំនោះបានតាមរយៈសមត្ថកិច្ចយុត្តាធិការ។ ដោយហេតុដូច្នេះហើយទើប ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដូចជាម្ចាស់សិទ្ធិលើការបញ្ចាំនឹងអាចទទួលបានការសងជាអាទិភាពជាងម្ចាស់បំណុលដទៃទៀត។ ជាមួយគ្នានេះគួរបញ្ជាក់បន្ថែមថា នៅក្នុងការបង្កើតសិទ្ធិលើការបញ្ចាំ

[6] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ (យ-សិទ្ធិប្រតិភោគប្រត្យក្ស)។

បានជាលក្ខខណ្ឌ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ កូនបំណុលចាំបាច់ត្រូវតែមានការប្រគល់និងផ្ទេរការកាន់កាប់ទ្រព្យទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំឬម្ចាស់បំណុលជាកំណត់ បើមិនដូច្នេះទេសិទ្ធិលើការបញ្ចាំមិនអាចមានអានុភាពកើតឡើងឡើយ។ ស្របតាមមាត្រា៨១៨កថាខណ្ឌទី១ក៏បានចែងដែរថា សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ លើសពីនេះទៅទៀត ច្បាប់បានហាមឃាត់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះដោយផ្ទាល់។ ក្នុងន័យនេះតាមស្មារតីជាសារវ័ន្តនៃច្បាប់ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុជាគោលការណ៍មិនអាចទាមទារការប្រាក់ពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុបាននោះទេ ហេតុដូច្នេះ ការផ្ទេរការកាន់កាប់ទៅម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុគឺចង់ផ្តល់នូវសិទ្ធិចំនួនបីជូនម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ គឺ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិបញ្ចាំបន្តលើវត្ថុបញ្ចាំនោះ។ ផ្ទុយទៅវិញបើសិនជាកម្មវត្ថុនៃការដាក់បញ្ចាំត្រូវបានកាន់កាប់ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ នោះនឹងធ្វើឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនទទួលបានផលប្រយោជន៍អ្វីឡើយពីកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ។

**កថាខណ្ឌទី២៖ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ**

ការបញ្ចាំជាគោលការណ៍ត្រូវបានបង្កើតឡើងនៅពេលដែលមានការព្រមព្រៀងរវាងគូភាគី និងការផ្ទេរការកាន់កាប់ពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំដើម្បីបំពេញលក្ខខណ្ឌគតិយុត្តក្នុងកាបង្កើតសិទ្ធិលើការបញ្ចាំដើម្បី ឱ្យកិច្ចសន្យាមានសុពលភាពក្នុងការអនុវត្តតាមគតិច្បាប់។ យ៉ាងណាមិញនៅត្រង់ចំណុចនេះយើងសូមធ្វើការគូសបញ្ជាក់ឡើងវិញបន្តិចថា ការបញ្ចាំគឺមានវត្ថុបំណងយ៉ាងជាក់ច្បាស់មួយដែលបានផ្សាភ្ជាប់ជាមួយសិទ្ធិលើការបញ្ចាំ គឺសិទ្ធិលើបំណុល ឬអាចនិយាយមួយបែបទៀតថា ការបង្កើតសិទ្ធិលើការបញ្ចាំជាទម្រង់មួយនៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ឬមិនមានភ្ជាប់ការប្រាក់ដែលមានការធានាកាតព្វកិច្ច។ ជាក់ស្តែងនៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំមានបំណងចង់ដាក់ទ្រព្យដើម្បីបញ្ចាំ គឺក្នុងហេតុផលយកទ្រព្យនោះដាក់បញ្ចាំដើម្បីធានានូវប្រាក់ដែលខ្លួនត្រូវការពីម្ចាស់សិទ្ធិលើការបញ្ចាំ។ ដោយហេតុដូច្នេះហើយទើបនៅពេលដែលមានការបង្កើតសិទ្ធិលើការបញ្ចាំនោះសិទ្ធិលើបំណុលក៏ត្រូវបានបង្កើតឡើងជាមួយគ្នានេះដែរ។

ចំពោះវត្ថុដែលអាចបង្កើតសិទ្ធិលើការបញ្ចាំមិនថាវត្ថុនោះជា ចលនវត្ថុ ឬ អចលនវត្ថុទេគឺសុទ្ធតែអាចបង្កើតកិច្ចសន្យាបញ្ចាំ(សិទ្ធិលើការបញ្ចាំ)បានទាំងអស់ មិនតែប៉ុណ្ណោះបើសិនជាអ្នកមានបំណងបង្កើតសិទ្ធិលើការបញ្ចាំមានសិទ្ធិលើបំណុល ក៏អាចបង្កើតសិទ្ធិលើការបញ្ចាំបានដែរគឺ បង្កើតតាមរយៈការបញ្ចាំសិទ្ធិ។[7]

ដោយឡែកនៅក្នុងអត្ថបទសារណានេះនឹងសិក្សាទៅលើការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ដូច្នេះ ដើម្បីឱ្យមានភាពច្បាស់លាស់ជាក់លាក់ ចំណុចដែលត្រូវសង្កត់ធ្ងន់គឺទៅលើសិទ្ធីលើការបញ្ចាំអចលនវត្ថុតែមួយ

[7] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៨៤០។

មុខតែប៉ុណ្ណោះ។ ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ កម្មវត្ថុនៃការដាក់បញ្ចាំត្រូវតែជា អចលនវត្ថុ។ ពាក្យថាអចលនវត្ថុ គឺ សំដៅទៅលើដីធ្លី និងវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូ ទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ។ល។[8] ចំពោះអចលនវត្ថុដែលជា ដី អាចមានពីប្រភេទ គឺ ដីភោគៈ និងដីកម្មសិទ្ធិស្ថាពរ។ គួររំលឹកថា ដីភោគៈ គឺជាដីមួយប្រភេទដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុធ្វើឡើងមុនឆ្នាំ២០០២ដែលមិនទាន់ត្រូវបានចុះបញ្ជីដីធ្លីជាប្រព័ន្ធ ឬ ដាច់ដោយដុំនៅឡើយ រីឯដីកម្មសិទ្ធិស្ថាពរ គឺជាដីដែលមាន វិញ្ញាបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលបានធ្វើឡើងក្រោយឆ្នាំ២០០២ ដោយមានការចុះបញ្ជីដីធ្លីជាប្រព័ន្ធឬដាច់ដោយដុំ។ ដីទាំងពីរប្រភេទនេះគឺសុទ្ធសឹងតែជាដីដែលអាចធ្វើជាកម្មវត្ថុនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុបានដោយសុពលភាព។

## ផ្នែកទី២៖ មូលហេតុ និងទម្រង់នៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅកម្ពុជា

ជាធម្មតាការបង្កើតកិច្ចសន្យាអ្វីមួយគឺមានគោលបំណងមួយឬច្រើនអាស្រ័យទៅតាមទម្រង់នៃកិច្ចសន្យានីមួយៗដែលភាគីចង់បាន។ គោលបំណងនោះអាចជាផលប្រយោជន៍សម្រាប់ភាគីនៃកិច្ចសន្យាដែលបានព្រមព្រៀងបង្កើតឡើង។ ជាក់ស្តែងមូលហេតុដែលបង្កើតឱ្យមានកិច្ចសន្យាបញ្ចាំដែលជាភាសាគតិយុត្តកម្ពុជាហៅថាការបង្កើតសិទ្ធិលើការបញ្ចាំ ជាគោលបំណងនៃច្បាប់ គឺដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងសង្គមកម្ពុជា។ ដើម្បីជាការស្រាយបំភ្លឺនៅត្រង់ចំណុចនេះយើងនឹងធ្វើការបែងចែកជាពីរកថាខណ្ឌ គឺ មូលហេតុនៃការបញ្ចាំនៅកម្ពុជា(កថាខណ្ឌទី១) និង ទម្រង់នៃការបញ្ចាំនៅកម្ពុជា(កថាខណ្ឌទី២)។

### កថាខណ្ឌទី១៖ មូលហេតុនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅកម្ពុជា

ដូចដែលយើងបានដឹងទាំងអស់គ្នាទៅហើយថារាល់កិច្ចសន្យាដែលភាគីបានធ្វើការព្រមព្រៀង គឺ អាចដោយសាតែការព្រមព្រៀងនោះបានផ្តល់ផលប្រយោជន៍ដល់គូភាគី។ ជុំវិញបញ្ហានេះ ជាការការកត់សម្គាល់ឃើញថាការបង្កើតកិច្ចសន្យាបញ្ចាំក៏មិនខុសពីកិច្ចសន្យាដទៃទៀតប៉ុន្មានដែរ ដែលត្រូវបានបង្កើតឡើងតាមរយៈឆន្ទៈរបស់គូភាគី។ ពាក់ព័ន្ធនឹងបញ្ហានេះ គួរគូសបញ្ជាក់បន្ថែមថា កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬ រំលត់នូវកាតព្វកិច្ច។[9] កិច្ចសន្យាបញ្ចាំដែលជាភាសាគតិយុត្តត្រូវបានហៅថាសិទ្ធិលើការបញ្ចាំ គឺបានផ្តល់ផលប្រយោជន៍ទាំងភាគីខាងម្ចាស់បំណុល(ម្ចាស់សិទ្ធិលើការបញ្ចាំ) និងភាគីខាងកូនបំណុល(អ្នកបង្កើតសិទ្ធិលើការបញ្ចាំ)។ ដើម្បីជាការបញ្ជាក់ឱ្យកាន់តែច្បាស់ទៅកាន់មតិខាងលើខាងក្រោមនេះនឹងធ្វើការបកស្រាយបញ្ជាក់បន្ថែម។

[8] សន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[9] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣១១។

ក្នុងសកម្មភាពជីវភាពជាក់ស្តែង នៅពេលដែលបុគ្គលណាម្នាក់មានការខ្វះខាតឬត្រូវការប្រាក់ជាបន្ទាន់ បុគ្គលនោះអាចនឹងស្វែងរក ឬ នឹករកវិធីសាស្ត្រផ្សេងៗដើម្បីទទួលបានប្រាក់ដែលខ្លួនត្រូវការជាបន្ទាន់នោះ។ ជាពិសេសក្នុងករណីដែលខ្វះខាតថវិកាសម្រាប់ទ្រទ្រង់ជីវភាពឬពង្រីកអាជីវកម្ម ប៉ុន្តែបុគ្គលនោះអាចនឹងមានជាទ្រព្យសម្បត្តិផ្សេងៗដើម្បីប្តូរជាប្រាក់ដោយការលក់ ការជួល ឬតាមសកម្មភាពផ្សេងៗទៀត។ ដោយហេតុនេះក្តីសម្រាប់ការលក់អាចនឹងប្រើពេលវេលាវែងក្នុងការទទួលបានអតិថិជនដែលអាចឱ្យតម្លៃបានសមរម្យ រីឯការជួលវិញអាចនឹងបានកម្រៃតិចជាមួយនឹងការប្រើរយៈពេលយូរក្នុងការអនុវត្ត នេះប្រសិនបើក្នុងករណីដែលមានទ្រព្យដែលអាចលក់ឬជួលបានភ្លាមតែប៉ុណ្ណោះ ដោយឡែកបើបុគ្គលនោះមានទ្រព្យដែលជាអចលនវត្ថុ អាចគិតសាកទៅមើលថាតើនៅពេលដែលមានដាក់លក់ឬជួលភ្លាមអាចនឹងមានអតិថិជនភ្លាមៗដែរឬទេ? ជាចម្លើយគឺមិនងាយនឹងមានទេ ហើយបើសិនជាមានក៏ក្នុងករណីតិចតួចតែប៉ុណ្ណោះ ដោយសារតែអចលនវត្ថុជាវត្ថុមួយប្រភេទដែលមានតម្លៃថ្លៃ និងមានការជាប់ពាក់ព័ន្ធនឹងការផ្ទេរការកាន់កាប់ក្នុងរូបភាពផ្សេងៗដែលតម្រូវឱ្យមានការចុះបញ្ជីចារបន្ទុកនៅស្ថាប័នមានសមត្ថកិច្ច ហើយជួនកាលដោយសាការចរចារគ្នាមិនត្រូវក៏រំសាយទៅវិញ។ ដោយហេតុនេះហើយទើបបុគ្គលដែលមានបំណងទិញអចលនវត្ថុត្រូវពិចារណាច្រើនជាងការទិញចលនវត្ថុ។ ជម្រើសល្អមួយក្នុងជម្រើសផ្សេងៗទៀតនោះគឺការដាក់បញ្ចាំ ព្រោះថាការដាក់បញ្ចាំមានលក្ខណៈឆាប់រហ័សដោយគ្រាន់តែអ្នកចង់បង្កើតសិទ្ធិលើការបញ្ចាំមានទ្រព្យដើម្បីបញ្ជាក់ទៅម្ចាស់សិទ្ធិលើការបញ្ចាំ(ម្ចាស់បំណុល) បន្ទាប់មកមានការព្រមព្រៀងនិងការផ្ទេរការកាន់កាប់រវាងគូភាគី នោះកិច្ចសន្យាបញ្ចាំនឹងមានសុពលភាព។ មូលហេតុដែលការដាក់បញ្ចាំប្រើរយៈពេលខ្លីក្នុងការពិចារណា គឺដោយសារតែការដាក់បញ្ចាំម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យទំហំនៃប្រាក់ស្មើឬលើសពីទំហំតម្លៃនៃវត្ថុទេ ហើយការទទួលផលចំណេញពីវត្ថុដាក់បញ្ចាំមានច្រើនគួរសមសម្រាប់ម្ចាស់សិទ្ធិលើការបញ្ចាំ ជាហេតុដែលម្ចាស់សិទ្ធិលើការបញ្ចាំមានការពិចារណាបានឆាប់រហ័ស។ ដូច្នេះសម្រាប់អ្នកបង្កើតសិទ្ធិលើការបញ្ចាំក៏អាចទទួលបានប្រាក់ឆាប់រហ័យតាមនោះដែរ។ រីឯអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំនោះវិញ អ្នកបង្កើតសិទ្ធិលើការបញ្ចាំនឹងទទួលបានមកវិញនៅពេលដែលខ្លួនសងប្រាក់ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំបានគ្រប់ចំនួន។

ការអធិប្បាយខាងលើនេះបានបង្ហាញពីផលប្រយោជន៍របស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ បន្តទៅទៀតនេះយើងនឹងពិនិត្យបន្ថែមទៀតទៅលើផលប្រយោជន៍របស់ម្ចាស់សិទ្ធិលើការបញ្ចាំវិញម្តង។ តាមស្មារតីជាសារវន្តនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អាចឱ្យឃើញពីអត្ថិភាពនៃសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំមានចំនួនពីរធំៗ គឺ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផល ។ នេះគឺមានន័យថាម្ចាស់សិទ្ធិលើការបញ្ចាំ បន្ទាប់ពីសិទ្ធិលើការបញ្ចាំត្រូវបានបង្កើតឡើងរួចហើយ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុ ទទួលផលប្រយោជន៍ពីវត្ថុ ក៏ដូចជាការយកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅដាក់បញ្ចាំបន្តបាន។ ជាពិសេសសម្រាប់អចលនវត្ថុ សិទ្ធិប្រើប្រាស់និងសិទ្ធិអាស្រ័យផល

ជាសិទ្ធិដែលមានសារៈសំខាន់និងមានផលប្រយោជន៍ច្រើនសម្រាប់អ្នកដែលមានសិទ្ធិកាន់កាប់លើអចលនវត្ថុនោះ។ ជាក់ស្តែងបើសិទ្ធិប្រើប្រាស់ សម្រាប់អចលនវត្ថុដែលជាដីសម្រាប់ធ្វើកសិកម្ម ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកដីនោះដើម្បីបង្កបង្កើនផលដំណាំផ្សេងៗដើម្បីបានប្រាក់កម្រៃបន្ថែមក្នុងពេលដែលខ្លួនបាននឹងកំពុងអនុវត្តសិទ្ធិលើការបញ្ចាំក្នុងនាមជាម្ចាស់បំណុល។ មួយវិញទៀតប្រសិនបើដីនោះជាដីដែលអាចអនុវត្តផ្នែកឧស្សាហកម្ម ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកអចលវត្ថុនោះទៅជួលឱ្យតតិយជនដែលនៅក្នុងក្របខ័ណ្ឌកតិសន្យាបានថែមទៀតផង។ លើសពីនេះទៅទៀតម្ចាស់សិទ្ធិលើការបញ្ចាំនៅមានសិទ្ធិមួយទៀតដែលអាចអនុវត្តបានក្នុងពេលដែលខ្លួនកំពុងអនុវត្តសិទ្ធិលើការបញ្ចាំគឺសិទ្ធិបញ្ចាំបន្ត។ ចំពោះលក្ខខណ្ឌផ្សេងៗដែលទាក់ទងនឹង សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផលក៏ដូចជាសិទ្ធិបញ្ចាំបន្តនឹងធ្វើការរៀបរាប់ពន្យល់លម្អិតនៅ**ជំពូកទី២ស្តីពីសិទ្ធិលើការបញ្ចាំអចលនវត្ថុ**។

**កថាខណ្ឌទី២៖ ទម្រង់នៃការបង្កើតសិទ្ធិលើការបញ្ចាំនៅកម្ពុជា**

នៅក្នុងបរិបទសង្គមកម្ពុជាជាការកត់សម្គាល់តាមធម្មតាឃើញថា ការបង្កើតសិទ្ធិលើការបញ្ចាំអាចកើតឡើងតាមទម្រង់ផ្សេងៗដែលអាស្រ័យទៅតាមស្ថានភាពនីមួយៗរបស់គូភាគីនៃកិច្ចសន្យា។ ដូច្នេះតើរូបភាពបែបណាខ្លះដែលអាចហៅថាជាការបញ្ចាំ?

នៅពេលដែលនិយាយអំពីកិច្ចសន្យាបញ្ចាំ ប្រជាពលរដ្ឋមួយចំនួនបានគិតថា មានតែការយកវត្ថុទៅដាក់បញ្ចាំនៅហាងបញ្ចាំ ឬ កន្លែងដែលមានអាជ្ញាប័ណ្ណប៉ុណ្ណោះទើបអាចជាកិច្ចសន្យាដែលមានសុពលភាព។ ហើយបើនិយាយឱ្យប្រាកដទៅ កិច្ចសន្យាបញ្ចាំមិនចាំបាច់ទាល់តែមានការយកវត្ថុទៅដាក់បញ្ចាំនៅហាងបញ្ចាំ ឬកន្លែងអាជីវកម្មទទួលបញ្ចាំដែលមានអាជ្ញាប័ណ្ណទេ ការដាក់បញ្ចាំអាចធ្វើបានជាលក្ខណៈឯកជនក៏បានដែរ រីឯសុពលភាពនៃកិច្ចសន្យាក៏មានសុពលភាពដែរ នេះបើយោងតាមអត្ថន័យជារួមនៃមាត្រា៨១៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ជាឧទាហរណ៍ជាក់ស្តែងដែលប្រជាពលរដ្ឋកម្ពុជាតែងអនុវត្តនោះគឺ ការខ្ចីប្រាក់ដែលជាពាក្យគតិយុត្តហៅថា ការខ្ចីបរិភោគ[10]។ ការខ្ចីប្រាក់អាចមានឬគ្មានវត្ថុដើម្បីដាក់ធានាលើបំណុល ប៉ុន្តែបើសិនជាការខ្ចីប្រាក់ដែលមានដាក់វត្ថុដើម្បីធានាសិទ្ធិលើបំណុលនិងមានការផ្ទេរការកាន់កាប់លើវត្ថុនោះគឺជារូបភាពនៃសិទ្ធិលើការបញ្ចាំហើយ។ ដោយឡែកចំពោះករណីបែបនេះមិនមែនជាកំហុសឆ្គងក្នុងការអនុវត្តតាមបញ្ញត្តិច្បាប់ទេ បើសិនជាការអនុវត្តនោះគ្រាន់តែជាការដោះទាល់ម្តងម្កាលជាលក្ខណៈឯកជន ប៉ុន្តែបើសិនជាអ្នកដែលទទួលវត្ថុបញ្ចាំមានបំណងបើកជាអាជីវកម្មទទួលការបញ្ចាំជាទូទៅសម្រាប់សារធារណៈជន អ្នកទទួលវត្ថុបញ្ចាំត្រូវធ្វើការស្នើសុំអាជ្ញាប័ណ្ណពីក្រសួងដែលមានសមត្ថកិច្ច(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)ដើម្បីប្រកបអាជីវកម្មបញ្ចាំឱ្យមានសុពលភាពតាមច្បាប់។

ដោយហេតុថានៅអត្ថបទស្រាវជ្រាវនេះធ្វើការសិក្សាតែអំពីសិទ្ធិលើការបញ្ចាំអចលនវត្ថុដែលជាសិទ្ធិមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលមានកំណត់ក្នុងច្បាប់សារធាតុនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដូច្នេះចំពោះ

[10] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា៥៧៨។

នីតិវិធីផ្សេងៗនៃការស្នើសុំអាជ្ញាប័ណ្ណ ឬ នីតិវិធីក្នុងការបង្កើតក្រុមហ៊ុនឬសហគ្រាសដើម្បីបើកអាជីវកម្មបញ្ចាំនឹងមិនត្រូវបានបកស្រាយឡើយ។

**ផ្នែកទី៣៖ ភាគីក្នុងទំនាក់ទំនងនៃសិទ្ធិលើការបញ្ចាំ**

អនុលោមតាមមាត្រា៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តថារូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចបាន។ នៅក្នុងទំនាក់ទំនងនៃសិទ្ធិលើការបញ្ចាំភាគីជាប្រធាននៃកិច្ចសន្យា។ ដូចដែលយើងបានសិក្សាពីខាងដើមរួចមកហើយថា នៅក្នុងកិច្ចសន្យាភាគីនៃកិច្ចសន្យាបញ្ចាំបានបង្កើតសិទ្ធិចំនួនពីរគឺសិទ្ធិលើការបញ្ចាំនិងសិទ្ធិលើបំណុលដែលមានភាពជាសារវន្តនៅក្នុងកិច្ចសន្យា។ ជាការឆ្លើយតបនឹងចំណុចនេះ យើងនឹងធ្វើការបែងចែកជាពីរកថាខណ្ឌគឺ ភាគីនៃសិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី១) និងភាគីនៃសិទ្ធិលើបំណុល(កថាខណ្ឌទី២)។

**កថាខណ្ឌទី១៖ ភាគីនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ**

សិទ្ធិលើការបញ្ចាំគឺជាសិទ្ធិមួយដែលម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលទទួលបានពីកូនបំណុល(អ្នកបង្កើតសិទ្ធិលើការបញ្ចាំ) ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន។[11] ដោយហេតុដូច្នេះអាចបង្ហាញឱ្យឃើញថា ភាគីនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុរួមមាន អ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ និងម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ។ នៅពេលអនុវត្តសិទ្ធិលើការបញ្ចាំអចលនវត្ថុ អ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុជាអ្នកផ្ទេរការកាន់កាប់ទៅម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ រីឯម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុជាអ្នកទទួលការកាន់កាប់ទៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំនោះ។ លុះដល់កាលកំណត់ដែលត្រូវអនុវត្តកាតព្វកិច្ចសង អ្នកបង្កើតសិទ្ធិលើការបញ្ចាំនឹងត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាកូនបំណុលដើម្បីធ្វើការប្រគល់ប្រាក់ជាការសងទៅម្ចាស់សិទ្ធិលើការបញ្ចាំដែលជាម្ចាស់បំណុលរបស់ខ្លួន ហើយម្ចាស់សិទ្ធិលើការបញ្ចាំនឹងមានកាតព្វកិច្ចក្នុងការប្រគល់ការកាន់កាប់ទៅឱ្យម្ចាស់ដើមវិញ បន្ទាប់មកកិច្ចសន្យាបញ្ចាំអចលនវត្ថុនឹងត្រូវបានរលត់តាមរយៈការសងដោយកូនបំណុល។ យ៉ាងណាមិញដើម្បីបញ្ចប់សិទ្ធិលើការបញ្ចាំ នៅមាននីតិវិធីមួយចំនួនទៀតដែលគូភាគីត្រូវបំពេញដើម្បីឱ្យការរំលត់នោះមានភាពត្រឹមត្រូវនិងសុក្រិតយុត្តិធម៌ និងជាប្រយោជន៍ដល់គូភាគីនៃកិច្ចសន្យាដែលយើងមិនអាចធ្វើការសិក្សាទាំងអស់នៅតែក្នុងចំណុចនេះមួយបាឡើយ ដូច្នេះហើយរាល់កិច្ចនីតិវិធីទាំងឡាយដែលមានភាពជាសារវន្តនឹងត្រូវបានរៀបរាប់បន្ថែមក្នុង ផ្នែកទី៣**ការបញ្ចប់សិទ្ធិលើការបញ្ចាំអចលនវត្ថុ**នៃជំពូកទី២**សិទ្ធិលើការបញ្ចាំអចលនវត្ថុ**។

[11] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៨១៦។

**កថាខណ្ឌទី២៖ ភាគីនៃសិទ្ធិលើបំណុល**

សិទ្ធិលើបំណុលគឺជាសិទ្ធិមួយដែលម្ចាស់បំណុលអាចអនុវត្តបានទៅលើកូនបំណុល។ ជាមួយគ្នានេះនៅក្នុងកិច្ចសន្យាស្តីពីការបញ្ចាំអចលនវត្ថុ គូភាគីនៃកិច្ចសន្យាទំនងជាមានតែអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិលើការបញ្ចាំតែប៉ុណ្ណោះ ដូច្នេះកូនបំណុលដែលត្រូវអនុវត្តកាតព្វកិច្ចអាចមានត្រឹមតែ អ្នកបង្កើតសិទ្ធិលើការបញ្ចាំតែម្នាក់ទេ ក៏ប៉ុន្តែជាសំណួរអាចធ្វើការចោទសួរថា ប្រសិនបើអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមិនមានវត្ថុដើម្បីដាក់បញ្ចាំ តើបុគ្គលដែលមានបំណងចង់បង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុនោះនឹងអាចបង្កើតបានដែរឬទេ? ហើយបើសិនជាអាចបង្កើតបានតើនឹងមាននីតិវិធីយ៉ាណាខ្លះ?

ក្នុងការអនុវត្តជាក់ស្តែងករណីបែបនេះអាចនឹងកើតមានច្រើន ពីព្រោះដោយសាតែបុគ្គលដែលចង់បង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុខ្វះទាំងធនធាន និង វត្ថុដើម្បីធ្វើការដាក់បញ្ចាំឱ្យកិច្ចសន្យាបញ្ចាំអចលនវត្ថុមានសុពលភាពតាមបញ្ញត្តិច្បាប់ដែលបានកំណត់។ ក្នុងករណីនេះប្រសិនបើអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនមានអចលនវត្ថុដើម្បីដាក់ប្រាតិភោគក្នុងការធានាសិទ្ធិលើបំណុលរបស់ខ្លួននោះទេ អ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចមានជម្រើសមួយទៀតដើម្បីអាចបង្កើតសិទ្ធិបញ្ចាំបាននោះគឺ ត្រូវមានអ្នកធានាដោយវត្ថុ។ អ្នកធានាដោយវត្ថុ គឺជាបុគ្គលដែលបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ។ [12] នៅក្នុងជីវភាពរស់នៅជាក់ស្តែង នៅពេលដែលបុគ្គលម្នាក់ខ្វះខាតផ្នែកហិរញ្ញវត្ថុនិងគ្មានវត្ថុដើម្បីដាក់ធានាលើបំណុលនោះ ជាធម្មតាបុគ្គលនោះអាចនឹងពឹងបុគ្គលម្នាក់ផ្សេងទៀតដែលអាចជាសាច់ញាតិឬអ្នកដែលស្គាល់ជិតដិតណាម្នាក់ក៏បានដែលមានវត្ថុ(អចលនវត្ថុ)អាចដាក់អចលនវត្ថុដើម្បីធានាសិទ្ធិលើបំណុលបាន ដោយច្បាប់បានបើកផ្លូវសម្រាប់កូនបំណុល អាចមានអ្នកធានាដោយវត្ថុបាន។ ក្នុងបុព្វហេតុដូច្នេះទើបការបង្កើតសិទ្ធិលើការបញ្ចាំអាចមានភាគីដែលជាអ្នកធានាដោយវត្ថុម្នាក់ទៀតដែលជាភាគីនៃសិទ្ធិលើបំណុលអាចមានវត្តមាននៅក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុ ឬការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ។

ស្របតាមការអធិប្បាយខាងលើរួចមកឃើញថា ភាគីដែលអាចមានវត្តមានក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុ ឬ សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចមានវត្តមានភាពរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនិងម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ឬ វត្តមានភាពនៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ និងអ្នកធានាដោយវត្ថុ(អចលនវត្ថុ)ដែលជាភាគីនៃសិទ្ធិលើបំណុល។

[12] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧៦ កថាខណ្ឌទី១។

# ជំពូកទី២៖
# សិទ្ធិលើការបញ្ចាំអចលនវត្ថុ

## ផ្នែកទី១៖ ការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ

វិស័យអចលនវត្ថុនៅតែជាវិស័យសំខាន់មួយក្នុងចំណោមវិស័យសំខាន់ៗផ្សេងទៀត ដែលប្រជាពលរដ្ឋកម្ពុជាយកទៅធ្វើការចាត់ចែងយ៉ាងពេញទំហឹង មិនថាសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ឬការលក់ចេញទិញចូលផ្សេងៗឡើយ។ យ៉ាងណាមិញការបញ្ចាំអចលនវត្ថុក៏ត្រូវបានប្រជាពលរដ្ឋកម្ពុជាចាត់ទុកថាជាយន្តការមួយដែលជួយសម្រួលដល់ជីវភាពរស់នៅ និងសកម្មភាពអាជីវកម្មបានច្រើនដែរ។ ដើម្បីឱ្យកាន់តែយល់ច្បាស់លើជំពូកនេះ យើងនឹងបែងចែកជាបីកថាខណ្ឌ គឺកថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ និងកថាខណ្ឌទី៣ នីតិវិធីក្នុងការចុះបញ្ជី។

### កថាខណ្ឌទី១៖ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ

កិច្ចសន្យាត្រូវបានបង្កើតឡើងដោយបុគ្គលចាប់ពីពីរអ្នកឡើងទៅ ហើយត្រូវមានឆន្ទៈត្រូវគ្នាក្នុងការបង្កើតកិច្ចសន្យានោះ។ ចំពោះកិច្ចសន្យាបញ្ចាំអចលនវត្ថុ ការព្រមព្រៀងពិតប្រាកដ និង ដោយសេរី ភាគីមានសមត្ថភាពធ្វើកិច្ចសន្យា មានកម្មវត្ថុមួយជាក់លាក់ ដែលលក្ខណៈទាំងនេះ វាជាធាតុផ្សំដ៏សំខាន់ក្នុងការបង្កើតកិច្ចសន្យា។ ម្យ៉ាងវិញទៀត ត្រូវសិក្សាផងដែរចំពោះការបង្ហាញឆន្ទៈរបស់ភាគី ដើម្បីឱ្យស្របតាមការបង្កើតកិច្ចសន្យាដែលមាននៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧។ ផ្អែកតាមមាត្រា៣១០នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បានឱ្យនិយមន័យនៃការបង្ហាញឆន្ទៈថា៖ ការបង្ហាញឆន្ទៈរបស់ភាគី ដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថាការបង្ហាញឆន្ទៈ ហើយការបង្ហាញឆន្ទៈនេះត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត។ ជាការពិតណាស់ ការបង្ហាញឆន្ទៈ ជាការបង្ហាញនូវអារម្មណ៍ ឬគំនិតនៅក្នុងការធ្វើអ្វីមួយ ទោះបីជាការសម្តែងនោះលេចចេញជារូបរាងតាមការនិយាយស្តី សំណេរ ឬកាយវិការ ឬការចាត់ទុកថាយល់ព្រមដោយតុណ្ហីភាព។ ការបង្ហាញឆន្ទៈផងដែរនោះតែងតែស្តែងឱ្យមានការព្រមព្រៀងរវាងគូភាគី និង ការបង្ហាញ ឆន្ទៈដោយពិតប្រាកដ និងដោយសេរី។ ដើម្បីជាការបញ្ជាក់ឱ្យកាន់តែច្បាស់ យើងបានធ្វើការបែងចែកជាប្រាំចំណុច ដើម្បីយកមកធ្វើការអធិប្បាយសម្រាយបញ្ជាក់ គឺ (១.១) ការព្រមព្រៀងរវាងគូភាគី (១.២) ការបង្ហាញឆន្ទៈដោយប្រាកដ និងដោយសេរី (១.៣) ការផ្ទេរការកាន់កាប់ (១.៤) ការហាមកិច្ចសន្យាបញ្ចាំផ្តាច់ និង (១.៥) អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ។

#### ១.១. ការព្រមព្រៀងរវាងគូភាគី

ការព្រមព្រៀង សំដៅទៅលើការចរចារគ្នា រវាងគូភាគីទាំងសងខាងដើម្បីបង្កើតនូវអ្វីមួយ ហើយសុពលភាពនៃកិច្ចសន្យាកើតឡើងដោយការផ្លាស់ប្តូរគ្នានូវការព្រមព្រៀងទៅវិញទៅមក និងភាគីទាំងសងខាង បានទទួលយល់ព្រមទៅវិញទៅមកផងដែរ។ គ្រប់កិច្ចសន្យាទាំងអស់ ត្រូវបានកើតចេញពីការត្រូវគ្នារវាងសំណើ និង

ការយល់ព្រមដែលហៅថាស្ទីការ ហើយមិនត្រូវឱ្យមានភាគីណាម្ខាងប្រព្រឹត្តិនូវកំហុសទេ ព្រោះថាបើរកឃើញថាភាគីណាម្ខាងមានកំហុសនោះ កិច្ចសន្យមិនត្រូវបង្កើតឡើងទេ។

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ពីនិយមន័យនៃសំណើថា គឺជាកាសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[13] សំណើ គ្រាន់ជាការបង្ហាញឆន្ទៈជាឯកតោភាគី មានន័យថាមានតែភាគីតែម្ខាងប៉ុណ្ណោះដែលដាក់នូវសំណើទៅភាគីម្ខាងទៀត ដើម្បីធ្វើឱ្យមានការទទួលស្គាល់ និង យល់ព្រមនូវបំណងរបស់គេនៅក្នុងការបង្កើតកិច្ចសន្យា និង លក្ខខណ្ឌសំខាន់នៃកិច្ចសន្យានោះ។ កាលបើសំណើត្រូវបានយល់ព្រមដោយភាគីម្ខាងទៀតត្រូវបានហៅថាជាស្ទីកានោះកិច្ចសន្យាត្រូវបានកើតឡើង។ ចំពោះសំណើក្នុងការដាក់បញ្ចាំនូវអចលនវត្ថុដើម្បីធានាបំណុលដោយទទួលបានមកវិញនូវប្រាក់កម្ចី ត្រូវបានតម្រូវឱ្យមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ហើយត្រូវមានទ្រព្យយកមកធានានៅក្នុងការដាក់បញ្ចាំ។ ដូច្នេះការដែលកិច្ចសន្យាមួយត្រូវបានកើតឡើងបានដោយសាតែ មានការបង្ហាញឆន្ទៈតាមរយៈសំណើ និង មានការយល់ព្រមពីភាគីម្ខាងទៀតដែលហៅថា ស្ទីការ។

**១.២. ការបង្ហាញឆន្ទៈដោយពិតប្រាកដ និងដោយសេរី**

ការបង្ហាញឆន្ទៈ ដោយពិតប្រាកដ សំដៅទៅលើការបង្ហាញឆន្ទៈដោយសុច្ចរិតថា ខ្លួនពិតជាមានឆន្ទៈចង់បង្កើតកិច្ចសន្យាដាក់បញ្ចាំអចលនវត្ថុ ដើម្បីទទួលបាននូវប្រាក់ និង ដើម្បីយកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ឬការធ្វើអាជីវកម្ម ឬក៏ធ្វើអ្វីផ្សេងដែលជាតម្រូវការរបស់បុគ្គលម្នាក់ៗ។ ចំពោះការបង្ហាញឆន្ទៈដោយសេរីជាការបង្ហាញឆន្ទៈដោយខ្លួនឯង គ្មានការបង្ខិតបង្ខំ គ្មានការគម្រាមកំហែង ឬ ស្ថិតនៅក្រោមអំណាចឥទ្ធិពលរបស់អ្នកណាឡើយ។ ការបង្ហាញឆន្ទៈដោយពិតប្រាកដ និងដោយសេរី អាចធ្វើបានលុះត្រាតែអវត្តមាននូវវិការៈនៃការបង្ហាញឆន្ទៈដែលស្របទៅតាមមាត្រា៣៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលបានបញ្ញត្តថា អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយមូលហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈតាមបញ្ញត្តិផ្នែកទី២ (វិការៈនៃការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី៣(មោឃៈភាព និង ការលុបចោល) ក្នុងករណីដូចជា ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ[14] ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក[15] ឬ ការបង្ហាញឆន្ទៈតាមរយៈព័ត៌មានមិនពិតរបស់ភាគីម្ខាងទៀត[16] ឬ ការរំលោភបំពានលើស្ថានភាព[17]

[13] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៧។

[14] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៦។

[15] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៧។

[16] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៨។

[17] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៩។

ឬ ការគម្រាមកំហែង[18] និងការបង្ហាញឆន្ទៈដែលត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ[19]។ តាមការបង្ហាញឆន្ទៈ ក៏ដូចជា តាមការព្រមព្រៀងពុំទាន់គ្រប់គ្រាន់នៅឡើយទេសម្រាប់ការបង្កើតសិទ្ធិលើការបញ្ចាំអចលវត្ថុ គឺត្រូវមានការផ្ទេរការកាន់កាប់(១.៣)។

**១.៣. ការផ្ទេរការកាន់កាប់**

ការផ្ទេរការកាន់កាប់ ដូចដែលមានបញ្ញត្តក្នុងមាត្រា៨១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ស្តីពីការបង្កើតសិទ្ធិលើការបញ្ចាំនិង ការប្រគល់វត្ថុចាំបាច់ បានបញ្ញត្តថា សិទ្ធិលើការបញ្ចាំត្រូវកើតឡើងដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ និង ការប្រគល់ដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេបដែលកំណត់នៅក្នុងកថាខណ្ឌទី៣ នៃមាត្រា២២៩(ការផ្ទេរការកាន់កាប់)នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

មាត្រាខាងលើនេះ បានចែងពីលក្ខខណ្ឌនៃការប្រគល់វត្ថុ ដែលជាសិទ្ធិលើការបញ្ចាំអចលនវត្ថុ មានន័យថាសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនត្រូវបានកើតមានអានុភាពទេ បើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំមិនត្រូវបានប្រគល់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។[20] ដូច្នេះបើនិយាយអំពីការប្រគល់ គឺអាចស្តែងឡើងតាមរយៈរូបភាពបីយ៉ាងគឺ (១.៣.១)ការប្រគល់ជាក់ស្តែង (១.៣.២) ការប្រគល់ដោយសង្ខេប និង (១.៣.៣)ការប្រគល់ដោយបញ្ជា។

**១.៣.១. ការប្រគល់ជាក់ស្តែង**

ការប្រគល់ជាក់ស្តែង ផ្អែកតាមមាត្រា២២៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ស្តីពីការផ្ទេរការកាន់កាប់ បានបញ្ញត្តថា ការកាន់កាប់ត្រូវបានផ្ទេរ ដោយការប្រគល់វត្ថុកាន់កាប់។ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការប្រគល់ដោយជាក់ស្តែង។ មានន័យថា ការប្រគល់ដោយជាក់ស្តែង គឺស្តែងឡើងដោយការផ្ទេរនូវអចលនវត្ថុនោះដោយផ្ទាល់។ ដូច្នេះការប្រគល់ជាក់ស្តែងចំពោះអចលនវត្ថុគឺមានន័យថា កម្មសិទ្ធិករនៃអចលនវត្ថុដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ បានផ្ទេរនូវសិទ្ធិកាន់កាប់ដែលខ្លួនធ្លាប់មានទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុកាន់កាប់ជំនួសតាមរយៈកិច្ចសន្យាបញ្ចាំអចលនវត្ថុ។

**១.៣.២. ការប្រគល់ដោយសង្ខេប**

ការប្រគល់ដោយសង្ខេប តាមមាត្រា២២៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ស្តីពីការផ្ទេរការកាន់កាប់ បើអ្នកដែលនឹងទទួលអនុប្បទាន(អនុប្បទាននិក)នូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះតាមការជាក់ ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ។ ដោយហេតុនេះអនុប្បទាយីនៃការកាន់កាប់ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មានតាមរយៈការក្តាប់ទុកវត្ថុ

[18] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥០។

[19] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥១។

[20] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី" ភាគ៤, មាត្រា ៨១៨។

កាន់កាប់។ ឬអាចនិយាយបានដោយខ្លីថា ការប្រគល់ដោយសង្ខេប គឺសំដៅដល់ការផ្ទេរការកាន់កាប់តាមរយៈការព្រមព្រៀងរបស់គូភាគីក្នុងករណីអនុប្បទានិកបានក្ដាប់ទុកវត្ថុដែលជាកម្មវត្ថុនៃការកាន់កាប់នោះ នៅក្នុងដៃតាមការជាក់ស្ដែងហើយអនុប្បទាយីបានបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយសង្ខេប។

**១.៣.៣. ការប្រគល់ដោយបញ្ជា**

ការផ្ទេរការកាន់កាប់ដោយបញ្ជា មាត្រា២២៩ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ស្ដីពីការផ្ទេរការកាន់កាប់ បានបញ្ញត្តថា អ្នកកាន់កាប់ដោយប្រយោល តាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅកាន់អ្នកកាន់កាប់ដោយចំពោះ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការផ្ទេរការកាន់កាប់ដោយបញ្ជា។

នៅក្នុងសកម្មភាពអនុវត្តជាក់ស្ដែងអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំនោះ អាចត្រូវបានកាន់កាប់ដោយតតិយជន ដែលត្រូវបានស្ដែងឡើងតាមរូបភាពជា ការជួលអចិន្ត្រៃយ៍ ឬ ការប្រវាស់បើអចលនវត្ថុនោះជាដី[21]ឬក្នុងទម្រង់ជាភតិសន្យា[22]។ ដូច្នេះអ្នកបង្កើតសិទ្ធិលើការបញ្ចាំដែលជាកម្មសិទ្ធិករនៃអចលនវត្ថុ ត្រូវធ្វើការជូនដំណឹងអំពីការដាក់បញ្ចាំអចលនវត្ថុនេះទៅ អ្នកជួល ឬ ភតិកៈនោះឱ្យបានដឹង ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកាន់កាប់ត្រូវបានផ្ទេរទៅម្ចាស់សិទ្ធិលើការបញ្ចាំ។ បុព្វហេតុដូច្នេះ សិទ្ធិអាស្រ័យផលដែលកម្មសិទ្ធិករធ្លាប់ទទួលបានពីវត្ថុអាចជាប្រាក់ថ្លៃឈ្នួលប្រចាំខែនឹងត្រូវបានផ្ទេរទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំតាមរយៈអានុភាពនៃការប្រគល់ដោយបញ្ជាដែលមាននៅក្នុងសិទ្ធិលើការបញ្ចាំអចលនវត្ថុនេះ។

**១.៤. ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់**

ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់ កិច្ចសន្យាបញ្ចាំផ្ដាច់ ជាកិច្ចសន្យាដែលម្ចាស់បំណុល និងកូនបំណុលព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាថា នៅពេលដែលត្រូវកំណត់សង ហើយកូនបំណុលមិនបានសងឬមិនបានបំពេញកាតព្វកិច្ចសងបំណុលនោះទេ អចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាដាក់បញ្ចាំ នឹងត្រូវក្លាយជាទ្រព្យរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ដែលអាចនិយាយជាភាសាសាមញ្ញថា ជាការបញ្ចាំផ្ដាច់។ ជាការពិតណាស់ដោយសង្កេតឃើញថាទាំងក្នុងបរិបទច្បាប់ ភូមិបាលឆ្នាំ១៩៩២ ច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ការបញ្ចាំអចលនវត្ថុផ្ដាច់ត្រូវបានហាមឃាត់ដោយច្បាប់ ដែលម្ចាស់បំណុលឬក៏ម្ចាស់សិទ្ធិលើការបញ្ចាំមិនត្រូវបានឡើងជាកម្មសិទ្ធិករនៃអចលនវត្ថុឡើយ ហើយរាល់ការធ្វើកិច្ចសន្យាឯណាដែលចែងផ្ទុយនឹងបញ្ញត្តិខាងលើនេះ ត្រូវទុកជាមោឃៈ។ តាមមាត្រា៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តថា បើពុំមានបញ្ញត្តិ

[21] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦២២។

[22] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥៩៦។

ពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទេ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ។ តាមខ្លឹមសារនៃមាត្រាខាងលើ យើងមើលឃើញថា ខ្លឹមសារនៃការហាមកិច្ចសន្យាបញ្ចាំផ្ដាច់ ដែលមាននៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មិនមែនជាការកំណត់ដាច់ខាត ជាក់លាក់ថា មិនឱ្យធ្វើកិច្ចសន្យាដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំក្លាយជាកម្មសិទ្ធិករនៃវត្ថុដាក់បញ្ចាំជាដាច់ខាតដូច ច្បាប់ភូមិបាល និង ក្រមរដ្ឋប្បវេណី ចាស់នោះទេ ព្រោះថាក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នេះ បានអនុញ្ញាតឱ្យ ប្រសិនបើមានបញ្ញត្តិពិសេស ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនេះ ឬចែងក្នុងច្បាប់ដោយឡែក អ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចធ្វើការព្រមព្រៀងឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ក្លាយជាកម្មសិទ្ធិករលើវត្ថុដាក់បញ្ចាំនោះបាន ក៏ប៉ុន្តែពុំមានបញ្ញត្តិណាមួយនៅក្នុងក្រម ក៏ដូចជាច្បាប់ណាបញ្ញត្តនៅឡើយ។

### ១.៥. អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ

អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ក៏បានបញ្ញត្តផងដែរអំពីអំឡុងពេលដែលមាន អត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលវត្ថុ គឺមិនអាចលើសពី៥ឆ្នាំបានឡើយ ក៏ប៉ុន្តែអាចបន្តទៀតបាន កុំឱ្យតែលើសពី៥ឆ្នាំ។[23] ជាមួយគ្នានេះដែរបើយើងធ្វើការពិនិត្យលើ សិទ្ធិលើការបញ្ចាំអចលនវត្ថុដែលមានអចិភាពនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ គឺ បានកំណត់មិនឱ្យលើសពី១០ឆ្នាំ ចំណែកឯក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់ត្រឹម៥ឆ្នាំប៉ុណ្ណោះ ហេតុដូចនេះហើយ ប្រាកដជាមានភាពចម្រូងចម្រាស់រវាងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ កាលបើការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនោះ មានរយៈពេល១០ឆ្នាំមុនក្រមរដ្ឋប្បវេណីបានចូលជាធរមាន ជាសំណួរអាចចោទឡើងថា តើអំឡុងពេលអត្ថិភាពនៃសិទ្ធិដែលនៅសល់ក្រោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចូលជាធរមាននឹងត្រូវអនុវត្តយ៉ាងដូចម្ដេច?

ទាក់ទងនឹងចម្ងល់ខាងលើនេះ មាត្រា៥៧ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី បានធ្វើការបកស្រាយ និងដោះស្រាយលើបញ្ហានេះ ដោយកំណត់អំពីអំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុមានអត្ថិភាព ដែលបានបញ្ញត្តថា ចំពោះការបញ្ចាំអចលនវត្ថុដែលត្រូវបានបង្កើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលអំឡុងពេលនៅសល់ ដែលសិទ្ធិលើការបញ្ចាំនោះមានអត្ថិភាព ត្រូវកំណត់ត្រឹម៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ បន្ទាប់ពីបានធ្វើការបកស្រាយអំពីការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុរួចមក

[23] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨៣៨។

ហើយ តើកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនេះ ត្រូវមាននីតិវិធីអនុវត្តយ៉ាងណាខ្លះទៀត? ដូច្នេះកថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ នឹងមានការបញ្ជាក់បន្ថែមលើបញ្ហាមួយនេះ។

**កថាខណ្ឌទី២៖ លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ**

ជាគោលការណ៍ ការបង្កើតកិច្ចសន្យាមានអានុភាពទៅបានដោយសាសំណើ និងស្ទីការត្រូវគ្នានោះកិច្ចសន្យាចាត់ទុកថាបានបង្កើតឡើងហើយ។ ចំពោះការបង្កើតកិច្ចសន្យាបញ្ចាំ នៅក្នុងបទបញ្ញត្តិស្ដីពីសិទ្ធិលើការបញ្ចាំ តាមមាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តអំពីការបង្កើតសិទ្ធិលើការបញ្ចាំ និងការប្រគល់វត្ថុជាចាំបាច់ គ្រាន់តែតម្រូវឱ្យមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំឱ្យទៅម្ចាស់សិទ្ធិលើការបញ្ចាំដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដោយមិនតម្រូវឱ្យមានការធ្វើជាលាយលក្ខណ៍អក្សរ និងចុះបញ្ជីនៅអង្គភាពសុរិយោដីឡើយ។ ប៉ុន្តែការបញ្ញត្តិដូច្នេះ គឺសម្រាប់តែកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុតែប៉ុណ្ណោះ រីឯកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុវិញ ជាលក្ខខណ្ឌតម្រូវគឺត្រូវមានការធ្វើជាលាយលក្ខណ៍អក្សរ និងចុះបញ្ជីនៅអង្គភាពសុរិយោដី បើមិនដូច្នេះទេ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំនោះនឹងមិនអាចមានសុពលភាពក្នុងការអនុវត្តឡើយ។ ជាមួយគ្នានេះដែរ ស្របតាម មាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បញ្ញត្តពីការបញ្ចាំអចលនវត្ថុ បានអនុញ្ញាតឱ្យយកបទបញ្ញត្តិនៃជំពូកទី៥ ស្ដីពីហ៊ីប៉ូតែកត្រូវយកមកអនុវត្តដូចគ្នា។ ដោយយោងតាមមាត្រា ៨៤៥ ស្ដីពីពីហ៊ីប៉ូតែក បានបញ្ញត្តថា ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាហ៊ីប៉ូតែក ដោយលិខិតយថាភូត និង មិនបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ។ ដូចគ្នាដែរចំពោះការបញ្ចាំអចលនវត្ថុ ក៏ត្រូវគោរពតាមលក្ខខណ្ឌតតាំងដែលមានចែងក្នុងមាត្រាខាងលើនេះ គឺលក្ខខណ្ឌនៃការបញ្ចាំអចលនវត្ថុអាចធ្វើការតតាំងចំពោះតតិយជនបានលុះត្រាតែការបង្កើតកិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយលិខិតយថាភូត និង ធ្វើការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីផងដែរ។

តើអ្វីទៅជាលិខិតយថាភូត? និងលិខិតយថាភូតនេះត្រូវធ្វើឡើងយ៉ាងដូចម្ដេច?

យោងតាមសន្ធានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឱ្យនិយមន័យលិខិតយថាភូតថាជា លិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនេះ។ តាមន័យចង្អៀត ជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសាការី។ [24] ស្របគ្នានេះដែរ យោងតាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ ត្រង់មាត្រា៩ចំណុច ខ បាន កំណត់អំពីនិយមន័យលិខិតយថាភូតថា លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៨៤៥ នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី។

---

[24] សាការី ជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់ពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទ តម្កល់រក្សាទុក និងចេញសេចក្តីសម្រេចយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់ យោងតាមសន្ធានុក្រមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

លិខិតយថាភូតអាចក្លាយទៅជាលិខិតអនុវត្ត កាលបើលិខិតនេះត្រូវបានធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានបំណងឱ្យសងជាប្រាក់មានកំណត់ ប៉ុន្តែទាល់តែមានសេចក្តីថ្លែងការណ៍បញ្ជាក់ក្នុងលិខិតអនុវត្តនោះថា កូនបំណុលនឹងទទួលយកការអនុវត្តដោយបង្ខំ។[25] ហេតុនេះហើយ ចំពោះការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត។ ដូច្នេះ ដោយសារតែ កិច្ចសន្យាដាក់បញ្ចាំ ជាកិច្ចសន្យាមួយដែលចំណុះឱ្យកិច្ចសន្យាខ្ចីដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយនៅក្នុងប្រការណាមួយនៃកិច្ចសន្យាបានចែងអំពីការធានានូវអចលនវត្ថុនោះ ឬ កិច្ចសន្យានោះអាចក្លាយទៅជាលិខិតអនុវត្តបាន ដោយត្រូវបំពេញនូវលក្ខខណ្ឌមួយទៀត គឺធ្វើឡើងដោយសារការី។[26] ប្រសិនបើ លិខិតនោះមិនបានធ្វើឡើងដោយសារការីមិនអាចក្លាយទៅជាលិខិតអនុវត្តបានទេ ទោះបីជាកិច្ចសន្យានោះធ្វើនៅសុរិយោដីក៏ដោយ។

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីសិទ្ធិលើការបញ្ចាំអចលនវត្ថុ**

ការចុះបញ្ជីគ្រាន់តែជាលក្ខខណ្ឌតតាំងជាមួយតតិយជនតែប៉ុណ្ណោះ ចំពោះការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ។ [27] នៅក្នុងការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ត្រូវបញ្ជាក់អំពីស្ថានភាពនៃអចលនវត្ថុ ឬ ស្ថានភាពនៃទ្រព្យនោះ និងបន្ទុកផ្សេងៗ ព្រមទាំងតម្លៃនៃអចលនវត្ថុនោះដែរ តួយ៉ាងការចុះបញ្ជីក៏ត្រូវបង្ហាញឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់កូនបំណុល សិទ្ធិនិងកាតព្វកិច្ចរបស់ភាគី ការកំណត់រយៈពេលនៃកិច្ចសន្យាជាអាទិ៍។ មួយវិញទៀតនៅក្នុងការចុះបញ្ជីកត្តាដែលសំខាន់មួយទៀត គឺត្រូវកំណត់ឱ្យបានច្បាស់អំពីទឹកប្រាក់ដែលជាសិទ្ធិលើបំណុលត្រូវទទួលបាន ពីការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ និងត្រូវតែកំណត់ឱ្យបានច្បាស់ផងដែរ នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការចុះបញ្ជីនោះដើម្បីធានានូវកាតព្វកិច្ច។

ស្របតាមការបកស្រាយខាងលើនេះ មានមតិមួយចំនួនបានលើកឡើងថា តើហេតុអ្វីចាំបាច់ត្រូវយកអចលនវត្ថុទៅចុះបញ្ជី?

ជាការឆ្លើយតបទៅនឹងមតិខាងលើនេះ គឺថា ការចុះបញ្ជី គឺជាលក្ខខណ្ឌដ៏ពិសេសនៅក្នុងការជូនដំណឹងដល់សាធារណៈជនឱ្យបានដឹងឮ ព្រោះថានៅពេលដែលអចលនវត្ថុមួយត្រូវបានដាក់បញ្ចាំ ម្ចាស់បំណុលនឹងទទួលបានការសងបំណុលរបស់ខ្លួន ពីទ្រព្យនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត និងអាចតតាំងចំពោះតតិយជនដែលជាជនក្រៅពីគូភាគីនៃកិច្ចសន្យា ឱ្យបានដឹងអំពីសិទ្ធិលើការបញ្ចាំអចលនវត្ថុនោះ។ លើសពីនេះទៅទៀតគឺដើម្បីទទួលបានសំណងជាអាទិភាពជាងម្ចាស់បំណុលដទៃ។ ការចុះបញ្ជី គឺបញ្ជាក់អំពីលំដាប់សិទ្ធិលើបំណុល ដែលមានប្រយោជន៍យ៉ាងខ្លាំងចំពោះការបែងចែកនូវចំណែក ដោយការលក់ដោយបង្ខំតាមរយៈអំណាចតុលាការអនុវត្ត ដូច្នេះហើយទើបការចុះបញ្ជីមានផលប្រយោជន៍ច្រើនដល់ម្ចាស់សិទ្ធិលើការ

[25]ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៥០។

[26] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៤៩៦។

[27] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨៤៥។

បញ្ចាំអចលនវត្ថុដែលជាម្ចាស់បំណុលរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ។ អាស្រ័យហេតុនេះ តើការចុះបញ្ជីអំពីសិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវមាននីតិវិធីក៏ដូចជាការអនុវត្តយ៉ាងដូចម្តេចខ្លះ?

ការចុះបញ្ជីអំពីសិទ្ធិលើការបញ្ចាំអចលនវត្ថុនេះ គឺធ្វើឡើងតាមពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ហើយចំពោះស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុ គឺមានតែរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុនោះតាំងនៅ។[28] ហើយចំពោះការទទួលពាក្យសុំចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុនោះតាំងនៅ គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការប្រតិបត្តិ។ មួយវិញទៀតពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរហើយត្រូវសរសេរនូវអ្វីដែលខ្លួនចង់ចុះបញ្ជីឲ្យបានច្បាស់លាស់ ដើម្បីជាភាពងាយស្រួលដល់ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជី ព្រោះរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី នឹងចុះបញ្ជីទៅតាមចំណុចដែលមានចែងក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ។[29] ចំពោះពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំត្រូវធ្វើឡើងតាមទម្រង់នៃពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ [30] និង ត្រូវសរសេរចំណុចបន្ថែមដូចជា[31]៖

- គោលបំណងក្នុងការបង្កើតសិទ្ធិលើការបញ្ចាំ
- មូលហេតុ និងកាលបរិច្ឆេទនៃកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ
- បុគ្គលមានសិទ្ធិចុះបញ្ជី
- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី( ឈ្មោះកូនបំណុល អំឡុងពេលដែលមានអត្ថិភាព ចំនួនប្រាក់ដើមប្រាក់ធានាសង ការសន្យាពិសេស លក្ខខណ្ឌភ្ជាប់នឹងសិទ្ធិលើបំណុលដែលត្រូវបានធានា) និង
- អត្តសញ្ញាណនៃអចលនវត្ថុ( ទីតាំង លេខក្បាលដី ឬ លេខប័ណ្ណ)

[28] ប្រកាស, លេខ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រកក្យក្សទាក់ទងក្រមរដ្ឋប្បវេណី, ប្រការ ៥ ចំណុច១។

[29] ប្រកាស, លេខ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រកក្យក្សទាក់ទងក្រមរដ្ឋប្បវេណី, ប្រការ៦។

[30] ប្រកាស, លេខ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រកក្យក្សទាក់ទងក្រមរដ្ឋប្បវេណី, ប្រការ២៦។

[31] ប្រកាស, លេខ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រកក្យក្សទាក់ទងក្រមរដ្ឋប្បវេណី, ប្រការ៥១។

ចំពោះការដាក់ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលដែលដាក់ពាក្យចុះបញ្ជី ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនដូចខាងក្រោម ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ[32]៖

- ឯកសារដែលបញ្ជាក់ អំពីអត្តសញ្ញាណរបស់បុគ្គល ដែលដាក់ពាក្យសុំចុះបញ្ជី
- លិខិតបញ្ជាក់សិទ្ធិតំណាងរបស់អភិបាលតំណាងនីតិបុគ្គល ប្រសិនបើអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល
- ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីនោះ ជាជនដែលស្ថិតនៅក្រោមអ្នកដំណាង ដែលកំណត់ដោយច្បាប់
- លិខិតប្រគល់សិទ្ធិដំណាង ក្នុងករណីដែលពាក្យសុំធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ
- ឯកសារបញ្ជាក់ពីមូលហេតុ នៃការចុះបញ្ជី
- ឯកសារបញ្ជាក់ពីមូលហេតុ នៃឧបាទេសកម្ម ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- សាលក្រម ឬ សាលដីកាជាស្ថាពរ ជាអាទិ៍ ក្នុងករណីដែលពាក្យសុំចុះបញ្ជី ត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ ជាអាទិ៍
- ឯកសារបញ្ជាក់ពីការយល់ព្រមរបស់តតិយជន ក្នុងករណីពាក់ព័ន្ធផលប្រយោជន៍តតិយជននោះ
- ឯកសារបញ្ជាក់អំពីសន្តតិកម្ម ឬ ការរួមបញ្ចូលគ្នានៃនីតិបុគ្គល ក្នុងករណីពាក្យសុំចុះបញ្ជី ដែលមានចែងក្នុងកថាខណ្ឌទី២ប្រការ១០និងប្រការ១១នៃប្រកាសនេះ
- គំនូសបង្ហាញសេវភាព
- គំនូសបង្ហាញទីតាំងអាគារ ដែលជាកម្មវត្ថុនៃផលុបភោគ
- ប័ណ្ណ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់។

## ផ្នែកទី២៖ ការអនុវត្តសិទ្ធិលើការបញ្ចាំអចលនវត្ថុ

នៅពេលដែលបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ តាមរយៈការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុដែលត្រឹមត្រូវតាមគតិច្បាប់ហើយ កិច្ចសន្យាបញ្ចាំអចលនវត្ថុនោះ និងមានអានុភាពអនុវត្តបានទៅលើម្ចាស់បំណុលដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ និង កូនបំណុលដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។ យោងតាមចំណងកិច្ចសន្យានេះ ដែលជាបុព្វហេតុធ្វើឱ្យម្ចាស់សិទ្ធិលើការបញ្ចាំមាននូវសិទ្ធិ និង ករណីកិច្ចមួយចំនួន ដែលបានកំណត់នៅក្នុងច្បាប់ ស្តីពីការបញ្ចាំអចលនវត្ថុដែលមាននៅក្នុងបរិបទក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[32]ប្រកាសអន្តរក្រសួង, លេខ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រកក្យក្បទាក់ទងក្រមរដ្ឋប្បវេណី, ប្រការ២៧។

ដែលនឹងរំលេចឱ្យឃើញនូវ សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ។ ដូច្នេះនៅក្នុងផ្នែកនេះយើងនឹងសិក្សាអំពី សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី១) សិទ្ធិនិងករណីយកិច្ចរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី២) និងការបញ្ចាំបន្ត(កថាខណ្ឌទី៣)។

**កថាខណ្ឌទី១៖ សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ**

ក្នុងនាមជាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុដែលបានកាន់កាប់ និងគ្រប់គ្រង កម្មវត្ថុនៃការដាក់បញ្ចាំដូច្នេះសិទ្ធិនិងករណីយកិច្ចមួយចំនួនត្រូវបានកំណត់ក្នុងច្បាប់យ៉ាងជាក់លាក់។ ដូចដែលបានបង្ហាញខាងលើរួចមកហើយ ដោយសារតែចំណងគតិយុត្តនៃកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ បានរំលេចឱ្យឃើញនូវសិទ្ធិចម្បងចំនួនបីដែលម្ចាស់សិទ្ធិលើការបញ្ចាំទទួលបាន គឺ សិទ្ធិប្រើប្រាស់ និងអាស្រ័យផល និងសិទ្ធិលើបំណុលដែលមានអាទិភាព។

ជាសំណួរសួរថាតើអ្វីទៅជាសិទ្ធិប្រើប្រាស់របស់ម្ចាស់សិទ្ធិលើការបញ្ចាំ? សិទ្ធិប្រើប្រាស់ជាសិទ្ធិមួយដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចប្រើប្រាស់នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំអចលនវត្ថុនោះ។ តាមស្មារតីនៃច្បាប់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបង្ហាញអំពីសិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំដែលម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ។ ជាឧទាហរណ៍ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកដីស្រែដែលកូនបំណុលបានយកមកដាក់បញ្ចាំទៅធ្វើកសិកម្ម នោះម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ដីកសិកម្មនោះក្នុងរយៈពេល១ឆ្នាំ ក្នុងករណីដើម្បីប្រមូលផលដំណាំទោះបីជាសិទ្ធិលើបំណុលត្រូវបានរលត់ក៏ដោយ។ ប៉ុន្តែបើកាប្រមូលផលនឹងយូរជា១ឆ្នាំ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវតែប្រញាប់ប្រមូលផលឱ្យបានមុនផុតអំឡុងពេល១ឆ្នាំ។ ក្រៅពីសិទ្ធិប្រើប្រាស់ និងអាស្រ័យផល ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិមួយទៀតគឺសិទ្ធិលើបំណុលដែលមានអត្តិភាព។

សិទ្ធិលើបំណុលដែលមានអាទិភាព សំដៅទៅលើសិទ្ធិលើបំណុលដែលខ្លួនទទួលបានមុនគេ។ យោងតាមច្បាប់ភូមិបាល ឆ្នាំ២០០១ បានចែងពីសិទ្ធិលើបំណុលដែលមានអាទិភាពនេះផងដែរ ត្រង់មាត្រា២១១ដែលបញ្ញត្តថា កិច្ចសន្យាដាក់បញ្ចាំអចលនវត្ថុផ្តល់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំនូវសិទ្ធិប្តឹងទៅតុលាការឱ្យដាក់លក់នូវអចលនវត្ថុដោយបង្ខំ ដើម្បីសងខ្លួនជាអាទិភាពដោយបុរិមានិងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត។ អាស្រ័យហេតុនេះហើយម្ចាស់សិទ្ធិលើការបញ្ចាំដែលទទួលបានការដាក់បញ្ចាំ នៅពេលដែលកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ច នោះម្ចាស់សិទ្ធិលើការបញ្ចាំនឹងប្រើប្រាស់នូវសិទ្ធិនេះ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺការអនុវត្តនឹងមានអាទិភាពសងមុនគេតាមរយៈការប្តឹងទៅតុលាការ ដើម្បីធ្វើការលក់អចលនវត្ថុនោះតែប៉ុណ្ណោះដោយមិនអនុញ្ញាតឱ្យមានការព្រមព្រៀងគ្នាហើយមានការផ្ទេរឬលក់ដោយមិនឆ្លងកាត់តុលាការនោះទេ។ ទាំង

ពីរចំណុចខាងលើនេះជាសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ បន្ទាប់ពីនេះយើងនឹងសិក្សាអំពីករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ។

ករណីយកិច្ចដែលម្ចាស់សិទ្ធិលើការបញ្ចាំត្រូវមាននោះគឺ ករណីយកិច្ចថែរក្សា និងគ្រប់គ្រងវត្ថុនៃការបញ្ចាំ។ ដោយសាការបញ្ចាំម្ចាស់សិទ្ធិលើការបញ្ចាំត្រូវមាសិទ្ធិកាន់កាប់វត្ថុនោះ ជៀសមិនផុតម្ចាស់សិទ្ធិលើការបញ្ចាំត្រូវមានករណីយកិច្ចថែរក្សានិងគ្រប់គ្រងវត្ថុនៃការបញ្ចាំ។ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំមិនបានជួយថែរក្សាការពារ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរដោយអចលនវត្ថុនៃការបញ្ចាំនោះ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល) អាចសុំលុបសិទ្ធិលើការបញ្ចាំនោះបាន ដូច្នេះម្ចាស់បំណុលត្រូវតែថែរក្សានិងគ្រប់គ្រងវត្ថុនៃការបញ្ចាំឱ្យបានល្អក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។ ចំពោះករណីយកិច្ចមួយទៀតនោះគឺករណីយកិច្ចប្រគល់វត្ថុនៃការបញ្ចាំទៅកូនបំណុលនៅពេលដែលកូនបំណុលបានសងរួចរាល់ហើយ មានន័យថានៅពេលដែលកូនបំណុលបានយកប្រាក់មកសងបំណុលដើម្បីទទួលយកអចលនវត្ថុនោះវិញហើយម្ចាស់សិទ្ធិលើការបញ្ចាំមាករណីយកិច្ចផ្តល់សិទ្ធិក្នុងការកាន់កាប់វត្ថុនោះទៅកូនបំណុលវិញ។

**កថាខណ្ឌទី២៖ សិទ្ធិនិងករណីយកិច្ចរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ**

ជាមួយគ្នានេះដែរ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ក៏មាននូវសិទ្ធិ និងករណីយកិច្ចមួយចំនួននៅក្នុងចំណងកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុដែលត្រូវអនុវត្តជាមួយម្ចាស់សិទ្ធិលើការបញ្ចាំផងដែរ។ ចំពោះសិទ្ធិរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំមានចំនួនពីរសំខាន់ៗគឺ សិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារវត្ថុបញ្ចាំក្រោយពេលបំពេញកាតព្វកិច្ចរួច។

ការបង្កើតកិច្ចសន្យា មិនមែនជារឿងសាមញ្ញហើយងាយស្រួលទេ គឺត្រូវមានលក្ខខណ្ឌ និង កម្មវត្ថុច្បាស់លាស់ដែលច្បាប់បានតម្រូវចំណែកឯការសុំរំលាយកិច្ចសន្យាក៏រឹតតែពិបាកថែមទៀត លុះត្រាតែមានកំណត់នៅក្នុងច្បាប់ជាក់លាក់ផងដែរ គឺមានន័យថាជាការដែលរកឃើញថាមានវិការៈរបស់ភាគី។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ រាល់កំហុសទាំងអស់មិនសុទ្ធតែជាមូលហេតុដែលត្រូវរំលាយកិច្ចសន្យានោះទេ ទាល់តែមានកំណត់ក្នុងច្បាប់ជាធរមាន។ កំហុសទាំងអស់នោះមានដូចជា ការកាន់កាប់ដោយខ្វះការប្រុងប្រយ័ត្ន ការប្រើប្រាស់ខុសកម្មវត្ថុ។ ចំពោះកាន់កាប់ដោយខ្វះការប្រុងប្រយ័ត្ន គឺមានដូចជាការប្រើប្រាស់ណាដែលនាំឱ្យខូចខាតអចលនវត្ថុរបស់កូនបំណុល ឬការប្រើប្រាស់ដែលមានបំណងឱ្យកូនបំណងខូចខាតផលប្រយោជន៍។ រីឯការប្រើប្រាស់ខុសកម្មវត្ថុ មានន័យថាការប្រើប្រាស់ដែលខុសពីបំណងដែលមានក្នុងកិច្ចសន្យា ឧទាហរណ៍ ក្នុងកិច្ចសន្យាព្រមព្រៀងថានឹងយកដីកូនបំណុលទៅដាំដុះដែលវាជាសិទ្ធិប្រើប្រាស់និងអាស្រ័យផល ប៉ុន្តែបែរជាម្ចាស់បំណុលមិនត្រឹមតែប្រើប្រាស់និងអាស្រ័យផលនោះទេ ថែមទាំងប្រើប្រាស់សិទ្ធិចាត់ចែងលើដីនោះថែមទៀតដូចជាជីកអណ្តូង ឬ ជីកស្រះលើដីនោះ ដែលវាមិនមែនជាសិទ្ធិប្រើប្រាស់និងអាស្រ័យផលដូចក្នុងកិច្ចសន្យា។ ហេតុផល

ទាំងនេះហើយដែលកូនបំណុលអាចមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាបាន។ មួយទៀតនោះគឺនៅពេលដែលកូនបំណុលបានបំពេញកាតព្វកិច្ចរួចហើយកូនបំណុលអាចទាមទារវត្ថុបញ្ចាំពី ម្ចាស់បំណុលមកវិញបាន។

អ្វីដែលយើងបានរៀបរាប់ខាងលើនោះគឺសិទ្ធិរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំឬសិទ្ធិរបស់កូនបំណុល ដូច្នេះតើកូនបំណុលក្រៅពីសិទ្ធិ និងមានករណីយកិច្ចអ្វីខ្លះ?

ជាទូទៅក្នុងនាមជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ក៏ត្រូវមានករណីយកិច្ចផងដែរ ដែលមានដូចជាករណីយកិច្ចប្រគល់វត្ថុដាក់បញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ និង បង់ពន្ធលើវត្ថុដាក់បញ្ចាំ។ ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ គឺជាលក្ខខណ្ឌដែលចាំបាច់ក្នុង ការបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ។ ដូចនេះ ការប្រគល់វត្ថុដាក់បញ្ចាំគឺជា លក្ខខណ្ឌដែលច្បាប់តម្រូវ។ អាស្រ័យហេតុនេះហើយ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ត្រូវតែប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាដាក់បញ្ចាំអចលនវត្ថុទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ក្រៅពីករណីយកិច្ចប្រគល់វត្ថុដាក់បញ្ចាំឱ្យទៅម្ចាស់សិទ្ធិលើការបញ្ចាំនៅមានកណីកិច្ចមួយទៀតដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំត្រូវបំពេញនោះគឺ ករណីយកិច្ចបង់ពន្ធលើអចលនវត្ថុ។ តាមមាត្រា ៨៣៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ អំពីសោហ៊ុយ និងបន្ទុកផ្សេងទៀតដែលកើតឡើងជាបន្ទុករបស់ម្ចាស់សិទ្ធិលើការបញ្ចាំក៏ប៉ុន្តែខ្លឹមសារនៃមាត្រានេះមិនមែនមានន័យថាម្ចាស់សិទ្ធិលើការបញ្ចាំត្រូវតែបង់ពន្ធលើអចលវត្ថុជូនរដ្ឋនោះទេ ដោយជាគោលការណ៍អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ជាអ្នកទទួលខុសត្រូវលើការបង់ពន្ធលើអចលនវត្ថុនោះ ក៏ប៉ុន្តែ ច្បាប់ក៏ចាត់ទុកលទ្ធភាពឱ្យគូភាគីអាចធ្វើការព្រមព្រៀងពិសេសបាន ដោយអនុលោមតាមមាត្រា ៨៣៧ ស្តីពីអានុភាពនៃការសន្យាពិសេស មានន័យថា ច្បាប់បានបញ្ញត្តទទួលស្គាល់ ការបង្ហាញឆន្ទៈរបស់គូភាគីតាមរយៈការបង្កើតកិច្ចសន្យាពិសេសចំពោះចំណុចនេះ។ ការបង់ពន្ធលើអចលនទ្រព្យ ក៏ដូចជាមូលដ្ឋានសម្រាប់គិតពន្ធលើអចលនទ្រព្យ ត្រូវធ្វើការបែងចែកទៅតាមទីតាំងភូមិសាស្ត្រដែលតម្លៃមានការប្រែប្រួលដូចជា នៅរាជធានីភ្នំពេញ និង តាមបណ្តាខេត្តផ្សេងទៀត។

**កថាខណ្ឌទី៣៖ ការបញ្ចាំបន្ត**

ជាធម្មតាតម្រូវការរបស់មនុស្សតែងតែមាន តែងតែត្រូវការដោយខានពុំបាន ដោយសាការខ្វះខាតវិស័យសេដ្ឋកិច្ចសម្រាប់ជីវភាពរស់នៅ។ ជុំវិញបញ្ហានេះគួរឱ្យកត់សម្គាល់ត្រង់ថានៅពេលដែលម្ចាស់សិទ្ធិលើការបញ្ចាំខ្វះខាតថវិកា ម្ចាស់សិទ្ធិលើការបញ្ចាំ(ម្ចាស់បំណុល)អាចដាក់បញ្ចាំអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះបន្តទៅជនដទៃទៀតបាន។ ការបញ្ចាំបន្តនេះអាចធ្វើបានតាមពីររូបភាពគឺ ការបញ្ចាំបន្តដោយមានការជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល) និងការបញ្ចាំបន្តដែលមានការទទួលខុសត្រូវ។ ការបញ្ចាំបន្តដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនេះមានបញ្ញត្តផងដែរនៅក្នុងមាត្រា៨២៦ កថាខណ្ឌទី១និងទី២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយការការដាក់បញ្ចាំបន្តអាចធ្វើទៅបានគឺត្រូវមានការយល់ព្រមពីអ្នក

បង្កើតសិទ្ធិលើការបញ្ចាំជាមុនសិន។ ស្របពេលជាមួយគ្នានេះដែរ បើសិនជាការដាក់បញ្ចាំបន្តមិនបានជូនដំណឹងទៅអ្នកបង្កើតសិទ្ធិលើការបញ្ចាំជាមុនទេតើការបញ្ចាំបន្តនេះអាចធ្វើបានដែរឬទេ? ជាចម្លើយនោះគឺ អាចធ្វើបាន ប៉ុន្តែការបញ្ចាំបន្តដោយមិនមានការជូនដំណឹងដល់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ នោះទេ ប្រសិនបើក្នុងករណីមានបញ្ហាដោយប្រការណាមួយនោះ ម្ចាស់សិទ្ធិលើការបញ្ចាំដែលបានបញ្ចាំបន្តនឹងមានការទទួលខុសត្រូវនិងរាប់រងរាល់ការខូចខាតដែលបានកើតឡើងដោយសាតែខ្លួនបានធ្វើការបញ្ចាំបន្តនូវអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដើមនោះ នៅក្នុងករណីបែបនេះនៅជាភាសាគតិយុត្តឱ្យហៅថា ការបញ្ចាំបន្តដែលមានការទទួលខុសត្រូវ។[33]

## ផ្នែកទី៣ ការបញ្ចប់សិទ្ធិលើការបញ្ចាំអចលនវត្ថុ

នៅក្នុងកិច្ចសន្យាដែលបានង្កើតឡើងដោយគូភាគីសម្រាប់អនុវត្ត ដើម្បីបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក គូភាគីនៃកិច្ចសន្យាបានអនុវត្តច្បាប់ចប់សព្វគ្រប់ដោយរលូននោះកិច្ចសន្យានឹងត្រូវបានរលត់កាតព្វកិច្ចទៅតាមកាលកំណត់ណាមួយដែលខ្លួនបានធ្វើការព្រមព្រៀងគ្នា។ ក្នុងន័យនេះសំដៅទៅលើ ប្រតិបត្តិការទាំងឡាយណាដែលមាននៅក្នុងកិច្ចសន្យានោះត្រូវបានបុគ្គលដែលពាក់ព័ន្ធបានអនុវត្តចប់សព្វគ្រប់ តាមរយៈការប្រគល់វត្ថុ ឬការប្រគល់ប្រាក់ ឬ ធ្វើនូវសកម្មភាពដូចដែលបានចែងក្នុងកិច្ចសន្យានោះ។ កូនបំណុលត្រូវអនុវត្តកាតព្វកិច្ច របស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់។[34] ក្នុងករណីនេះ ដើម្បីឱ្យការបញ្ចប់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានអានុភាពទៅបានមានពីរករណីដែលក្នុងនោះករណីទីមួយគឺ វាជាសិទ្ធិរបស់កូនបំណុលដែលត្រូវបានអនុវត្តកាតព្វកិច្ចទៅតាមខ្លឹមសារនៃកិច្ចសន្យានោះ និងករណីទីពីរ ប្រសិនបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យានោះទេ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច អនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ឬការអនុវត្តដោយបង្ខំ។ ដើម្បីឱ្យកាន់តែជ្រាបច្បាស់ ខាងក្រោមនេះយើងនឹងធ្វើការបងស្រាយនិងពន្យល់បន្ថែម ទៅលើការដែលគូភាគីអាចអនុវត្តបាន មានចំនួនពីររបៀប គឺ ការសងបំណុល និងការលុបការចុះបញ្ជីសិទ្ធិលើការបញ្ចាំ(កថាខណ្ឌទី១) និង ការអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ(កថាខណ្ឌទី២ )។

### កថាខណ្ឌទី១៖ ការសងបំណុល និងការលុបការចុះបញ្ជីសិទ្ធិលើការបញ្ចាំ

បើនិយាយអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាគតិទូទៅនឹងអាចនឹកដល់ការផ្សះផ្សា ឬការព្រមព្រៀងគ្នាដើម្បីដោះស្រាយវិវាទអ្វីមួយ ដែលអាចមានជាការទាមទារសំណង ការផ្តល់តាវកាលិកដើម្បីបញ្ចប់វិវាទ និងការសងសំណងជាសាច់ប្រាក់។ នៅត្រង់នេះយើងនឹងសិក្សាអំពីការសងជាសាច់ប្រាក់ដែលកូន

[33] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី" ភាគ៤, មាត្រា ៨២៦កថាខណ្ឌទី២។

[34] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៨៤ កថាខណ្ឌទី១។

បំណុល (អ្នកបង្កើតសិទ្ធិលើការបញ្ចាំ) បានបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុជាមួយម្ចាស់បំណុល(ម្ចាស់សិទ្ធិលើការបញ្ចាំ) ហើយជាកាតព្វកិច្ចកូនបំណុលត្រូវធ្វើការសងប្រាក់ទៅកាន់ម្ចាស់បំណុលវិញ។

ជាធម្មតានៅពេលដែលមានការខ្ចីគឺត្រូវមានការសងត្រឡប់មកវិញ ដែលវាអាចជាសាច់ប្រាក់ ឬជាវត្ថុប្រើប្រាស់ដែលអាចប្តូរជាប្រាក់បាន។ ការសង គឺសំដៅទៅលើការឱ្យតម្លៃដែលទិញ ឬដែលខ្ចីគេយកមក ឬចេញថ្លៃឱ្យគេជំនួស រួមទាំងការសងប្រាក់ ឬការសងជម្ងឺចិត្តជាដើម។ បើយោងទៅតាមកិច្ចសន្យា ភាគីម្ខាង ឬភាគីទាំងសងខាងត្រូវទទួលបន្ទុកចំពោះកាតព្វកិច្ច ហើយភាគីដែលទទួលបន្ទុកចំពោះកាតព្វកិច្ច ត្រូវអនុវត្តកាតព្វកិច្ចនោះទៅតាមខ្លឹមសារនៃកិច្ចសន្យានោះ។ មានន័យថាកិច្ចសន្យាដែលមានចែងពីកាតព្វកិច្ចរបស់គូភាគីណាមួយ ភាគីនោះត្រូវធ្វើការអនុវត្តកាតព្វកិច្ចទៅតាមខ្លឹមសារនៃកិច្ចសន្យានោះ។ ការសងអាចធ្វើឡើងដោយកូនបំណុល ឬតតិយជនក៏បានដោយមានការយល់ព្រមពីម្ចាស់បំណុល ហើយម្ចាស់បំណុល និងកូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន។[35] ការសងដោយកូនបំណុល ជាការសងដែលមានអានុភាពផ្នែកច្បាប់ព្រោះថាកូនបំណុលទទួលកាតព្វកិច្ចក្នុងការសង។ ក្នុងករណីដែលកម្មវត្ថុយកមកសងនោះមិនមែនជាកម្មសិទ្ធិរបស់អ្នកសង ឬអ្នកសងនោះគ្មានសមត្ថភាពដើម្បីចាត់ចែងលើកម្មវត្ថុដែលត្រូវសងនោះទេ ឬដោយសាការកម្រិតសមត្ថភាព នាំឱ្យមានការសងនោះគ្មានសុពលភាព។[36] ក្នុងករណីនេះ ទោះបីជាការសងដែលធ្វើឡើងដោយអនីតិជនដែលមានសិទ្ធិចាត់ចែងលើកម្មវត្ថុនៃការសងនោះក៏ដោយ សកម្មភាពនោះអាចត្រូវលុបចោលដោយសាមូលហេតុនៃការកម្រិតសមត្ថភាព។

មកដល់ត្រង់នេះយើងក៏អាចនិយាយពីវិធីសងផងដែរ ការសងគឺកូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និងតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។[37] ការសងនេះមានន័យថា កូនបំណុលត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលមានចែងក្នុងខ្លឹមសារនៃកិច្ចសន្យា ដូចជាគោលបំណងនៃកិច្ចសន្យាដែលបានព្រមព្រៀងគ្នាជាមួយនឹងម្ចាស់បំណុល ហើយការសងនេះត្រូវតែគោរពតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ មានន័យថាកូនបំណុលត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដោយមិនត្រូវធ្វើឱ្យមានការរំខាន ឬបង្កការលំបាកដល់ម្ចាស់បំណុលដោយសាតែការសងរបស់ខ្លួននោះទេ។ ជាទូទៅកូនបំណុលមានកាតព្វកិច្ចត្រូវសងទៅម្ចាស់បំណុលឱ្យបានអស់ពីសមត្ថភាពដែលអាចធ្វើបាន។ ប៉ុន្តែក៏អាចមើលទៅលើជីវភាពរស់នៅជាប្រចាំរបស់កូនបំណុលដែរ ដែលពេលខ្លះកូនបំណុលមិនអាចអនុវត្តបានទាំងមូលបានភ្លាមៗទេ ពោលគឺកូនបំណុលអាចបំពេញកាតព្វកិច្ចបានមួយផ្នែក ឬធ្វើការសងមួយភាគសិនតែប៉ុណ្ណោះ។ ក្នុងករណីនេះ

[35] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៣៤។
[36] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៣៥។
[37] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤០។

ម្ចាស់បំណុលមិនមានករណីយកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ [38] មានន័យថាម្ចាស់បំណុលមានសិទ្ធិក្នុងការបដិសេធមិនទទួលការសងមួយភាគរបស់កូនបំណុល ហើយចាត់ទុកថា ការសងនោះមិនមានសុពលភាពដោយហេតុថាចំនួនដែលកូនបំណុលស្នើផ្តល់ការសងមិនគ្រប់តាមចំនួនដែលត្រូវសង។ ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលបានទទួល ដោយដឹងថាជាការសងមួយភាគ ការសងនោះមានសុពលភាពត្រឹមទំហំដែលបានសង។[39] ប៉ុន្តែបើមានការសន្យាពិសេសអំពីការសងបន្តិចម្តងៗ ការសងមួយភាគអាចធ្វើទៅបាន។ ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់បំណុលទទួលការសងមួយភាគ ការសងនោះមានសុពលភាព ហើយកាតព្វកិច្ចត្រូវកាត់បន្ថយនៅត្រឹមតុល្យភាពនៃចំនួនសរុប។[40]

ចំពោះពេលវេលានិងទីន្លែងនៃការសង ជាជម្រើសរបស់កូនបំណុលនិងម្ចាស់បំណុលក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលក្នុងនោះកូនបំណុលត្រូវសងទៅឱ្យម្ចាស់បំណុលនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលពេលកំណត់ទាំងនោះមានដូចខាងក្រោម៖[41]

- នៅពេលដល់កំណត់នៃពេលដែលត្រូវបានកំណត់ពិតប្រាកដសម្រាប់ការអនុវត្តកាតព្វកិច្ច
- នៅពេលកូនបំណុលដឹងថាដល់ពេលកំណត់ត្រូវសងហើយ ក្នុងករណីដែលការកំណត់ពេលមិនពិតប្រាកដសម្រាប់ការអនុវត្តកាតព្វកិច្ច
- នៅពេលកូនបំណុលទទួលការទាមទារឱ្យអនុវត្តកាតព្វកិច្ច ក្នុងករណីដែលមិនបានកំណត់ពេលសម្រាប់ការអនុវត្តកាតព្វកិច្ចនោះ។[42]

លើសពីនេះទៅទៀត កូនបំណុលក៏អាចសងមុនពេលកំណត់បានដែរ [43] បើការសងនោះពុំធ្វើឱ្យប៉ះពាល់ឬនាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវណាមួយទៅដល់ម្ចាស់បំណុល។ ដោយសាពេលកំណត់នៃការសងគឺវាជាផលប្រយោជន៍នៃកូនបំណុល[44] ដូច្នេះប្រសិនបើការសងមុនពេលកំណត់នាំឱ្យមានការខូចខាតដល់ម្ចាស់បំណុល ការសងនេះមិនអាចធ្វើបានទេ ពោលគឺម្ចាស់បំណុលអាចធ្វើការបដិសេធចំពោះការសងមុនពេលកំណត់បាន។

[38] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤១។
[39] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤១។
[40] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី" ភាគ២, ទំព័រ ១៦៤-១៦៥។
[41] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤៣។
[42] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩១។
[43] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤៣ កថាខណ្ឌទី២។
[44] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៣០។

ដោយឡែកចំពោះទីកន្លែងនៃការសងវិញ ប្រសិនបើមានការព្រមព្រៀងពិសេសរវាងម្ចាស់បំណុល និងកូនបំណុលអំពីទីកន្លែងដែលត្រូវសង ការសងនោះត្រូវអនុវត្តតាមការព្រមព្រៀងនោះ។ [45] ប៉ុន្តែបើសិនជាគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើងនៅទីកន្លែងនោះស្ថិតនៅ នាពេលសិទ្ធិលើបំណុលកើតឡើង។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។[46] ក្រៅពីទីកន្លែងនៃការសង និងម៉ោងនៃការសងក៏ត្រូវបានគិតគូរផងដែរ ដោយកូនបំណុលត្រូវសងនៅក្នុងម៉ោងធម្មតា តាមទំនៀមទម្លាប់ និងគោលការណ៍ភាពសុចរិត និងភាពត្រឹមត្រូវ។ [47] ដោយសានៅតំបន់ខ្លះមានការកំណត់សងដោយធ្វើទៅតាមទំនៀមទម្លាប់ ដូចជាកាកំណត់សងនៅចន្លោះពេលថ្ងៃលិចនិងថ្ងៃរះជាដើម ដែលទង្វើនេះត្រូវបានបុគ្គលជាច្រើននៅតំបង់នោះអនុវត្ត។ រីឯតំបន់ដែលមិនមានទំនានទម្លាប់ទាក់ទងនឹងម៉ោងនៃការសងនេះទេ ជាទូទៅគេធ្វើឡើងនៅក្នុងម៉ោងធ្វើការដើម្បីបង្កភាពងាយស្រួលដល់គូភាគីទាំងសងខាងក្នុងការណាត់ជួបគ្នានៅកន្លែងធ្វើការជាដើម។ ជាក់ស្តែងនៅហាងបញ្ចាំនីមួយៗតែងតែមានការបិទផ្សាយនូវថ្ងៃធ្វើការ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វាចេញចូលនៃទីកន្លែធ្វើអាជីវកម្មនោះ។[48]

ដូច្នេះនៅពេលដែលម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ បានទទួលការសងពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុដែលជាកូនបំណុលរបស់ខ្លួនរួចរាល់ហើយ នោះក៏ជាពេលដែលត្រូវលុបការចុះបញ្ជីចារបន្ទុកអំពីសិទ្ធិលើការបញ្ចាំលើអចលនវត្ថុដែរ។ ចំពោះការលុបគឺមានតែស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីតែប៉ុណ្ណោះទើបអាចធ្វើការលុបចេញវិញបាន គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ ស្រុក ខណ្ឌដែលអចលនវត្ថុនោះតាំងនៅ និងធ្លាប់បានយកទៅធ្វើការចុះបញ្ជីចារបន្ទុកកាលពីពេលបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ។

**កថាខណ្ឌទី២៖ ការអនុវត្តកាតព្វកិច្ចតាមប្រព័ន្ធតុលាការ**

នៅពេលកូនបំណុល និងម្ចាស់បំណុលបានបង្កើតកិច្ចសន្យាជាមួយគ្នាហើយ កូនបំណុលមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាដែលខ្លួនបានបង្កើតឡើងជាមួយម្ចាស់បំណុលនោះទេ តាមក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា និង ផ្តល់សិទ្ធិសម្រាប់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តសិទ្ធិ

---

[45] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤៥។

[46] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤៥។

[47] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៤៤។

[48] ប្រកាស, លេខ ០៣០ សហវ.ប្រក, ១៣ មករា ២០១៧, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទទួលប្រតិភោគដោយអនុប្បទាន ប្រការ១៣។

ប្រាតិភោគរបស់ខ្លួន មានដូចជា ការទាមទារឱ្យអនុវត្តការតព្វកិច្ចដោយបង្ខំ ទាមទារសំណងនៃការខូចខាត និង ការរំលាយកិច្ចសន្យា។[49]

ការទាមទារឱ្យអនុវត្តដោយបង្ខំ គឺជាគោលបំណងឱ្យអនុវត្តកាតព្វកិច្ចដោយផ្ទាល់របស់កូនបំណុល។ ផ្ទុយមកវិញ ការទាមទារសំណងការខូចខាត និង ការរំលាយកិច្ចសន្យា ជាការដាក់កំហិតឱ្យកូនបំណុល អនុវត្តកាតព្វកិច្ចរបស់ខ្លួន និងបញ្ចុះបញ្ចូលកូនបំណុលឱ្យអនុវត្តកាតព្វកិច្ចដោយប្រយោល។ ក្នុងករណីនេះការរំលាយកិច្ចសន្យាមិនត្រូវបានយកមកសិក្សានៅទីនេះនោះទេ ព្រោះថាម្ចាស់បំណុលត្រូវសម្រេចឱ្យបាននូវសិទ្ធិលើបំណុលដែលកើតឡើងតាមរយៈការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុរបស់ខ្លួន ដូច្នេះយើងនឹងធ្វើការសិក្សាទាក់ទងនឹងការអនុវត្តដោយបង្ខំ និង ការទាមទារសំណងនៃការខូចខាត។ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានក្នុងករណី ដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា ទៅតាមទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចខាងក្រោមនេះ៖

ក. កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសាការយឺតយ៉ាវក្នុងការអនុវត្តរបស់ខ្លួន សំដៅទៅលើករណីភាគីទាំងពីរបានកំណត់ពេលវេលាជាក់លាក់ ដើម្បីអនុវត្ត តែភាគីកូនបំណុលទុកពេលដែលកំណត់ជាក់លាក់នោះឱ្យកន្លងហួស ដោយមិនអើពើក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នោះត្រូវចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្ត។

ខ. កូនបំណុលអលទ្ធភាព ក្នុងការអនុវត្តកាតព្វកិច្ច សំដៅទៅលើពេលដែលកូនបំណុលគ្មានលទ្ធភាពក្នុងការអនុវត្តតាមសារធាតុ តាមស្ថានភាពសង្គម ឬសេដ្ឋកិច្ច នោះការអនុវត្តកាតព្វកិច្ចត្រូវចាត់ទុកថា អលទ្ធភាពក្នុងការអនុវត្ត។

គ. កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច មានន័យថាកូនបំណុលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែសកម្មភាពនៃការអនុវត្តកាតព្វកិច្ចនោះ គឺបង្ហាញមិនសមស្រប និងមិនត្រឹមត្រូវនៅក្នុងសកម្មភាពដែលមិនសមហេតុផល។ នៅពេលដែលការអនុវត្តកាតព្វកិច្ចមិនបានធ្វើឡើង នោះត្រូវបានចាត់ទុកថាការយឺតយ៉ាវក្នុងការអនុវត្ត ឬអសមត្ថភាពក្នុងការអនុវត្ត មិនមែនជាការអនុវត្តមិនបានពេញលេញនោះទេ។

កាលណា កូនបំណុលមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះទេ ម្ចាស់បំណុលអាចជ្រើសរើសវិធីសង្គ្រោះកិច្ចសន្យាដោយទាមទារអោយអនុវត្តដោយបង្ខំចំពោះកម្មវត្ថុរបស់កូនបំណុល ដែលបានយកមកដាក់បញ្ចាំនោះបានទៅតាមនីតិវិធីរបស់តុលាការ ។

យើងសុំបែងចែកជាបួនចំណុច គឺ ២.១.ស្ថាប័ននៃការអនុវត្ត ២.២. នីតិវិធីនៃការរឹបអូសអចលនវត្ថុ ២.៣. នីតិវិធីនៃការលក់អចលនវត្ថុដោយបង្ខំ ២.៤ នីតិវិធីចែកចំណែក។

---

[49] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩០។

### ២.១. ស្ថាប័ននៃការអនុវត្ត

ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងជាក់លាក់នូវស្ថាប័នដែលទទួលបន្ទុកអនុវត្តដោយបង្ខំ។[50] ស្ថាប័នអនុវត្ត គឺជាស្ថាប័នទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំដែលជាអំណាចរបស់រដ្ឋ។ មានន័យថាមានតែ ស្ថាប័នអនុវត្តទេដែលមានសិទ្ធិអំណាចចាត់ចែងនីតិវិធីអនុវត្តដោយបង្ខំ ពោលគឺពុំមានស្ថាប័នណាផ្សេងដែលអាចអនុវត្តដោយបង្ខំឡើយ។[51] ស្ថាប័នអនុវត្តរួមមាន តុលាការអនុវត្ត និងអាជ្ញាសាលា។[52] តុលាការអនុវត្តនិងអាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័នទាំងពីរនេះ មានចរិតលកខណៈផ្សេងគ្នា ហេតុនេះហើយបានជាច្បាប់ដាក់បន្ទុកផ្សេងពីគ្នា ទៅតាមស្ថាប័ននីមួយៗដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្ត និងទៅតាមប្រភេទនៃការអនុវត្តដោយបង្ខំ។

**តុលាការអនុវត្ត** គឺជាតុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬដែលធ្វើការពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ។ ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៣៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ច្បាប់ពុំបានបង្កើតឱ្យមានតុលាកាពិសេសពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំទេ ពោលគឺ តុលាការអនុវត្តគឺសាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ។ តុលាការអនុវត្តនេះ បានដើរតួនាទីជាស្ថាប័នអនុវត្តដោយបង្ខំដោយផ្ទាល់ ហើយប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំដែលស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់តុលាការអនុវត្ត រួមមានៈ ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះសិទ្ធិលើបំណុលនិងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[53] ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ [54] ការអនុវត្តដោយបង្ខំនិងការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា[55] ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុក្នុងករណីដែលវត្ថុនោះកាន់កាប់ដោយតតិយជន[56] ជាអាទិ៍។ លើសពីនេះទៅទៀត តុលាការអនុវត្តក៏ដើរតួនាទីជាស្ថាប័នសម្រាប់សហការលើនីតិវិធីអនុវត្តដោយបង្ខំ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលាដូចជាការផ្លាស់ប្តូរទំហំនៃការហាមឃាត់មិនឱ្យរឹបអូស[57] ការចែកចំណែកដែលមិនអាចសម្រេចដោយអាជ្ញាសាលាបាន[58] និងការសម្រេចសេចក្តីអំពីការតវ៉ាការចាត់ចែងការអនុវត្ត[59] ជាអាទិ៍។

---

[50] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ ចំណុច២។
[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ ចំណុច១។
[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ ចំណុច២។
[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០២។
[54] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៨។
[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥៦។
[56] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥២៦។
[57] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨១។
[58] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០១។
[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៥។

**អាជ្ញាសាលា** គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូលឯកសារនានាដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលកំណត់តាមច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗទៀត។ បន្ថែមលើសពីនេះទៅទៀត អាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យមួយ ដែលទទួលបន្ទុកបញ្ជូននូវឯកសារនានាដែលចេញដោយស្ថាប័នតុលាការ និង ធ្វើការអនុវត្តដោយបង្ខំដែលច្បាប់បានប្រគល់សិទ្ធិឱ្យ។ ជាគោលការណ៍សមត្ថកិច្ចរបស់អាជ្ញាសាលាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី គឺអនុវត្តដោយបង្ខំចំពោះតែចលនវត្ថុ ដែលពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំស្ថិតនៅ។[60] ទោះបីជាយ៉ាងណាក៏ដោយ ចំពោះការអនុវត្តដោយបង្ខំគ្មានគោលបំណងឱ្យសងជាប្រាក់អាជ្ញាសាលាមានសមត្ថកិច្ចអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុបានដែរ។ នៅក្នុងការអនុវត្តដោយបង្ខំលើអចលនវត្ថុ អាជ្ញាសាលាមានភារកិច្ចជាជំនួយដ៏ស្វាហាប់ដល់តុលាការអនុវត្ត នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលអាជ្ញាសាលាធ្វើការសិក្សាស្រាវជ្រាវព័ត៌មានយ៉ាងលម្អិត និងសិក្សាអំពីស្ថានភាពនៃអចលនវត្ថុនោះហើយបើមានការប្រឆាំងតបតណាមួយកើតឡើង អាជ្ញាសាលាអាចប្រើកម្លាំង ឬ សុំជំនួយពីនគរបាល ឬកងកម្លាំងដែលមានសមត្ថកិច្ចចូលរួមធ្វើអន្តរាគមន៍ធ្វើការដោះស្រាយបាន។ មិនតែប៉ុណ្ណោះ ចំពោះការលក់អចលនវត្ថុនោះវិញ ប្រសិនបើលក់តាមវិធីលក់ដោយឡាយឡុង ដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នេះ។[61] ទាំងការស្រាវជ្រាវពីសណ្ឋាននៃអចលនវត្ថុ និងការលក់ឡាយឡុងដោយស្រោមសំបុត្រគឺជាការងារដែលធ្វើឡើងដោយអាជ្ញាសាលា តាមការបង្គាប់តុលាការ។ យើងសង្កេតឃើញថា អាជ្ញាសាលាក៏មានតួនាទី ជាអ្នកលក់នូវអចលនវត្ថុនោះផងដែរ។ អាស្រ័យហេតុនេះទោះបីជាអាជ្ញាសាលា មិនមានសមត្ថកិច្ចចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុក៏ដោយ ក៏អាជ្ញាសាលាមានតួនាទីយ៉ាងសកម្មជាមួយតុលាការអនុវត្តទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគអចលនវត្ថុដែរ ដូចជាការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និងការលក់ឡាយឡុងអចលនវត្ថុជាដើម។

### ២.២. នីតិវិធីនៃការរឹបអូសអចលនវត្ថុ

ក្នុងនីតិវិធីងអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគត្រូវបានចាប់ផ្តើមដោយការរឹបអូសអចលនវត្ថុចលនវត្ថុជានានា ឬសិទ្ធិលើបំណុលជាដើម។ ការរឹបអូសគឺជាសកម្មភាព នៃការប្រើអំណាចផ្អាកផ្តាក់ទ្រព្យសម្បត្តិជាក់លាក់ណាមួយទៅក្នុងស្ថានភាពដែលមានបំណង ដើម្បីធានាទ្រព្យនោះ ទុកជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។[62] និយាយម្យ៉ាងទៀត ការរឹបអូស គឺជាការហាមឃាត់ដោយស្ថាប័នអនុវត្ត នូវការចាត់ចែងជាក់ស្តែង និងតាមផ្លូវ

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៨៤។
[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៤៣៦។
[62] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣៧១។

ច្បាប់របស់កូនបំណុលនៃការអនុវត្តទៅលើទ្រព្យសម្បត្តិជាក់លាក់មួយ ដូចជា ហាមឃាត់ការផ្ទេរកម្មសិទ្ធិដោយការលក់ ឬប្រទានកម្មជាដើម។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការរឹបអូសធ្វើឡើងតាមរយៈដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។[63]

ក្នុងចំណោមការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគទាំងអស់ គឺមានតែការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុតែមួយប៉ុណ្ណោះដែលមានភាពលំបាក និងមាននីតិវិធីស្មុកស្មាញជាងគេ ដោយហេតុថា អចលនវត្ថុភាគច្រើនមានតម្លៃថ្លៃៗ ហើយភាគច្រើនជាទីតាំងនៃសម្រាប់ការរស់នៅជាប្រចាំថ្ងៃរបស់កូនបំណុល ដែលចាំបាច់ស្ថាប័នអនុវត្តត្រូវតែធ្វើការពិនិត្យពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការរឹបអូសអចលនវត្ថុនោះ។ អចលនវត្ថុដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបានរួមមាន ដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគានោះ សិទ្ធិជួលអចិន្ត្រៃដែលត្រូវបានចុះបញ្ជីផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាកម្មសិទ្ធិរួម។[64] មូលហេតុដែលច្បាប់តម្រូវឱ្យរឹបអូសអចលនវត្ថុដែលបានចុះបញ្ជី គឺដើម្បីធានាថាអចលនវត្ថុដែលត្រូវបានរឹបអូសនោះគឺ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តពិតប្រាកដមែន។ ទោះជាយ៉ាងនេះក្តី ច្បាប់ក៏មិនបានហាមឃាត់តុលាការអនុវត្តរឹបអូសអចលនវត្ថុដែលមិនបានចុះបញ្ជីដែរ។ ក្នុងករណីនេះ ក្រឡាបញ្ជីនៃតុលាការអនុវត្តត្រូវផ្ទុកផ្តាក់ទៅអង្គភាពសុរិយោដីឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុនោះ ទៅតាមនីតិវិធីដែលកំណត់ដោយក្រសួងមានសមត្ថកិច្ច។

ក្រោយពីបានពិនិត្យពាក្យសុំឱ្យអនុវត្តដោយបង្ខំឃើញថា អ្នកដាក់ពាក្យសុំពោលគឺ ម្ចាស់សិទ្ធិលើបំណុលនៃការអនុវត្តបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់សព្វគ្រប់ហើយ តាំងពីការពិនិត្យសមត្ថកិច្ចតុលាការកម្មវត្ថុអនុវត្ត ជាពិសេសអ្នកដាក់ពាក្យសុំបង់ពន្ធ និងសោហ៊ុយនានាសម្រាប់អនុវត្ត ហើយតុលាការអនុវត្តត្រូវចាប់ផ្តើមនីតិវិធីរឹបអូស។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។ នៅពេលចាប់ផ្តើមនីតិវិធីនៃការលក់ តុលាការអនុវត្តត្រូវចេញ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ដែលដីកានេះត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអត្តសញ្ញាណនៃអចលនវត្ថុដែលត្រូវបានរឹបអូសនោះ។ បន្ទាប់មកក្រឡាបញ្ជីត្រូវចាត់ចែងការបញ្ជូនដីកាសម្រេចនេះ ទៅកូនបំណុលនៃការអនុវត្តដើម្បីឱ្យកូនបំណុលបានដឹងអំពី ការរឹបអូសនេះ ហើយតវ៉ាចំពោះការអនុវត្តឱ្យតុលាការផ្អាក ឬ លុបចោលការអនុវត្តប្រសិនបើគាត់មានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់។[65] បន្ទាប់មកទៀតក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដូចមានចែងក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។ ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដូចមានចែងក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។ ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីផ្ទុកផ្តាក់ការរឹបអូស

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥១៩។

[64] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥១៧ កថាខណ្ឌទី១។

[65] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥១៩។

អចលនវត្ថុនោះ គឺអង្គភាពសុរិយោដី ស្រុក ក្រុង ខណ្ឌ ឬរាជធានី ខេត្តនៃអចលនវត្ថុស្ថិតនៅ។ ការផ្ទុកផ្តាក់ធ្វើឡើងតាមវិធីដែលក្រឡាបញ្ជីជាជំនួយរបស់តុលាការអនុវត្ត ផ្ញើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីការរឹបអូស ដែលលិខិតនោះត្រូវបានបញ្ជាក់លំអិតអំពីអត្តសញ្ញាណនៃអចលនវត្ថុ គោលបំណងនៃការចុះបញ្ជី មូលហេតុនៃការចុះបញ្ជី អ្នកដែលមានសិទ្ធិចុះបញ្ជី ហើយត្រូវភ្ជាប់ទៅជាមួយនូវ ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ រួមទាំងប្រាក់ពន្ធសម្រាប់ការចុះបញ្ជីទៅអង្គភាពសុរិយោដីនៃទីតាំងនៃអចលនវត្ថុស្ថិតនៅ ឱ្យបានឆាប់រហ័ស។[66]

ពន្ធលើការចុះបញ្ជីផ្ទុកផ្តាក់ពីការរឹបអូសខាងលើ គឺជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្ត។ តុលាការក៏អាចចាត់ចែងឱ្យក្រឡាបញ្ជីផ្ទុកផ្តាក់ចុះបញ្ជីអំពីការរឹបអូសជាមុន ទើបបញ្ជូនដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំទៅឱ្យកូនបំណុលពេលក្រោយក៏បាន ដើម្បីឱ្យកូនបំណុល ចាត់ចែងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិនៃការរឹបអូសនោះ។[67] ក្រោយពីចុះបញ្ជីការរឹបអូសរួចរាល់ហើយ អង្គភាពសុរិយោដីនោះត្រូវផ្ញើរបាយការណ៍អំពីការចុះបញ្ជីរឹបអូស ដោយភ្ជាប់មកនូវឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីទៅក្រឡាបញ្ជី ដើម្បីជូនចៅក្រមពិនិត្យ។ ក្រោយពីការរឹបអូសត្រូវបានធ្វើរួចហើយ ចៅក្រមត្រូវចេញសេចក្តីបង្គាប់ឱ្យវាយតម្លៃដើម្បីចាត់តាំងអ្នកជំនាញធ្វើការវាយតម្លៃអចលនវត្ថុនោះ។ អ្នកវាយតម្លៃនិងស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុនោះ ហើយធ្វើរបាយការណ៍ជូនចៅក្រមពិនិត្យ។ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ អាចសួរសំនួរ ឬ ទាមទារកូនបំណុលនៃការអនុវត្ត ឬតតិយជនបង្ហាញឯកសារនានាដែលចាំបាច់បាន។ លើសពីនេះ អ្នកវាយតម្លៃអាចស្នើសុំជំនួយពីអាជ្ញាសាលាដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន ឬចាត់ចែងចាំបាច់ដើម្បីបើកទ្វាដែលបិទបាន។ បើយល់ឃើញថាចាំបាច់តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវបន្ថែមអំពីស្ថានភាពនៃការកាន់កាប់ រចនាសម្ព័ន្ធនៃអាគារបើមានអាគារ ឬ បើកម្មវត្ថុនៃការអនុវត្តគឺជាអាគារជាដើម ដោយដីកាបង្គាប់ឱ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ។[68] អាជ្ញាសាលា ត្រូវធ្វើរបាយការណ៍ស្តីពី ការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ជូនចៅក្រម ដើម្បីជាមូលដ្ឋានសម្រាប់ចៅក្រមធ្វើឯកសារលំអិតអំពីវត្ថុដើម្បីឱ្យសាធារណៈជនមើល។[69]

ដូចដែលយើងបានដឹងរួចមកហើយថា ការរឹបអូសអាចធ្វើបានតែតាមរយៈដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំតែប៉ុណ្ណោះ។ ចាប់តាំងពីដីកាសម្រេចនេះត្រូវបានបញ្ជូនដល់ដៃកូនបំណុលនៃការអនុវត្ត អានុភាពនៃការរឹបអូស ត្រូវចាប់រាប់ពីពេលនោះ។ ប៉ុន្តែ ក្នុងករណីដែលការបញ្ជូនធ្វើឡើងក្រោយពេលចុះបញ្ជីផ្ទុកផ្តាក់ការរឹប

[66] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤២០ កថាខណ្ឌទី១។

[67] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤២១ កថាខណ្ឌទី២។

[68] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣០។

[69] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣៤ កថាខណ្ឌទី១។

អូសវិញ នោះអានុភាពនៃការរឹបអូសត្រូវចាប់រាប់ចាប់តាំងពីការចុះបញ្ជី។ ការរឹបអូសនេះបង្កើតបាននូវអានុភាពចំនួនពីរ គឺ ទីមួយអានុភាពចំពោះវត្ថុ មានទៅលើវត្ថុដែលភ្ជាប់ទៅនឹងអចលនវត្ថុ និងផ្នែកមួយនៃអចលនវត្ថុនោះព្រមទាំងវត្ថុចំណុះ និងសិទ្ធិចំណុះនៃអចលនវត្ថុនោះ។ ឧទាហរណ៍ ផ្ទះវីឡាមួយកន្លែងត្រូវបានតុលាការចេញដីកាសម្រេចរឹបអូសតាមភាគីម្ចាស់បំណុល។ អានុភាពនៃដីកាសម្រេចនេះ មានទៅលើ របង ទីធ្លាសួនច្បារ និងសម្ភារៈនានាដែលភ្ជាប់ទៅនឹងផ្ទះវីឡាដូចជា ទ្វាបង្អួច និងម៉ាស៊ីនត្រជាក់ជាដើម និងទីពីរ អានុភាពចំពោះមនុស្ស ពោលគឺកូនបំណុល ត្រូវបានហាមឃាត់ការចាត់ចែង ឬផ្ទេរកម្មសិទ្ធិទៅអ្នកដទៃតាមគ្រប់វិធី ដោយកូនបំណុលអាចត្រឹមតែប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុតាមវិធីធម្មតាប៉ុណ្ណោះ។

### ២.៣. នីតិវិធីនៃការលក់អចលនវត្ថុដោយបង្ខំ

តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃ អចលនវត្ថុ ដោយផ្អែកទៅលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត។[70] ច្បាប់មិនបានកំណត់លក្ខណៈសម្បត្តិរបស់អ្នកវាយតម្លៃទេ ដូច្នេះ តុលាការអាចជ្រើសតាំងអ្នកជំនាញក្នុងការវាយតម្លៃអចលនវត្ថុ ដែលជាក្រុមហ៊ុនឯកជនណាមួយ ដោយបច្ចុប្បន្ន គឺជាក្រុមហ៊ុនជំនាញខាងវាយតម្លៃអចលនវត្ថុ (Real Estate Property Co.LTD ) ជាដើម។ អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការស្រាវជ្រាវ អំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះ។[71]

តាមការសិក្សាស្រាវជ្រាវ ចំពោះការអនុវត្តដោយបង្ខំ គឺមិនទាន់មានស្ថាប័នមួយណាដែល មានភារកិច្ចច្បាស់លាស់នៅក្នុងការវាយតម្លៃអចលនវត្ថុនៅឡើយទេ។ ជាពិសេសសម្រាប់ការអនុវត្តក្នុងតុលាការនីមួយៗ គឺមានភាពដាច់ដោយឡែកពីគ្នាទៅតាមទម្លាប់ជាក់ស្តែងហើយការវាយតម្លៃនេះធ្វើឡើងត្រូវផ្អែកលើះ

ការវាយតម្លៃដោយមន្ទីររៀបចំដែនដី នគរូបណីយកម្ម សំណង់ និងសុរិយោដីយោងតាមរយៈការអនុវត្តកន្លងមក នៅឯសាលាតំបូងរាជធានីភ្នំពេញ បានធ្វើការជ្រើសតាំងមន្ទីររៀបចំដែនដី នគរូបណីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញជាអ្នកវាយតម្លៃ ដោយផ្អែកតាមលិខិតសុំធ្វើការវាយតម្លៃលើអចលនវត្ថុ។ ដោយការវាយតម្លៃគឺផ្អែកលើ ប្រកាស លេខ៣៧១ សហវ.ប្រក ចុះថ្ងៃ ទី០៥ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានធ្វើការបែងចែកជាភូមិសាស្ត្រ និងតម្លៃនៃអចលនវត្ថុក្នុងប្រតិបត្តិការបង់ពន្ធ។ ចំពោះការរៀបចំការវាយតម្លៃនោះ គឺការិយាល័យរៀបចំដែនដី នគរូបនីកម្ម សំណង់ និងភូមិបាលជាអ្នកវាយតម្លៃ។

ចំពោះការវាយតម្លៃដោយក្រុមហ៊ុនឯកជន មានលក្ខណៈខុសពីស្ថាប័នខាងលើត្រង់ថា ចំពោះការវាយតម្លៃដែលធ្វើឡើងដោយក្រុមហ៊ុនមានការរៀបចំជារបាយការណ៍នៃការវាយតម្លៃ ដែលបានរៀបរាប់យ៉ាងលម្អិតអំពីស្ថានភាពនៃសំណង់ ក៏ដូចជាតម្លៃលើទីផ្សារ ព្រមទាំងភាពខ្លាំង និងខ្សោយនៃអចលនវត្ថុនោះ។ ប៉ុន្តែការជ្រើស

---

[70] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣០។

[71] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣០ កថាខណ្ឌទី៥។

តាំងក្រុមហ៊ុន គឺ ធ្វើឡើងតាមរយៈថៅក្រមនៃការអនុវត្តនេះដោយសាតែត្រូវធ្វើការកំណត់អំពីតម្លៃនៃអចលនវត្ថុនោះ ដើម្បីបន្តនីតិវិធី។

បន្ទាប់ពីបំពេញលក្ខខណ្ឌនៃការលក់ និងបានរៀបចំនីតិវិធីនៃការលក់រួច តុលាការត្រូវប្រកាសអំពីការលក់ និង បង្គាប់ឱ្យអាជ្ញាសាលាធ្វើសកម្មភាពអនុវត្តការលក់ តាមវិធីនៃការលក់ណាមួយជាកំណត់។ កិច្ចចម្បងនៃនីតិវិធីអនុវត្តការលក់ កាលបើអ្នកទិញដែលបានដេញថ្លៃទិញបាន ក្នុងតម្លៃអតិបរិមា តុលាការអនុវត្តត្រូវសម្រេចអំពីការអនុញ្ញាតឱ្យលក់។

បន្ទាប់ពីតុលាការអនុវត្តចេញ ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមាន តុលាការអនុវត្តត្រូវចេញដីកាសម្រេចឱ្យអាជ្ញាសាលាអនុវត្តលក់ [72] ហើយដីកាសម្រេចឱ្យអនុវត្តលក់នោះត្រូវកំណត់អំពីនីតិវិធីនៃការលក់៖ វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់។ ក្នុងករណីដែលមិនអាចលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានទេ តុលាការអនុវត្តអាចកំណត់វិធីផ្សេងដើម្បីលក់បាន។[73]

បន្ទាប់ពីតុលាការចេញ ដីកាសម្រេចឱ្យអនុវត្តការលក់ ក្រឡាបញ្ជីតុលាការ ត្រូវផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ ដោយបញ្ជាក់នូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា កាលបរិច្ឆេទលក់ ទីកន្លែងលក់ ព្រមទាំងព័ត៌មានផ្សេងទៀត។ [74] រយៈពេលនៃការផ្សាយមិនមានកំណត់ច្បាស់លាស់ទេ។ តាមការអនុវត្តការផ្សាយធ្វើឡើងក្នុងអំឡុងពេល០១ខែ។ ជាទូទៅភាពមិនប្រក្រតីនៃនីតិវិធីនៃការលក់អាចកើតមានដោយសាការលក់ដោយសម្ងាត់។[75] ចំពោះការលក់ដោយសំងាត់នេះអាចកើតឡើងដោយសាការមិនប្រកាសជាសាធារណៈ ឬ ការលក់ដោយមិនបើកចំហឱ្យសាធារណៈជនបានដឹងដែលនោះ បញ្ជាក់ឱ្យឃើញពីភាពមិនប្រក្រតីនៃនីតិវិធីរបស់តុលាការ។ ការលក់នោះមិនអាចត្រូវបានធ្វើឡើងដោយអ្នកទិញជាបុគ្គលដែលអសមត្ថភាព ឬបុគ្គល ដែលមិនអាចក្លាយជាអ្នកទិញបាន ដែលមានជាអាទិ៍ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬតាមកិច្ចសន្យា ថៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬបមន្ត្រីតុលាការផ្សេងទៀត គឺច្បាប់មិនអនុញ្ញាតឱ្យក្លាយជាអ្នកទិញឡើយ។ លើសពីពីនេះទៅទៀត ដើម្បីឱ្យនីតិវិធីដំណើរការទៅបានល្អ និងមានភាពសុក្រិត្យ តុលាការគួរតែមានការសហការជាក្រុមហ៊ុនឯកជន ក្នុងការផ្សាយដោយអាចផ្សាយក្នុងសៀវភៅមគ្គុទេស ឬ គេហទំព័របាន។

[72] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី៣។
[73] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី២។
[74] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី៣។
[75] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា៥២៥ និង មាត្រា៥២៦។

កាលបរិច្ឆេទនៃកាលក់ ត្រូវធ្វើឡើងដោយអាជ្ញាសាលា នៅកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ក្នុងការផ្សាយជាសាធារណៈ។ គោលគំនិតនៃកាលបរិច្ឆេទនៃការលក់ គឺដើម្បីកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអប្បបរមាតាមរយៈវិធីនៃការលក់ដែលបានកំណត់ដោយតុលាការអនុវត្ត។

កាលបរិច្ឆេទនៃការលក់ អាជ្ញាសាលា ត្រូវឱ្យបុគ្គលដែលមានវត្តមាន មើលសំណុំរឿងនៃការអនុវត្តដោយបង្ខំ ហើយលើកទឹកចិត្តឱ្យពួកគេស្នើសុំទិញ។ កាលបរិច្ឆេទនៃការលក់ អាជ្ញាសាលាត្រូវចែកទម្រង់ពាក្យសុំផ្តល់សំណើទិញ ទៅអ្នកមានបំណងធ្វើសំណើទិញ។ អ្នកមានបំណងធ្វើសំណើទិញទាំងអស់ ត្រូវសរសេរបំពេញទម្រង់ក្នុងពាក្យសុំនោះ។ ចំណុចសំខាន់ៗ ដែលត្រូវបំពេញក្នុងទម្រង់ពាក្យសុំផ្តល់សំណើទិញ៖

- អត្តសញ្ញាណរបស់អ្នកផ្តល់សំណើទិញ ឬ អ្នកតំណាងដោយអាណត្តិ
- តម្លៃដែលស្នើសុំទិញ
- ប្រាក់ធានាសំណើទិញ
- វិធីផ្តល់ប្រាក់ធានាលើសំណើទិញ(មូលប្បទានបត្រ ឬ សាច់ប្រាក់)

បុគ្គលដែលបម្រុងធ្វើសំណើទិញអចលនវត្ថុត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹង១០%នៃតម្លៃអតិប្បរមា។ ចំនួនទឹកប្រាក់ដែលបានស្នើ ត្រូវដាក់ឱ្យស្មើ ឬ ច្រើនជាងតម្លៃលក់អប្បបរមា។ ក្នុងករណីនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ អ្នកស្នើសុំទិញ ត្រូវបានចងដោយពាក្យស្នើសុំទិញនោះ រហូតដល់ពេលដែលមានពាក្យសុំទិញថ្មីដែលមានតម្លៃខ្ពស់ជាមុន ហើយពាក្យសុំនោះមានលក្ខណៈស្របច្បាប់។

នៅពេលបញ្ចប់ការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ផ្ទាលមាត់ អាជ្ញាសាលា ត្រូវប្រកាសអត្តសញ្ញាណរបស់អ្នកទិញដែលដេញថ្លៃបាន និង ថ្លៃលក់ឡាយឡុងនោះ ទើបអាជ្ញាសាលាប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុង។

### ២.៤. នីតិវិធីចែកចំណែក

ការចែកចំណែក គឺជានីតិវិធីមួយដ៏សំខាន់មិនអាចខ្វះបានក្នុងការអនុវត្តដោយបង្ខំចំពោះ សិទ្ធិទាមទារដែលមានគោលបំណងឱ្យសងប្រាក់ ព្រោះនៅដំណាក់កាលនេះ សិទ្ធិលើបំណុល របស់ម្ចាស់បំណុល អាចសម្រេចជាស្ថាពរ តាមរយៈការទទួលបានចំណែកពីការលក់ដោយបង្ខំនូវទ្រព្យរបស់កូនបំណុល។ ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាជ្ញាសាលាពុំមានសមត្ថកិច្ចក្នុងការចែកចំណែកនោះទេ គឺតុលាការអនុវត្តជាអ្នកមានសមត្ថកិច្ចក្នុងការចែកចំណែកនេះ។[76] ប៉ុន្តែការចែកចំណែកពីការលក់អចលនវត្ថុ ត្រូវធ្វើឡើងដោយអាជ្ញាសាលា។ ក្នុងនីតិវិធីចែកចំណែកដោយអាជ្ញាសាលា ប្រសិនបើប្រាក់ដែលទទួលពីការលក់ចលវត្ថុ នោះគ្រប់គ្រាន់សម្រាប់ចែកចំពោះម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលផ្សេងទៀតដែល មានសិទ្ធិទទួលបានការចែកចំណែក

[76] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៨៧។

ព្រមទាំងសោហ៊ុយនៃនីតិវិធីហើយនោះ ការចែកចំណែក ត្រូវធ្វើឡើងដោយអាជ្ញាសាលា។ ផ្ទុយទៅវិញ ប្រសិនបើប្រាក់ដែលបានមកពីការលក់អចលនវត្ថុ មិនគ្រប់សម្រាប់ចែកចំណែកដល់ម្ចាស់បំណុលទាំងអស់ និងសោហ៊ុយនីតិវិធីបានទេ ប៉ុន្តែម្ចាស់បំណុលទាំងអស់ព្រមព្រៀងគ្នាទទួលយកចំណែកតាមសមាមាត្រនូវភាគដែលខ្លួនមាន សិទ្ធិទទួល អាជ្ញាសាលាអាចធ្វើការចែកចំណែកបានតាមការព្រមព្រៀងនោះ។[77]

ជាគោលការណ៍ ការចែកចំណែកពីការលក់អចលនវត្ថុ ត្រូវធ្វើឡើងដោយតុលាការអនុវត្ត។[78] សមត្ថកិច្ចចែកចំណែករបស់តុលាការអនុវត្តមានចំពោះ៖

- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្នុងករណីដែលកូនបំណុលទី៣ បានផ្ញើប្រាក់ស្មើនឹងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសមកតុលាការ។
- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្នុងករណី ដែលសិទ្ធិលើបំណុលត្រូវបានលក់ ហើយប្រាក់ដែលបានពីការលក់នោះត្រូវបានប្រគល់ជូនតុលាការអនុវត្ត។[79]
- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតដែលមានគោលបំណងឱ្យប្រគល់ត្រូវបានរឹបអូស ហើយអាជ្ញាសាលាលក់អចលនវត្ថុនោះរួចប្រគល់ ប្រាក់ពីការលក់មកតុលាការ។

ករណីការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលអ្នកទិញ គឺជាម្ចាស់បំណុលនៃការអនុវត្តដែលត្រូវទទួលបានការចែកចំណែក ហើយអ្នកទិញនេះបានបង់ថ្លៃលក់ដោយដកចេញ នូវចំណែកដែលខ្លួនត្រូវទទួលបាន នៅកាលបរិច្ឆេទ នៃការចែកចំណែក។

ក្នុងករណីមានម្ចាស់បំណុលច្រើននាក់ ហើយប្រាក់ដែលបានពីការលក់អចលនវត្ថុមិនគ្រប់ សម្រាប់ការចែកចំណែកដល់ម្ចាស់បំណុលទាំងអស់ និងសោហ៊ុយសម្រាប់ការអនុវត្ត ដោយយកលិខិតគណនាបំណុលដែលម្ចាស់បំណុលទាំងអស់ និងសោហ៊ុយសម្រាប់ការអនុវត្ត ដោយយកលិខិតគណនាបំណុលដែលម្ចាស់បំណុលនីមួយៗផ្ញើមកជាមូលដ្ឋាន ការចែកចំណែកត្រូវធ្វើតាមតារាងបែងចែកចំណែក។ ជាទូទៅ លំដាប់នៃការទទួលបានចំណែកនិង ចំនួនទឹកប្រាក់នៃការបែងចែកចំណែកធ្វើឡើងតាមការព្រមព្រៀងរវាងម្ចាស់បំណុលទាំងអស់ដូចដែលមានក្នុងតារាងបែងចែកចំណែក។ វិធីចែកចំណែក គឺធ្វើឡើងដោយគ្រាន់តែប្រគល់ដោយផ្ទាល់នូវប្រាក់ចំណែកដែលម្ចាស់បំណុលនីមួយៗត្រូវទទួលបាន ហើយដែលម្ចាស់បំណុលនោះមានវត្តមាននៅក្នុងតារាងបែងចែកចំណែក។ ដោយឡែកចំពោះម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែក ប៉ុន្តែម្ចាស់បំណុល

---

[77] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៩៩ កថាខណ្ឌទី២។

[78] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៨៧។

[79] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥១១ នៃកថាខណ្ឌទី១ និងកថាខណ្ឌទី២។

នោះមិនមានវត្តមាននៅកាលបរិច្ឆេទចែកចំណែក ប៉ុន្តែបានជូនដំណឹង ដោយមានមូលហេតុសមរម្យដល់តុលាការអនុវត្តត្រូវផ្អាកទុក នូវប្រាក់ចំណែកនោះនៅតុលាការសិនរង់ចាំម្ចាស់បំណុល មកទទួលយក។[80]

កាលណាម្ចាស់បំណុលមានតែម្នាក់ ឬ មានច្រើននាក់ ប៉ុន្តែប្រាក់ដែលបានមកពីការលក់អចលនវត្ថុ មានគ្រប់គ្រាន់សម្រាប់ចែកចំណែកដល់ម្ចាស់បំណុលទាំងអស់ រួមទាំងសោហ៊ុយសម្រាប់ការអនុវត្តបាន តុលាការអនុវត្តមិនចាំបាច់ធ្វើតារាងបែងចែកចំណែកឡើយ។ ការចែកចំណែក គឺផ្អែកលើសេចក្ដីចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និងតារាងគណនាបំណុលដែលម្ចាស់បំណុលបានផ្ញើមកតុលាការ។ វិធីចែកចំណែកធ្វើឡើងដោយការប្រគល់សាច់ប្រាក់ទៅម្ចាស់បំណុលទាំងអស់ដែលមានវត្តមាននៅកាលបរិច្ឆេទចែកចំណែក។ ដោយឡែក ម្ចាស់បំណុលដែលត្រូវទទួលចំណែក ប៉ុន្តែមិនបានចូលរួមដោយមានមូលហេតុសមរម្យ ហើយជូនដំណឹងមកតុលាការ តុលាការអនុវត្តត្រូវរក្សាទុកប្រាក់នៃចំណែកនោះសិនរង់ចាំម្ចាស់បំណុលនោះមកទទួលយក។ ប្រសិនបើការបែងចែកមានប្រាក់ដែលនៅសល់ តុលាការត្រូវប្រគល់ប្រាក់នោះ ទៅកូនបំណុលនៃការអនុវត្តវិញ។[81]

[80] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៩៤ កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[81] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៩៥ កថាខណ្ឌទី២

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុក្នុងក្របខ័ណ្ឌច្បាប់កម្ពុជាពិតជារបបគតិយុត្តមួយដែលមានសារៈសំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជាពិតមែន។ បើធ្វើការពិនិត្យឱ្យបានច្បាស់ទៅនោះ នឹងអាចឃើញថាសិទ្ធិលើការបញ្ចាំអចលនវត្ថុគឺជាយន្តការមានអាទិភាពមួយដែលប្រជាពលរដ្ឋកម្ពុជានិយមចូលចិត្តប្រើប្រាស់សម្រាប់ការវិនិយោគលើអាជីវកម្ម ឬ ជាតម្រូវការបន្ទាន់ណាមួយដើម្បីជាឧត្តមប្រយោជន៍របស់បុគ្គលម្នាក់ៗក៏ដូចជាការជួយជម្រុញឱ្យសេដ្ឋកិច្ចកម្ពុជារីកចម្រើនថែមមួយកម្រិតទៀត។ ជាមួយគ្នានេះបើនិយាយអំពី ការបញ្ចាំជាការពិតណាស់វាមិនមែនជាសញ្ញាណថ្មីសម្រាប់កម្ពុជានោះទេដោយយើងសង្កេតឃើញថា ការបញ្ចាំមានវត្តមាននៅកម្ពុជាតាំងពីក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ ច្បាប់ភូមិបាលឆ្នាំ២០០១ រហូតដល់បច្ចុប្បន្នគឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នៅក្នុងបរិបទសង្គមកម្ពុជាទម្រង់នៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ ជាការកត់សម្គាល់និងសិក្សាស្រាវជ្រាវឃើញថាការបញ្ចាំអាចត្រូវបានបង្កើតឡើងតាមរយៈ ការដាក់បញ្ចាំអចលនវត្ថុជាលក្ខណៈឯកជន ឬការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុតាមរយៈការដាក់បញ្ចាំនៅ ហាងបញ្ចាំ ក្រុមហ៊ុន ឬសហគ្រាសដែលមានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ចនិងក្រសួងហិរញ្ញវត្ថុក្នុងការប្រកបជអាជីវកម្មទទួលបញ្ចាំអចលនវត្ថុ។ ទោះបីជាយ៉ាងនេះក្ដីច្បាប់កម្ពុជាលើកទឹកចិត្តដល់ប្រជាពលរដ្ឋគួរគប្បីធ្វើការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុជាមួយបុគ្គលដែលមាននីតិសប្បទារអនុញ្ញាតដោយច្បាប់ក្នុងការទទួលបញ្ចាំទើបជាការប្រសើរ។

ជាមួយគ្នានេះគួររំលឹកផងដែរថា ការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមានលក្ខណៈខុសប្លែកពីកិច្ចសន្យាផ្សេងៗបន្តិច ដោយតម្រូវឱ្យគូភាគីបំពេញដោយខានពុំបាន គឺ ត្រូវតែមានការផ្ទេរការកាន់កាប់អចលនវត្ថុពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំទៅម្ចាស់សិទ្ធិលើការបញ្ចាំ ហាមឃាត់ការកាន់កាប់ផ្ទាល់ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ហើយត្រូវតែបំពេញនូវលក្ខខណ្ឌគ្រឹះនិងលក្ខខណ្ឌទម្រង់ ដែលជាលក្ខខណ្ឌសុពលក្នុងការអនុវត្តកិច្ចសន្យាឱ្យមានប្រសិទ្ធិភាព។ គួរគូសបញ្ជាក់ថា ចំពោះលក្ខខណ្ឌទម្រង់ចាំបាច់ត្រូវតែធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូត ដែលធ្វើដោយមន្ត្រីមានសមត្ថកិច្ចនិងមានការចុះបញ្ជីដោយរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសុរិយោដីថ្នាក់ ស្រុក ខណ្ឌ ដែលអចលនវត្ថុនោះតាំងនៅ ព្រោះកម្មវត្ថុនៃការបញ្ចាំជាអចលនវត្ថុដែលមានការពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មនៃសិទ្ធិកាប់កាប់។ បុព្វហេតុដូច្នេះហើយ បើសិនជាការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុណាដែលធ្វើឡើងផ្ទុយពីការបញ្ញត្តដោយច្បាប់ ការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនោះមិនអាចមានសុពលភាពបានឡើយ។

ជុំវិញបញ្ហានេះភាពជាសារវន្តនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុឃើញថា ភាគីគឺជាប្រធាននៃកិច្ចសន្យាដោយសារតែភាគីជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចដែលជាសមត្ថជនមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យាដោយសុពល

តាមរយៈការបង្ហាញឆន្ទៈផ្ទាល់ខ្លួនដោយមិនមានវិការៈ។ លើសពីនេះទៅទៀតយើងអាចដឹងរួចមកហើយថា ភាគីនៅក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុអាចមានរហូតដល់បុគ្គលបីរូបគឺ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំ និងអាចមានអ្នកធានាដោយវត្ថុដែលជាភាគីនៃសិទ្ធិលើបំណុល ព្រោះនៅក្នុងករណីខ្លះដោយសារតែអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនមានវត្ថុដែលជាអចលនវត្ថុក្នុងការដាក់បញ្ចាំ ជាហេតុដែលនាំឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវមានអ្នកធានាដោយវត្ថុម្នាក់ទៀតដែលមានវត្ថុមាននៅក្នុងកិច្ចសន្យា។

មួយវិញទៀតយើងអាចមើលឃើញថាការបបង្កើសិទ្ធិលើការបញ្ចាំអចលនវត្ថុ បានផ្តល់ផលប្រយោជន៍ដល់គូភាគីទាំងសងខាង គឺទាំងភាគីអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ និងភាគីម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ ដោយភាគីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនឹងទទួលបានតម្លៃប្រាក់សមរម្យដែលអាចឱ្យភាគីអ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចទទួលយកបាន ហើយអ្នកបង្កើតសិទ្ធិលើការបញ្ចាំនឹងទទួលបានអចលនវត្ថុរបស់ខ្លួនមកវិញនៅពេលដែលខ្លួនបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅម្ចាស់សិទ្ធិលើការបញ្ចាំបានរួចរាល់។ រីឯម្ចាស់សិទ្ធិលើការបញ្ចាំវិញនឹងអាចទទួលបាននូវសិទ្ធិចំនួនពីរ ក្នុងខណៈពេលដែលខ្លួនកំពុងអនុវត្តសិទ្ធិលើការបញ្ចាំអចលនវត្ថុនោះគឺសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល។

របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា បានអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំមានអត្ថិភាព ក្នុងការទទួលបានសំណងនៃការខូចខាតតាមយៈការអនុវត្តដោយបង្ខំដោយសមត្ថកិច្ចយុត្តាធិការទៅលើអ្នកបង្កើតសិទ្ធិលើការបញ្ចាំដែលជាកូនបំណុលរបស់ខ្លួនបាន ប្រសិនបើក្នុងករណីដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអនុវត្តកាតព្វកិច្ចសងបំណុលទៅម្ចាស់បំណុល ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំទេ។

សរុបរួមមក របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុ គឺជាយន្តការផ្លូវច្បាប់មួយដែលជួយសង្គ្រោះដល់ប្រជាពលរដ្ឋកម្ពុជាមួយចំនួនដែល អលទ្ធភាពផ្នែកហិរញ្ញវត្ថុនិងត្រូវការប្រាក់បន្ទាន់ឱ្យមានលទ្ធភាពក្នុងការស្តាឡើងវិញនូវស្ថេរភាពសេដ្ឋកិច្ចគ្រួសារ ឬការពង្រីកវិសាលភាពនៃអាជីវកម្ម ឱ្យបានល្អប្រសើរជាងមុន និងអាចមានលទ្ធភាពទទួលមកវិញនូវអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំ នៅពេលដែលខ្លួនមានលទ្ធភាពក្នុងការសងបំណុលម្ចាស់សិទ្ធិលើការបញ្ចាំ។ នេះគឺជាឧត្តមប្រយោជន៍សម្រាប់កម្ពុជាទាំងមូលដែលជួយជម្រុញឱ្យសេដ្ឋកិច្ចមានការរីកចម្រើននិងមានការអភិវឌ្ឍ។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅប្រធានបទស្តីពី "របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា" យើងអាចធ្វើការកត់សម្គាល់បានថា ចំណុចជាសារវន្តនៃនីតិវិធីច្បាប់ជាច្រើនដែលមាននៅក្នុងការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមួយ ដើម្បីធ្វើឱ្យមានសុពលភាពអនុវត្តឱ្យស្របតាមមាគ៌ាក៏ដូចជាស្មារដីនៃនីតិនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាវត្តមានភាពនៃរបបគតិយុត្តនៃសិទ្ធិលើការបញ្ចាំលើអចលនវត្ថុមានរយៈកាលយូរយ៉ាងនេះក្តី ក៏នៅមានចំណុចមួយចំនួនដែលប្រជាពលរដ្ឋក៏ដូចជាមន្ត្រីខ្លះអនុវត្តខ្វះចន្លោះ និងនៅមិនទាន់មានភាពត្រឹមត្រឹមត្រូវតាមច្បាប់ទាំងស្រុងនៅឡើយ។ ដោយហេតុដូច្នេះខ្ញុំបាទសូមលើកឡើងពីភាពអសកម្មក៏ដូចជាការអនុវត្តមិនបានពេញលេញ ដែលជាចន្លោះខ្វះខាតដែលធ្លាប់បានកើតឡើងហើយក៏អាចជាសកម្មភាពដែលនៅតែបន្ត និងសូមផ្តល់អានុសាសន៍ ដើម្បីកែសម្រួលដល់ការពង្រឹង និង ពង្រីកវិសាលភាពនៃប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

ជាកិច្ចចាប់ផ្តើម ដោយខ្ញុំបាទបានសង្កេតឃើញថា ប្រជាពលរដ្ឋជាច្រើននៅមិនទាន់យល់ដឹងច្បាស់លាស់នៅឡើយអំពីនីតិវិធីនៃការបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុឱ្យបានត្រឹមត្រូវតាមច្បាប់ និងអ្វីដែលពិសេសនោះគឺមិនយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្នុងការទទួលបាននិងត្រូវអនុវត្ត។ ភាពនៃចន្លោះខ្វះខាតទាំងនោះគឺអាចមកពីការដែលមិនយល់អំពីច្បាប់ ឬ ម្យ៉ាងទៀត ដោយសារតែគូភាគីព្រមព្រៀងគ្នាដោយបំបាត់នូវធាតុសំខាន់នៃច្បាប់ដើម្បីតែផលប្រយោជន៍បន្តិចបន្តួច តែបែរជាធ្វើឱ្យមានផលពិបាកនៅពេលក្រោយ។ ដោយមើលឃើញថា កិច្ចសន្យាបញ្ចាំលក្ខខណ្ឌសុពលភាព គឺភាគីអ្នកបង្កើតសិទ្ធិលើការបញ្ចាំត្រូវតែផ្ទេរការកាន់កាប់ទៅម្ចាស់សិទ្ធិលើការបញ្ចាំ ប៉ុន្តែជាក់ស្តែងការអនុវត្តខ្លះបែរជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំផ្ទេរត្រឹមតែលិខិតដែលបញ្ជាក់ពីសិទ្ធិកាន់កាប់ ប៉ុន្តែបែរជាការគ្រប់គ្រងលើវត្ថុនៅតែត្រូវបានកាន់កាប់ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំដដែល។ នេះបានបញ្ជាក់ឱ្យយើងឃើញថា ការអនុវត្តដូច្នេះចំពោះកិច្ចសន្យាបញ្ចាំមិនអាចមានសុពលភាពបានឡើយ ហើយនៅពេលមានវិវាទអ្នកដែលខាតបង់នូវផលប្រយោជន៍គឺភាគី ព្រោះដោយសារតែមោឃៈភាពនៃកិច្ចសន្យាបញ្ចាំ។

លើសពីនេះទៅទៀត នៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាទេ ឬអលទ្ធភាពក្នុងការសងបំណុលម្ចាស់សិទ្ធិលើការបញ្ចាំ តាមផ្លូវច្បាប់ដើម្បីទទួលបាលសំណងពីសំណាក់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ គឺមានវិធីមួយដែលត្រូវបានយកមកអនុវត្ត នោះគឺការអនុវត្តលក់ដោយបង្ខំតាមរយៈសមត្ថកិច្ចយុត្តាធិការ ប៉ុន្តែការអនុវត្តមួយចំនួនកន្លងមកបានធ្វើឡើងតាមរយៈអនុវត្តលក់ដោយបង្ខំដោយខ្លួនឯងដោយមិនបានឆ្លងកាត់និតិវិធីតុលាការ។ នេះអាចមកពីការខ្វះការយកចិត្តទុកដាក់ ឬ ភាពអសកម្មពីសំណាក់មន្ត្រីដែលមានសមត្ថកិច្ច ឬ អាចមកពីការទទួលបានលាបសការៈបន្តិចបន្តួចហើយបែរជាធ្វើមិនដឹងមិន

ព្វចេះតែបណ្តែតបណ្តោយឱ្យប្រតិបត្តិបន្តបន្ទាប់រហូតដល់អ្នកដែលមិនបានសិក្សាពីច្បាប់គិតថានោះគឺជានីតិវិធីច្បាប់ទៅវិញ។

អាស្រ័យដូចដែលបានជម្រាបជូនខាងលើ ប្រសិនបើបណ្តែតបណ្តោយឱ្យសកម្មភាពទាំងអស់នោះនៅតែមានបន្តបន្ទាប់នោះអ្នកដែលទទួលរងនូវការខាងបង់គឺជាតិ ហើយអ្នកដែលរងគ្រោះគឺ អ្នកបង្កើតសិទ្ធិលើការបញ្ចាំដែលមានឋានៈជាកូនបំណុលដែលមានជីវភាពខ្សត់ខ្សោយនឹងត្រូវធ្លាក់ខ្លួនកាន់តែក្រ នោះវិសមភាពសង្គមនិងកាន់តែកើងឡើងដែលអាចជាផលវិបាកសម្រាប់ជាតិទាំងមូល។

ខ្ញុំបាទសូមធ្វើការស្នើសុំ ឱ្យស្ថាប័នដែលមានសមត្ថកិច្ចគួរពង្រឹងបន្ថែមនូវការអនុវត្តឱ្យមានភាពហ្មតចត់ជាងនេះបន្តិចចំពោះសកម្មភាពអនុវត្ត ហើយចំពោះអ្នកដែលបើកអាជីវកម្មក៏ដូចជាគ្រឹះស្ថានផ្សេងៗដែលទទួលការបញ្ចាំអចលនវត្ថុ អាចដាក់កំណត់ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំមានការបញ្ជាក់នៅក្នុងកិច្ចសន្យាឱ្យបានច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីដែលត្រូវតែមាន ដើម្បីជាសវាងការអនុវត្តខុសឆ្គងពីបញ្ញត្តិច្បាប់យ៉ាងដូច្នេះ។

សរុបរួមមក កាលណាកម្ពុជាមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ហើយការអនុវត្តធ្វើឡើងស្របតាមស្មារតីនៃច្បាប់ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ នោះតុលាការនឹងមានភាពឯករាជ្យ ការអនុវត្តច្បាប់នឹងមានយុត្តិធម៌ ពិតណាស់ថា កម្ពុជានឹងក្លាយជានីតិរដ្ឋនិងមានការអភិវឌ្ឍយ៉ាងពិតប្រាកដ។

# ឯកសារយោង

## វចនានុក្រម

– សន្ទានុក្រម នៃក្រមរដ្ឋប្បវេណី ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

– វចនានុក្រម សម្តេចព្រះសង្ឃរាជជួនណាត

## ច្បាប់ទូទៅ

– រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

– ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

– ក្រមនីតិវិធីរដ្ឋប្បវេណី ខែកក្កដា ឆ្នាំ២០០៦

## ច្បាប់ដោយឡែក

– ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១

– ច្បាប់ភូមិបាលឆ្នាំ ២០០១

– អនុក្រិត្យ លេខ១១៤ ស្តីពីការដាក់បញ្ចាំ ផ្ទេរ នូវសិទ្ធិជួលរយៈពេលវែង ឬសិទ្ធិលើដីសម្បទានសេដ្ឋកិច្ច

– ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០២៨ សហវ-ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រតិភោគដោយអនុប្បទាន

– ប្រកាសរបស់ក្រសួងយុត្តិធម៌ លេខ ៣០កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

– ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីឆ្នាំ២០១៣

## សៀវភៅ

– សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤គន្លឹ៦

– សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ៥

– សៀវភៅស្តីពី "ការពន្យល់អំពីនីតិវិធីលក់ដោយបង្ខំចំពោះអចលនវត្ថុ" បោះពុម្ពលើកទី១ ខែមករា២០១២"

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** សម្រង់បទបញ្ញត្តិពាក់ព័ន្ធក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី២៖** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគ ដោយអនុប្បទាន

**ឧបសម្ព័ន្ធទី៣៖** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០៣០ សហវ ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១៧ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន

**ឧបសម្ព័ន្ធទី៤៖** គម្រូកិច្ចព្រមព្រៀងប្រាក់កម្ចី និងដាក់បញ្ចាំអចលនវត្ថុ

**ឧបសម្ព័ន្ធទី៥៖** ប័ណ្ណកម្មសិទ្ធិដីធ្លីប្រភេទប្លង់រឹងនៅប្រទេសកម្ពុជា

**ឧបសម្ព័ន្ធទី៦៖** ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

**ឧបសម្ព័ន្ធទី៧៖** ការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ

**ឧបសម្ព័ន្ធទី៨៖** លិខិតជូនដំណឹង

**ឧបសម្ព័ន្ធទី៩៖** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា

# ឧបសម្ព័ន្ធទី១

## ជំពូកទី ៤
## សិទ្ធិលើការបញ្ចាំ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨០៦.–** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

**មាត្រា ៨០៧.–** នុបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨០៨.–** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩

(ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

**មាត្រា ៨១៩.-** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

**មាត្រា ៨២០.-** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

**មាត្រា ៨២១.-** អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

**មាត្រា ៨២២.-** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

**មាត្រា ៤២៣.–** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើខុសនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

**មាត្រា ៤២៤.–** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៤២៥.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៤២៦.–** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណី

នេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិត នៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើ សិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

**មាត្រា ៤២៧.-** ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើត សិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើត សិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

**មាត្រា ៤២៨.-** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការ អនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

## ផ្នែកទី ៣
## ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.–** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

**មាត្រា ៨៣៥.-** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

**មាត្រា ៨៣៦.-** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

**មាត្រា ៨៣៧.-** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨៣៨.-** រយៈពេលដែលមានអត្ថិភាព

១-រយៈពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីរយៈពេលនេះ រយៈពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែរយៈពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

**មាត្រា ៨៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០

លិខិតចូល

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និងកាទទួលខុសត្រូវក្រៅកិច្ចសន្យា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៨
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St 92 Sangkat Wat Phnom Khan Daun Penh Phnom Penh CAMBODIA

- បានឃើញអនុក្រឹត្យលេខ ១៣៨.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨២ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម ទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១: គោលដៅ

ប្រកាសនេះមានគោលដៅអនុវត្តចំពោះប្រតិបត្តិការខ្ចីប្រាក់ដែលមានវត្ថុដាក់ធានាជាទ្រព្យផ្សេងៗ នៅកន្លែង អាជីវកម្មស្របច្បាប់ណាមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ប្រការ២: គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធានការជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងអាជីវកម្មដើម្បី :

-កែលំអ និងតំរង់ទិសដល់ប្រតិបត្តិការអាជីវកម្ម ឱ្យអនុវត្តបានត្រឹមត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

-ការដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗ ធ្វើឡើងតាម រយៈកន្លែងអាជីវកម្មដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង និង កាត់បន្ថយបាននូវហានិភ័យមួយចំនួនដែលអាចកើតមានឡើងជាយថាហេតុ ។

-សំរួលដល់វិនិយោគិន និងប្រជាពលរដ្ឋដែលមានបំណងដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យ សម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗឱ្យទទួលបាននូវសេវាល្អប្រសើរ និងតំលៃមួយសមស្របតាមថ្លៃទីផ្សារ ។

-បង្កើនការគ្រប់គ្រងការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមតាមរយៈការត្រួតពិនិត្យ ការពារ អំពើចោរកម្មទ្រព្យសម្បត្តិ ។

-បង្កើនភាពជឿទុកចិត្តដល់អតិថិជន អាជីវករ និងអ្នកទិញទ្រព្យពីកន្លែងអាជីវកម្ម

-ធានាការទូទាត់ និងរក្សាទុកទ្រព្យដែលអាចទទួលយកបានរវាងអតិថិជន និងអាជីវករ

-បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ

ប្រការ៣: និយមន័យ

- **"ក្រសួង"** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- **"អាជីវកម្ម"** សំដៅដល់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬ អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

- **"អាជីវករ"** សំដៅដល់អ្នកទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ ដើម្បីប្រកបអាជីវកម្មឱ្យខ្ចីប្រាក់ដោយយកទ្រព្យផ្សេងៗដាក់ធានា។

- **"បញ្ចាំ"** សំដៅទៅលើការណ៍ដែលអតិថិជនដាក់នូវចលនវត្ថុ ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗ ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"ប្រាតិភោគដោយអនុប្បទាន"** សំដៅទៅលើការណ៍ដែលអតិថិជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"អតិថិជន"** សំដៅដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានដែលជា រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗទៅដាក់ធានាជាមួយនឹងអាជីវករ ដើម្បីទទួលបានប្រាក់កម្ចី ។

- **"កិច្ចសន្យា"** សំដៅដល់កិច្ចសន្យាបញ្ចាំ ឬកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលធ្វើឡើងរវាងអតិថិជនជាមួយនឹងអាជីវករលើការដាក់ទ្រព្យធានា ។

- **"កន្លែងអាជីវកម្ម"** សំដៅដល់ហាងទទួលបញ្ចាំ ឬក្រុមហ៊ុនទទួលបញ្ចាំ ឬហាងទទួលប្រាតិភោគដោយអនុប្បទាន ឬក្រុមហ៊ុនទទួលប្រាតិភោគដោយអនុប្បទានរួមមាន : អាគារ លំនៅដ្ឋាន ឃ្លាំង ឬទីកន្លែង អាជីវកម្មផ្សេងៗទៀតដែលត្រូវបានជ្រើសរើសដើម្បីធ្វើជាទីកន្លែងសម្រាប់ធ្វើអាជីវកម្ម ។

- **"ទ្រព្យ"** សំដៅដល់ទ្រព្យបញ្ចាំរួមមានចលនវត្ថុ ឬឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ និងឯកសារផ្សេងៗ ដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ និង សំដៅដល់ទ្រព្យប្រាតិភោគដោយអនុប្បទានដែលមានចលនវត្ថុជាកម្មវត្ថុយកមកដាក់ធ្វើប្រាតិភោគដោយអនុប្បទាន។

- **"អាជ្ញាប័ណ្ណ"** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **"លោះ"** គឺជាការទទួលយកមកវិញនូវទ្រព្យ ដែលបានមកពីការសងប្រាក់កម្ចីរួមទាំងការប្រាក់របស់អតិថិជន ជូនទៅអាជីវករដូចដែលមានចែងនៅក្នុងកិច្ចសន្យា។

**ប្រការ៤: ការអនុញ្ញាតធ្វើអាជីវកម្ម**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់អាចធ្វើអាជីវកម្មបានទេ ប្រសិនបើគ្មានអាជ្ញាប័ណ្ណពីក្រសួង។

**ប្រការ៥: ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ**

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ដែលកំពុងធ្វើអាជីវកម្ម ឬមានបំណងចង់ធ្វើអាជីវកម្មត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនៅក្រសួង ។

ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបានរៀបចំជូនដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៦: ថ្លៃអាជ្ញាប័ណ្ណ

អាជីវករត្រូវបង់ថ្លៃអាជ្ញាប័ណ្ណដូចខាងក្រោម :

សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

| | | |
|---|---|---|
| -អាជ្ញាប័ណ្ណថ្មីចំនួន | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| -បន្តអាជ្ញាប័ណ្ណចំនួន | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| -អាជ្ញាប័ណ្ណសាខាចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -បន្តអាជ្ញាប័ណ្ណសាខាចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |

សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

| | | |
|---|---|---|
| -អាជ្ញាប័ណ្ណថ្មីចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -បន្តអាជ្ញាប័ណ្ណចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -អាជ្ញាប័ណ្ណសាខាចំនួន | ៥០០.០០០ រៀល | (ប្រាំសែនរៀល) |
| -បន្តអាជ្ញាប័ណ្ណសាខាចំនួន | ៥០០.០០០ រៀល | (ប្រាំសែនរៀល) |

អាជីវករត្រូវបង់ប្រាក់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងខាងលើទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៧: សុពលភាព និងការបន្តសុពលភាពអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណ័មានសុពលភាពរយៈពេល ០១ ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពឱ្យបាន ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព ។

ក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬមិនបន្តអាជ្ញាប័ណ្ណប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រសួងបានកំណត់ ។

ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណមិនបន្តសុពលភាពអាជ្ញាប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយ នូវឯកសារពាក់ព័ន្ធព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុន ។

## ប្រការ៨: លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ

ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណ ជូនដល់អាជីវករទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-ជារូបវ័ន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ហើយមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬនីតិបុគ្គលមានសញ្ជាតិខ្មែរដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់

-លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយក្រសួងយុត្តិធម៌ ឬពីអាជ្ញាធរពាក់ព័ន្ធ

-បានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅក្រសួងពាណិជ្ជកម្ម

-មានអាស័យដ្ឋានស្នាក់នៅច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

-ត្រូវបង្ហាញពីកន្លែងសុវត្ថិភាពដើម្បីធានាថែរក្សា និងការការពារការខូចខាត ឬការបាត់បង់ទ្រព្យ

-សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-អាជីវករអាចដកប្រាក់តំកល់ខាងលើមកវិញបាន លុះត្រាតែមានការអនុញ្ញាតិពីក្រសួងដូចដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-ត្រូវមានលិខិតបញ្ជាក់អាស័យដ្ឋានកន្លែងអាជីវកម្មអោយបានច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន

-មានកំរិតវប្បធម៌យ៉ាងតិចបំផុតថ្នាក់បរិញ្ញាបត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនិតិសាស្ត្រ ឬវិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បំរើការងារផ្នែកនេះពីមុន ។

-មានសមត្ថភាពក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងការនិយាយ ការសរសេរ និងមានសមត្ថភាពក្នុងការរៀបចំរបាយការណ៍ដែលមានទំរង់បែបបទត្រឹមត្រូវ ។

-បង្ហាញពីម្ចាស់ភាគហ៊ុន នាយកក្រុមហ៊ុន អ្នកគ្រប់គ្រងផ្នែកផ្សេងៗ និងឈ្មោះបុគ្គលិកដែលបំរើការងារនៅក្នុងកន្លែងអាជីវកម្មអោយបានច្បាស់លាស់ ។

-បានបង់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ

-ភ្ជាប់គំរូស្លាកសញ្ញា និងត្រារបស់កន្លែងអាជីវកម្ម ព្រមទាំងហត្ថលេខារបស់អ្នកកាន់អាជ្ញាប័ណ្ណ

ការកំណត់លក្ខខណ្ឌផ្សេងទៀត អាចនឹងតម្រូវបន្ថែមដោយក្រសួង ។

## ប្រការ៩: លក្ខខណ្ឌនៃការមិនផ្តល់អាជ្ញាប័ណ្ណ

ក្រសួងមិនផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មជូនអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងឡាយណាដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ផ្តល់ព័ត៌មានមិនពិតចំពោះចំណុចណាមួយដែលមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ

-មិនបានផ្តល់ព័ត៌មានដែលខ្វះចន្លោះណាមួយដែលមានចែងក្នុងប្រការ៨ នៃប្រកាសនេះមកអោយក្រសួងក្នុង

រយៈពេល ១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) បន្ទាប់ពីមានការស្នើសុំជាលាយល័ក្ខអក្សរពីក្រសួងដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ១០: ភារកិច្ចនិងករណីយកិច្ចរបស់អាជីវករ (អ្នកកាន់អាជ្ញាប័ណ្ណ)**

អ្នកកាន់អាជ្ញាប័ណ្ណមានភារកិច្ចដូចតទៅ :

១-ត្រូវអនុវត្តគោរពតាមរាល់លិខិតបទដ្ឋានផ្សេងៗដែលចេញដោយក្រសួង

២-ត្រូវការពារ និងលើកកំពស់អត្ថប្រយោជន៍អតិថិជនរបស់ខ្លួន ហើយភារកិច្ចចំបងមួយទៀតគឺមិនត្រូវគេចវេសពីការទទួលខុសត្រូវចំពោះភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងកិច្ចការអាជីវកម្មរបស់ខ្លួនឡើយ

៣-ត្រូវមានស្លាកសញ្ញាអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាប័ណ្ណត្រូវរក្សានៅក្នុងហាង ឬក្រុមហ៊ុនដែលកំពុងប្រកបអាជីវកម្ម និងត្រូវដាក់តាំងនៅកន្លែងដែលងាយមើលឃើញ

៤-ត្រូវមានសៀវភៅចុះបញ្ជីទ្រព្យ សៀវភៅលោះទ្រព្យ និងសៀវភៅចំណូលចំណាយប្រចាំខែ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ។ ដោយទំរង់នៃសៀវភៅទាំងនោះនឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៥-ត្រូវចេញកិច្ចសន្យាឱ្យទៅអតិថិជន។ ទំរង់នៃកិច្ចសន្យានឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៦-ត្រូវសរសេរជាលាយល័ក្ខអក្សរ ដើម្បីជៀសវាងការយល់ខុសពីគ្នាទៅវិញទៅមកនូវរាល់ការលើកលែងការសន្យា និងការធានាលើសេវាជាក់លាក់ណាមួយចំពោះអតិថិជន

៧-ត្រូវពិនិត្យអោយបានល្អិតល្អន់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយ ដោយបញ្ជាក់ជូនទៅភាគីហត្ថលេខីអំពីភារកិច្ចដែលភាគីនីមួយៗត្រូវទទួលខុសត្រូវ

៨-ត្រូវរក្សាទុកទ្រព្យនៅកន្លែងមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ

៩-អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាតលើទ្រព្យដែលកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា

១០-ត្រូវផ្តល់ជូនអតិថិជននូវសេវាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់

១១-ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីមានការសង្ស័យបទល្មើសនៃអតិថិជន ឬទ្រព្យណាមួយ

១២-ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ(សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលសមត្ថកិច្ចដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មយ៉ាងយូររយៈពេល ០៧ថ្ងៃ (ប្រាំពីរថ្ងៃ) បន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យ

១៣-ត្រូវតាមដាននូវរាល់សភាពការណ៍ដែលអាចជះឥទ្ធិពលដល់លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដើម្បីផ្តល់ជាដំបូន្មានដល់អតិថិជនរបស់ខ្លួន និង/ឬដើម្បីជួយអតិថិជនក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវ

១៤-ត្រូវធានាថារាល់ការព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ត្រូវតែធ្វើឡើងជាលាយលក្ខ័អក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ ព្រមទាំងមានការបញ្ជាក់អោយបានច្បាស់លាស់នូវរាល់លក្ខខណ្ឌភារកិច្ច និង រាល់អនុសាសន៍ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា។ រាល់កិច្ចសន្យាដែលបានពិនិត្យនិងចុះហត្ថលេខា ត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ

១៥-ត្រូវធានាថារាល់ការបង្ហាញនៅក្នុងការផ្សាយពាណិជ្ជកម្មគឺជាការពិត ហើយរាល់ការផ្សព្វផ្សាយអំពីទ្រព្យ

សម្បត្តិ ឬសេវាទាំងអស់ត្រូវតែមានបញ្ជាក់ពីអត្តសញ្ញាណរបស់កន្លែងអាជីវកម្ម និងឈ្មោះបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ

១៦-ត្រូវរក្សាទុកអោយបានល្អនូវសៀវភៅកត់ត្រា ឯកសារអាជីវកម្ម និងលិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការអាជីវកម្ម

១៧-ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួន នៅនឹងច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ។ នៅថ្ងៃ ឬម៉ោងដែលប្រកាសបិទមិនធ្វើការនោះ មិនត្រូវទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយ ។ អាជីវករត្រូវជូនដំណឹងទៅក្រសួងអំពីការផ្លាស់ប្តូរពេលវេលាធ្វើការដែលបានបិទនៅលើច្រកទ្វារចេញ-ចូល

១៨-ត្រូវផ្តល់របាយការណ៍ពីប្រតិបត្តិការអាជីវកម្មដោយភ្ជាប់បញ្ជីទ្រព្យមកក្រសួងរៀងរាល់ខែ និងរៀងរាល់ដំណាច់ឆ្នាំ

១៩-មិនត្រូវផ្តល់ប្រាក់កម្ចីដល់អតិថិជន ០១ នាក់ ឬ ០១ ក្រុម លើសពី ២០% នៃដើមទុនអាជីវកម្មនោះឡើយ

២០-មិនត្រូវផ្តល់ប្រាក់កម្ចីលើសពី ២០.០០០.០០០ រៀល សំរាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ

២១-មិនត្រូវធ្វើអាជីវកម្មខុសពីឈ្មោះ ឬអាស័យដ្ឋានរបស់ខ្លួនដែលបានប្រើនៅក្នុងអាជ្ញាប័ណ្ណនោះទេ

២២-មិនត្រូវបង្កវិវាទប្បដិវាទក្នុងការធ្វើអាជីវកម្មជាមួយអាជីវករដទៃទៀតឡើយ

២៣-មិនត្រូវផ្តល់គំនិត ឬយោបល់ណាមួយដល់អតិថិជនក្រៅអំពីធុរៈកិច្ចនិងបទពិសោធន៍របស់ខ្លួនឡើយ

២៤-មិនអាចធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើអាជីវកម្ម ដោយគ្មានការជូនដំណឹងជាមុនយ៉ាងតិច ៣០ថ្ងៃ (សាមសិបថ្ងៃ) ទៅក្រសួងបានឡើយ

២៥-មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាដែលកំពុងមានជាតិស្រវឹងជោគជាំក្នុងខ្លួន ឬពីជនណាដែលខ្លួនបានសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម។

២៦-មិនត្រូវឱ្យអតិថិជនផ្តិតមេដៃលើកិច្ចសន្យា ឬកំណត់ត្រាផ្សេងៗដែលមិនទាន់បានបំពេញត្រឹមត្រូវពេញលេញនោះឡើយ

២៧-មិនត្រូវធ្វើអាជីវកម្មដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច

២៨-នៅពេលមានការស្នើសុំអោយផ្តល់យោបល់ ឬវាយតំលៃវត្ថុអ្វីមួយ អាជីវករត្រូវគិត និងធ្វើការវិភាគឱ្យបានល្អិតល្អន់នូវរាល់កត្តាដែលអាចជះឥទ្ធិពលដល់តំលៃវត្ថុត្រូវដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន មុននឹងជំរាបជូនដល់អតិថិជនរបស់ខ្លួន។

## ប្រការ១១៖ ការផ្ទេរអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណមិនអាចផ្ទេរទៅអោយអ្នកផ្សេងបានឡើយ លុះត្រាតែមានការអនុញ្ញាតពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ១២: ការផ្អាកសកម្មភាពអាជីវកម្ម និងការបញ្ឈប់អាជីវកម្ម

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់សំណើជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) មុនអាជីវកម្មត្រូវបានផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរ។ ការសំរេចលើការផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មជាសិទ្ធិរបស់ក្រសួង។

ក្រោយពីបញ្ឈប់អាជីវកម្មហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

## ប្រការ១៣: ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ

ក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណមកវិញ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តដូចករណីណាមួយដូចខាងក្រោម :

-ពុំបានអនុវត្តអោយបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសនេះឬលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួង

-ក្រោយពីទទួលបានការណែនាំពីក្រសួងព្រមទាំងទទួលពិន័យរដ្ឋបាលហើយ អ្នកកាន់អាជ្ញាប័ណ្ណនៅតែបន្តប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ

-អ្នកកាន់អាជ្ញាប័ណ្ណខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរួមមាន កាតព្វកិច្ចបង់ពន្ធ និងចំណូលផ្សេងៗជូនរដ្ឋ ចាប់ពី ០២ ខែ (ពីរខែ) ជាប់គ្នា

-ករណីកន្លែងអាជីវកម្មក្ស័យធន ឬប្រព្រឹត្តិបទល្មើសក្នុងការធ្វើអាជីវកម្មណាមួយ ក្រសួងនឹងជូនដំណឹងជាលាយលក្ខ័អក្សរ ៣០ថ្ងៃ (សាមសិបថ្ងៃ) មុន ចំពោះកន្លែងអាជីវកម្មដែលនឹងត្រូវដកហូតអាជ្ញាប័ណ្ណ និងចុះផ្សាយអោយសាធារណៈជនបានជ្រាប ឬអាចស្នើទៅតុលាការដើម្បីរឹបអូស ឬឃាត់ទុកវត្ថុដែលដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន ។

## ប្រការ១៤: ការចាត់ចែងនៅលើទ្រព្យ

-ក្នុងករណីអតិថិជនពុំមានលទ្ធភាពសងប្រាក់កម្ចី និងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសាន្ត ការចាត់ចែងលើទ្រព្យមានដូចខាងក្រោម:

+សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ទ្រព្យបញ្ចាំនឹងត្រូវចាត់ចែងតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

+សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

-ក្នុងករណីអតិថិជនបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យា នោះអាជីវករត្រូវប្រគល់ទ្រព្យទៅឱ្យអតិថិជនវិញភ្លាម ។

អាជីវករមិនមានសិទ្ធិលក់ ផ្ទេរ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យអោយទៅអ្នកផ្សេងក្នុងកំឡុងពេលដែលទ្រព្យនេះកំពុងជាប់កិច្ចសន្យា លុះត្រាតែមានការឯកភាពពីអតិថិជន។

### ប្រការ១៥: ការកំណត់អត្រាការប្រាក់ និង រយៈពេលបញ្ចាំ

-អត្រាការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរវាងអាជីវករ និងអតិថិជន។ ប៉ុន្តែការព្រមព្រៀងលើអត្រាការប្រាក់នេះមិនត្រូវអោយផ្ទុយពីច្បាប់កំណត់នោះឡើយ ។

-កិច្ចសន្យាមានរយៈពេលយ៉ាងយូរត្រឹម ០៤ ខែ (បួនខែ) ចាប់ពីថ្ងៃបរិច្ឆេទនៃការដាក់ទ្រព្យ និងអាចបន្តសុពលភាពបាន ។

### ប្រការ១៦: ការបង់កិច្ចពន្ធលើអាជីវកម្ម

អាជីវករត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ប្រការ១៧: ការបង្កើតសាខា

អាជីវករអាចបង្កើតសាខាបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយត្រូវសុំអាជ្ញាប័ណ្ណសម្រាប់សាខាអាជីវកម្មដោយបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងនៅក្នុងប្រការ ៨ នៃប្រកាសនេះ។

### ប្រការ១៨: របាយការណ៍អាជីវកម្មប្រចាំខែ

អាជីវករត្រូវផ្តល់ស្ថិតិ និងរបាយការណ៍អាជីវកម្មប្រចាំខែមកក្រសួងមិនអោយលើសពី ១៥ថ្ងៃ នៃខែ បន្ទាប់។ ស្ថិតិ និងរបាយការណ៍នោះត្រូវបញ្ជាក់ថាពិត និងត្រឹមត្រូវដោយអ្នកកាន់អាជ្ញាប័ណ្ណ ។

### ប្រការ១៩: របាយការណ៍អាជីវកម្មប្រចាំឆ្នាំ

ក្នុងរយៈពេល ០៣ ខែ (បីខែ) ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ អាជីវករត្រូវផ្តល់ឱ្យក្រសួងនូវរបាយការណ៍អាជីវកម្ម នៃឆ្នាំសារពើពន្ធកន្លងមក ។

### ប្រការ២០: ការត្រួតពិនិត្យបញ្ជី

ក្រសួងអាចចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មតាមការចាំបាច់ ។ អាជីវករត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ។

### ប្រការ២១: ការដាក់ពិន័យរដ្ឋបាល

អាជីវករទាំងឡាយណាដែលល្មើសទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាដែលមានចែងក្នុងប្រកាសនេះនឹងត្រូវទទួលទណ្ឌកម្មដូចជា ទទួលការដាក់ពិន័យ ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ ដូចមានចែងនៅក្នុងសៀវភៅបន្ទុក។ ក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិប្តឹងទៅតុលាការដើម្បីអនុវត្តទណ្ឌកម្មខាងលើ ។

### ប្រការ២២: ការអនុវត្តតាមសៀវភៅបន្ទុក

អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅបន្ទុក ស្តីពីលក្ខខណ្ឌអនុវត្តអាជ្ញាប័ណ្ណសំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

### ប្រការ២៣: អវសានប្បញ្ញត្តិ

បទប្បញ្ញត្តិ ឬ លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

## ប្រការ២៤: ការអនុវត្តប្រកាស

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កន្លែងអាជីវកម្ម និងបុគ្គលដែលពាក់ព័ន្ធ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

## ប្រការ២៥: សុពលភាពនៃការអនុវត្តប្រកាស

ប្រកាសនេះមានតំលៃអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
  " ដើម្បីជូនជ្រាប និងសហការអនុវត្ត "
- ដូចមានក្នុងប្រការ ២៤
  " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០៣៣០......សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលទ្រព្យគោកដោយអនុប្បទាន

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- **អ្នកទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យប្រាតិភោគដោយអនុប្បទានពីក្រសួង/ មន្ទីរ
- **អ្នកដាក់បញ្ចាំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំជាមួយអ្នកទទួលបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី
- **អ្នកដាក់ប្រាតិភោគដោយអនុប្បទាន** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់ប្រាតិភោគដោយ-អនុប្បទានជាមួយអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចី
- **ទ្រព្យ** សំដៅដល់ចលនវត្ថុ ឬអចលនវត្ថុដែលជាកម្មវត្ថុយកទៅដាក់បញ្ចាំ
- **លោះ** សំដៅដល់ការទទួលយកមកវិញនូវទ្រព្យដែលបានដាក់បញ្ចាំ ឬដែលបានដាក់ប្រាតិភោគដោយអនុប្បទានក្រោយពីបានសងប្រាក់ដើម (ប្រាក់កម្ចី) និងការប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យាដែលបានកំណត់ជូនទៅអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទានវិញ
- **កិច្ចសន្យា** សំដៅដល់កិច្ចសន្យាទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទានដែលធ្វើឡើងរវាងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករក្នុងការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយ-អនុប្បទាន។ ក្រសួងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញតួនាទី និងភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិ-ការរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និង/ឬ ទទួលប្រាតិភោគដោយអនុប្បទាន

**ប្រការ៦.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០%នៃដើមទុន
- អ្នកកាន់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលទ្រព្យបញ្ចាំ
- បង្កើតឱ្យមានប្រព័ន្ធផ្តត់ផ្គង់សាច់ប្រាក់ឆាប់រហ័សដោយស្របច្បាប់ក្រៅពីប្រព័ន្ធធនាគារ
- រួមចំណែកទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដើម្បីធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់ យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយ-អនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ពាក្យបច្ចេកស័ព្ទដែលបានប្រើនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គ-នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតតតិយុត្តិដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **លិខិតអនុញ្ញាតប្រកបអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅក្នុងព្រះរាជាណា-ចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **អាជីវកម្មទទួលបញ្ចាំ** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនយកទ្រព្យទៅដាក់បញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនធ្វើអនុប្បទានសិទ្ធិលើចលនវត្ថុ របស់ខ្លួនជូនដល់អ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អ្នកទទួលបញ្ចាំ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យបញ្ចាំពីក្រសួង/មន្ទីរ

- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងពាក្យស្នើសុំអាជ្ញាបណ្ណរបស់ក្រសួង។

**ប្រការ៧.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចត្រូវមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំស្នើសុំរបស់មន្ទីរ។

**ប្រការ៨.-**

ក្រសួង/មន្ទីរមានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬបន្តសុពលភាពជូនក្រុមហ៊ុន/សហគ្រាសគិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញ និងគ្រប់ចំនួន។

**ប្រការ៩.-**

ដើមទុនសម្រាប់ប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ដូចខាងក្រោម÷

**ក- អាជីវកម្មទទួលបញ្ចាំរួមមាន÷**

- ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម : ត្រូវមានដើមលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

**ខ- អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរួមមាន÷**

- ខ្នាតតូច : ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល
- ខ្នាតមធ្យម : ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល
- ខ្នាតធំ (កម្រិត១) : ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល
- ខ្នាតធំ (កម្រិត២) : ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន។

**ប្រការ១០.-**

ប្រភេទ ខ្នាត ថ្លៃ និងសុពលភាពអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងត្រូវបានកំណត់ដូចខាងក្រោម÷

| លរ | ប្រភេទ | | ថ្លៃអាជ្ញាបណ្ណថ្មី/បន្ត | សុពលភាព |
|---|---|---|---|---|
| -អាជីវកម្មទទួលបញ្ចាំ | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ២.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៣.០០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ៤.០០០.០០០រៀល/០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ១.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/០១ឆ្នាំ | |
| -អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | | | | |
| ១ | អាជ្ញាបណ្ណ | ខ្នាតមធ្យម | ១.០០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ១.៥០០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ២.០០០.០០០រៀល/០១ឆ្នាំ | |
| ២ | អាជ្ញាបណ្ណសាខា | ខ្នាតមធ្យម | ៥០០.០០០រៀល/០១ឆ្នាំ | ០៣ឆ្នាំ |
| | | ខ្នាតធំ (កម្រិត១) | ៧៥០.០០០រៀល/០១ឆ្នាំ | |
| | | ខ្នាតធំ (កម្រិត២) | ១.០០០.០០០រៀល/០១ឆ្នាំ | |

ថ្លៃអាជ្ញាបណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាបណ្ណដូចមានចែងក្នុងប្រការនេះត្រូវបង់រៀងរាល់០១ (មួយ) ឆ្នាំម្តងទៅក្នុងគណនីទោលរបស់រតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យបាន៣០ ថ្ងៃមុន នៃឆ្នាំបន្ទាប់។

**ប្រការ១១.-**

ប្រភេទ ថ្លៃ និងសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូច ដែលចេញដោយមន្ទីរត្រូវបានកំណត់ដូចខាងក្រោម÷

| លរ | ប្រភេទ | | ថ្លៃលិខិតអនុញ្ញាតថ្មី/ បន្ត | សុពលភាព |
|---|---|---|---|---|
| -អាជីវកម្មទទួលបញ្ចាំ | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ១.០០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| -អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | | | | |
| ១ | លិខិតអនុញ្ញាត | ខ្នាតតូច | ៥០០.០០០រៀល | ០១ឆ្នាំ |
| ២ | លិខិតអនុញ្ញាតសាខា | ខ្នាតតូច | ២៥០.០០០រៀល | ០១ឆ្នាំ |

ថ្លៃលិខិតអនុញ្ញាតប្រកបអាជីវកម្មដូចមានចែងក្នុងប្រការនេះ ត្រូវបង់ចូលគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិ នៃកម្ពុជានៅបណ្តារាជធានី-ខេត្ត តាមដីកាអមរបស់មន្ទីរសាមីរាជធានី-ខេត្ត នោះ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យបាន ៣០ ថ្ងៃមុនលិខិតអនុញ្ញាតនោះផុតសុពលភាព និងត្រូវបង់ថ្លៃបន្តសុពលភាពដូចមានចែងក្នុងប្រការនេះ។

**ប្រការ១២.-**

ក្រុមហ៊ុន/ សហគ្រាស អាចបង្កើតសាខាបានលុះត្រាតែមានអាជ្ញាបណ្ណពីក្រសួង/ លិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។

ដើម្បីបើកសាខាបានក្រុមហ៊ុន/ សហគ្រាសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ និងប្រការ ៧នៃប្រកាសនេះ។

## ជំពូកទី៤

## កិច្ចដំណើរការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន

### ផ្នែកទី១

### ភារកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ១៣.-**

**អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មមានភារកិច្ចដូចខាងក្រោម÷**

- ត្រូវទទួលខុសត្រូវចំពោះអតិថិជនដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន
- ត្រូវមានស្លាកយីហោអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់បង្ហាញនៅកន្លែងដែលងាយមើលឃើញ
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះ អាសយដ្ឋានដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ត្រូវមានកិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងត្រូវថែរក្សាទុកដាក់ឱ្យបានល្អ។ ទម្រង់កិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តការអាជីវកម្មនឹងមានផ្តល់ជូនដោយក្រសួង
- រាល់កិច្ចសន្យាដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន ព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បរមា លក្ខខណ្ឌ រយៈពេលកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៦ និងភារកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានការចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យា
- ត្រូវរក្សាទុកទ្រព្យបញ្ចាំ និង/ ឬប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា
- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងករណីមានការសង្ស័យចំពោះអតិថិជន ឬទ្រព្យណាមួយដែលពាក់ព័ន្ធនឹងបទល្មើស
- ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងរយៈពេល០៧ (ប្រាំពីរ )ថ្ងៃយ៉ាងយូរបន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យបញ្ចាំ និង/ ឬទ្រព្យប្រាតិភោគដោយអនុប្បទាន
- ត្រូវធានាថារាល់ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន/ សហគ្រាសត្រូវតែជាការពិត និងមានការបញ្ជាក់ពីអត្តលេខក្រុមហ៊ុន/ សហគ្រាស

## ផ្នែកទី ៣
## អត្រាការប្រាក់ និងរយៈពេលនៃការដាក់បញ្ញើ និង/ឬប្រាតិភោគដោយអនុប្បទាន

**ប្រការ១៦.-**

អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរវាងអ្នកទទួលបញ្ញើ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន និងអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងត្រូវអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ដែលនៅជាធរមាន។

កិច្ចសន្យានេះមានសុពលភាពអនុវត្តយ៉ាងយូរត្រឹម០៤ (បួន) ខែ ចាប់ពីកាលបរិច្ឆេទនៃការដាក់ទ្រព្យបញ្ញើ ឬដាក់ទ្រព្យប្រាតិភោគដោយអនុប្បទាន និងអាចបន្តសុពលភាពសារជាថ្មីបាន។

## ផ្នែកទី ៤
## ការចាត់ចែងទ្រព្យ

**ប្រការ១៧.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន/សហគ្រាសត្រូវប្រគល់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានទៅឱ្យអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានវិញភ្លាម។

**ប្រការ១៨.-**

ក្រុមហ៊ុន/សហគ្រាស ពុំមានសិទ្ធិលក់ ផ្ទេរ ប្រើប្រាស់ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគ-ដោយអនុប្បទាន ឱ្យទៅបុគ្គលផ្សេងទៀតក្នុងអំឡុងពេលដែលទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទាននោះកំពុងជាប់កិច្ចសន្យា ដោយពុំមានការឯកភាពពីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានឡើយ។

**ប្រការ១៩.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានពុំមានលទ្ធភាពសងប្រាក់កម្ចីនិងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសាន្តការចាត់ចែងលើទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានមានដូចខាងក្រោម÷

- **សម្រាប់អាជីវកម្មទទួលបញ្ញើ÷**ទ្រព្យបញ្ញើត្រូវចាត់ចែងអនុលោមតាមនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សម្រាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន÷**ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៥
## ការផ្លាស់ប្តូរទីតាំង នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ២០.-**

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវមានការឯកភាពជាមុនពីក្រសួង/មន្ទីរ។

ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរមុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ឬមន្ទីរ ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ ឬរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

- ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ និងមិនត្រូវមានប្រតិបត្តិការទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយក្រៅពីថ្ងៃ ឬម៉ោងដែលបានប្រកាសបិទមិនធ្វើការ
- ត្រូវផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដូចមានចែងក្នុងប្រការ២៩នៃប្រកាសនេះ ដោយត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវដោយនាយកក្រុមហ៊ុន/ សហគ្រាស
- ត្រូវបំពេញកាតព្វកិច្ចពន្ធដារឱ្យបានត្រឹមត្រូវដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬមកក្រសួង/មន្ទីរក្នុងករណីសង្កេតឃើញសកម្មភាពណាមួយដែលបម្រើដល់ការលាងសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬបទល្មើសភេរវកម្មណាមួយ
- ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន។

**ប្រការ១៤.-**

ក្រុមហ៊ុន/ សហគ្រាសត្រូវបានហាមឃាត់សកម្មភាពអាជីវកម្មមួយចំនួនដូចខាងក្រោម÷

- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈមិនពិត ឬឆបោក ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាមួយដែលកំពុងឋិតក្នុងភាពស្រវឹងជោគជាំ ជនវិប្បល្លាសស្មារតី ឬពីជនណាមួយដែលសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម
- មិនត្រូវបង្កវាទប្បដិវាទក្នុងការធ្វើអាជីវកម្មជាមួយអ្នកទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានដទៃទៀត
- មិនត្រូវចូលរួម ឬធ្វើអាជីវកម្ម ដើម្បីបម្រើដល់សកម្មភាពលាងសម្អាតប្រាក់ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ
- មិនត្រូវទទួលយកទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានណាដែលពុំមានឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណទ្រព្យច្បាស់លាស់
- មិនត្រូវធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- មិនត្រូវទទួលយកទ្រព្យណាមួយដែលច្បាប់ហាមឃាត់។

## ផ្នែកទី ២
## ការផ្តល់ប្រាក់កម្ចី

**ប្រការ១៥.-**

ចំពោះក្រុមហ៊ុន/ សហគ្រាស ដែលទទួលបានអាជ្ញាបណ្ណពីក្រសួង ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬដល់អ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំ។

ចំពោះក្រុមហ៊ុន/ សហគ្រាស ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំនោះ។

**ប្រការ២១.-**

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុននិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវផ្តល់ឯកសារដូចខាងក្រោម÷

**ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម និងជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជនឱ្យបានរួចរាល់

**ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរនាមករណ៍ ឬលិខិតសម្រេចរបស់នាយកក្រុមហ៊ុន/សហគ្រាស
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍

**គ. ការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាលដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរភាគទុននិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុននិក
- លិខិតថ្កោលទោសឬលិខិតបញ្ជាក់កិរិយាមារយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច

**ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ/អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះចំពោះអ្នកកាន់អាជ្ញាបណ្ណ។
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ ចំពោះអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ២៦.-**

នៅក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឯកសារតម្រូវផ្សេងៗក្រសួង/មន្ទីរ ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន/សហគ្រាសដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី៦
## ការត្រួតពិនិត្យ និងរបាយការណ៍

**ប្រការ២៧.-**

ក្រសួង/មន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យជាក់ស្ដែងដល់ទីកន្លែងដើម្បីធានាដល់ការអនុវត្តប្រកាសនេះ។

**ប្រការ២៨.-**

មន្ទីរត្រូវផ្ដល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

-របាយការណ៍ប្រចាំត្រីមាសស្ដីពីសកម្មភាពអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនថ្ងៃទី១៥ នៃត្រីមាសបន្ទាប់

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំសារពើពន្ធ។

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលនាយកដ្ឋានបានផ្ដល់ជូន។

**ប្រការ២៩.-**

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវផ្ដល់ជូនក្រសួង/មន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រតិបត្តិការអាជីវកម្មប្រចាំខែមិនឱ្យលើសពីថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យលើសពីត្រីមាសទី១ នៃឆ្នាំបន្ទាប់

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់តាមគំរូដែលកំណត់ដោយក្រសួង។

**ប្រការ៣០.-**

ក្រសួង/មន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីរកឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មដែលផ្ដល់ដោយក្រុមហ៊ុន/សហគ្រាស ដោយរាល់ការចំណាយលើសវនករឯករាជ្យជាបន្ទុករបស់ក្រុមហ៊ុន/សហគ្រាស។

## ជំពូកទី៧
## ការផ្សះផ្សា និងដោះស្រាយវិវាទ

**ប្រការ៣១.-**

វិវាទរវាងក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានជាមួយក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ឬជាមួយអ្នកដាក់បញ្ចាំ/អ្នកដាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋាន/មន្ទីរ។

ក្រសួង/មន្ទីរសម្រុះសម្រួល និងផ្សះផ្សាវិវាទតាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល០២ខែយ៉ាងយូរ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន/មន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះគូភាគី។

## ផ្នែកទី ៦
## ប្រាក់តម្កល់ធានាអាជីវកម្ម

**ប្រការ២២.-**

ក្រុមហ៊ុន/សហគ្រាស ខ្នាតមធ្យម និងខ្នាតធំត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០ % (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

ក្រុមហ៊ុន/សហគ្រាសខ្នាតតូច ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០% (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិនៃកម្ពុជាតាមដីកាអមរបស់មន្ទីរសាមីនោះ។

ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើអាចដកវិញបានក្រោយពីក្រុមហ៊ុន/សហគ្រាសបានបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ហើយត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៥ ។

**ប្រការ២៣.-**

នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់ និងឯកសារតម្រូវផ្សេងៗ ក្រសួងត្រូវចេញលិខិតអនុញ្ញាតឱ្យដក ឬលិខិតបដិសេធដកប្រាក់តម្កល់នោះ ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី ៥
## ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

**ប្រការ២៤.-**

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុន/ សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/ មន្ទីរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្អាកដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់សារពើពន្ធ
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ចស្តីពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារពាក់ព័ន្ធការជម្រះបញ្ជីជាមួយអតិថិជនដែលដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទាន

ក្រសួង/មន្ទីរអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្នយ៉ាងយូរត្រឹម៤ (បួន) ខែ ក្នុង១ (មួយ) ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលនៅសល់តែប៉ុណ្ណោះ។

**ប្រការ២៥.-**

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/ មន្ទីរ មុនបញ្ឈប់សកម្មភាពអាជីវកម្ម និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម÷

- លិខិតស្នើសុំបញ្ឈប់អាជីវកម្មដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- អាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវដែលចេញដោយអាជ្ញាធរពន្ធដារមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាតតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម និងការជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជន
- បង្កាន់ដៃបង់ប្រាក់តម្កល់ធានាអាជីវកម្ម។

**ប្រការ៣២.-**

ក្រុមហ៊ុន/សហគ្រាស ឬអ្នកដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទានដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង/មន្ទីរមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល៩០ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអញ្ជើញភាគីពាក់ព័ន្ធវិវាទដើម្បីសាកសួរ ឬផ្តល់ភស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីអង្គហេតុសំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**ប្រការ៣៣.-**

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មទទួលបញ្ញើ និងទទួលប្រាតិភោគដោយអនុប្បទាន គ្មានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាព
- ប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរ
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូន
- អនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ
- មិនបានផ្តល់ ឬផ្តល់របាយការណ៍យឺតយ៉ាវតាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង។

**ប្រការ៣៤.-**

ក្រុមហ៊ុន/សហគ្រាសទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មបណ្តោះអាសន្នពី០៦ ខែទៅ១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ

- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់ជាធរមាន។

**ប្រការ៣៥.-**

ក្រសួង/មន្ទីរមានសិទ្ធិព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្ត ល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាក្រោយពីទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ
- បន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះក្រោយពីទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

**ប្រការ៣៦.-**

ក្រសួង/មន្ទីរ មានសិទ្ធិដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាចាប់ពី០៦ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ ហើយនៅតែមិនរៀងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធលើសពី០៦ ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពលើសពី០៣ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយនៅតែបន្តប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទៀត
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះលើសពី០៥ ករណីឡើងទៅ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មលើសពី០៣ ខែ ក្រោយពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាលើសពី០២(ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ហើយ
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៩ និងប្រការ២៥ នៃប្រកាសនេះក្រោយពីអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវបានព្យួររួចហើយ
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួង/មន្ទីរ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន៣០ (សាមសិប) ថ្ងៃមុននឹងដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រុមហ៊ុន/សហគ្រាសដែលបានប្រព្រឹត្តខុស។

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល៣០ថ្ងៃមុន លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់)រៀល ក្នុង០១ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ត្រូវគុណទ្វេដង។

**ប្រការ៤៣.-**

ការបង្កើតសាខាដោយគ្មានអាជ្ញាបណ្ណពីក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង០១សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាខានោះ។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសមេ។

ការបង្កើតសាខាដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀលក្នុង០១ សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សាខានោះ។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/ សហគ្រាសមេ។

**ប្រការ៤៤.-**

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន២.០០០.០០០ (ពីរលាន) រៀលក្នុង០១ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរ ឬដកហូតអាជ្ញាបណ្ណនោះ។

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មនោះ។

**ប្រការ៤៥.-**

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ អ្នកកាន់អាជ្ញាបណ្ណនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន៤០០.០០០ (បួនរយពាន់) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីមន្ទីរចំនួន២០០.០០០ (ពីររយពាន់)រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

**ប្រការ៤៦.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០(ពីរលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៧.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់ហើយត្រូវបំពេញឯកសារស្នើសុំ។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៣៧.-**

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន១០.០០០.០០០ (ដប់លាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទាន ដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០(ប្រាំលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបានក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មមកមន្ទីរ។

**ប្រការ៣៨.-**

ការក្លែងបន្លំអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

**ប្រការ៣៩.-**

ការប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវប្រញាប់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលក្រសួងនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ការប្រើប្រាស់លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល និងត្រូវប្រញាប់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលមន្ទីរនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

**ប្រការ៤០.-**

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០(មួយលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤១.-**

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ៤២.-**

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១០ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០(ម្ភៃពាន់) រៀល ក្នុង ០១ ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលចំនួនទឹកប្រាក់ផាកពិន័យត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៨.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

## ជំពូកទី០៩

## អន្តរប្បញ្ញត្តិ

**ប្រការ៤៩.-**

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**ប្រការ៥០.-**

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែ មករា ឆ្នាំ២០១៧

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៨.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

## ជំពូកទី០៩
## អន្តរប្បញ្ញត្តិ

**ប្រការ៤៩.-**

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**ប្រការ៥០.-**

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ</u>

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ក" ម្ចាស់ប្រាក់** ។

និង

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ............ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង..................... ហៅកាត់ថា **ភាគី"ខ" ជាអ្នកខ្ចីប្រាក់** ។

***ភាគី"ក" និងភាគី"ខ" បានព្រមព្រៀង តាមប្រការដូចខាងក្រោម:***

<u>ប្រការ១:</u> ភាគី"ក" យល់ព្រមឲ្យភាគី"ខ" ខ្ចីប្រាក់ចំនួន.....................ដុល្លារ (...........................................)
ភាគី"ខ"បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី ។

<u>ប្រការ២:</u> ភាគី"ខ" យល់ព្រមបង់ការប្រាក់ឲ្យភាគី"ក" ហើយភាគី"ក" យល់ព្រមទទួលការប្រាក់ពី ភាគី"ខ" ក្នុងអត្រាព្រមព្រៀង............ភាគរយ ក្នុង១ខែ ស្មើនឹង..................(.....................................................) នៃប្រាក់ដែលបានខ្ចី។ រយៈពេល..................................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី..........ខែ........... ឆ្នាំ.......... រហូតដល់ថ្ងៃទី..........ខែ..........ឆ្នាំ...........។

<u>ប្រការ៣:</u> ភាគី"ខ" យល់ព្រមបង់ការប្រាក់ឲ្យ ភាគី"ក" នៅថ្ងៃទី............រៀងរាល់ខែនីមួយៗ ។ ភាគី"ក" យល់ព្រមឲ្យភាគី"ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណាមួយ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី"ខ" មានបំណងបង់ចេញសងនូវទាំងប្រាក់ដើមនិងការប្រាក់ផង ។ ក្នុងករណីភាគី"ខ" ពុំបានបង់ការក្នុងរយៈពេល<u>**០៣ខែជាប់ៗគ្នានោះ**</u> ភាគី"ខ"យល់ព្រមឲ្យភាគី"ក" ប្រើសិទ្ធិរបស់ខ្លួនក្នុងការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបានដោយឯកតោភាគី ។

ភាគី"ខ"បានយល់ព្រមថា ករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ០៣ខែ អនុញ្ញាតឲ្យភាគី"ខ" រឹបអូសយកផ្ទះ និងដីដែលបានដាក់បញ្ចាំឲ្យភាគី"ខ" រួចចុះចេញពីផ្ទះ និងដី ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

ប្រការ៤: យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី "ខ" បានដាក់អចលនទ្រព្យធានាមានដូចជា:

| ល.រ | ប្រភេទទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.........................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង................................ ។ | | |

ប្រការ៥: កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ ម្នាក់ មេធាវី ០១ច្បាប់ ។

ប្រការ៦: កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ............... ថ្ងៃទី.........ខែ..........ឆ្នាំ...........

ភាគី "ខ" សាក្សីភាគី "ខ" សាក្សីភាគី "ក" ភាគី "ក"

ឈ្មោះ........................ ឈ្មោះ........................ ឈ្មោះ........................ ឈ្មោះ........................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ............ថ្ងៃទី........ខែ.........ឆ្នាំ.........

មេធាវី

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 12010604-0005

រាជធានី/ខេត្ត : ភ្នំពេញ
ក្រុង/ស្រុក/ខណ្ឌ : ចំការមន
ឃុំ/សង្កាត់ : ទួលស្វាយព្រៃទី ១
ភូមិ : ៤

សន្លឹកផែនទីលេខ : 5932-II 94 b 4
លេខក្បាលដី : 5
ទំហំ : 107 ម²
ប្រភេទដី :
ប្រភេទការប្រើប្រាស់ដី : លំនៅឋាន
លក្ខណៈនៃការប្រើប្រាស់ដី : ឯកជន




មាត្រដ្ឋាន 1/800

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០...

## កំរូសន្លឹកបណ្ណចាស់

No. 3176097

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 12010604-0005

រាជធានី/ខេត្ត : ភ្នំពេញ
ក្រុង/ស្រុក/ខណ្ឌ : ចំការមន
ឃុំ/សង្កាត់ : ទួលស្វាយព្រៃទី ១
ភូមិ : ៤

សន្លឹកផែនទីលេខ : 5932-II 94 ៦ 4
លេខក្បាលដី : 5
ទំហំ : 107 ម²
ប្រភេទដី :
រូបភាពប្រើប្រាស់ដី : លំនៅឋាន
លក្ខណៈនៃការប្រើប្រាស់ដី : ឯកជន




ថ្ងៃ ខែ ឆ្នាំ ព.ស.២៥...

មាត្រដ្ឋាន 1/600

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០...

គំរូសន្លឹកប័ណ្ណថ្មី

[illegible] [illegible] [illegible] [illegible] [illegible]

[illegible] [illegible] [illegible] [illegible]

[illegible]

| [illegible] | | | [illegible] | | 12070111-0388 |
|---|---|---|---|---|---|
| [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| [illegible] | [illegible] | | [illegible] | | |
| | | | | | |

លេខ : [redacted]

អក្សរសញ្ញាខ្ទង់ ...គ៣៧...........................

| ភិនភាគក្បាលដី | | | | អត្រានុកូលដ្ឋានអ្នកកាន់កាប់ | | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទដី | ទំហំ | | | នាមត្រកូល និងនាមខ្លួន ទាំងប្តី ប្រពន្ធ | ថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើត | សាវ័ពារ | សញ្ជាតិ | លេខចារិកដោយសង្ខេបនៃលិខិតសញ្ញា និងសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| | ហ | អ | ស | | | | | | | |
| សាងសង់ | ០០ | ០១ | ៦៨ | [redacted] | [redacted] | [redacted] | ខ្មែរ | [redacted] | | |
| | | | | [redacted] | [redacted] | [redacted] | ខ្មែរ | | | |
| | | | | [redacted] | [redacted] | [redacted] | ខ្មែរ | | | |

# ឧបសម្ព័ន្ធទី៦

ក្រដាសពុម្ពលេខ.៥

ឈ្មោះដី : ........................ ឈ្មោះភូមិ ភ្នំបាក់

ព្រំប្រទល់ :

ខាងជើង : នួន ស្ទឹង, ឌីណា ប៊ុនហួរ, ទីទូច ឡូត, ល្បៀក ធីតូ

ខាងត្បូង : ឌីណា ប៊ុនហួរ, ឃុយ លាយ, ឡឿន សុខា, នួន

ខាងកើត : ឃុយ លាយ, ប៊ុន ឡេង, ងិន ច័ន្ទឌី, ហ៊ុ សំណាង, ឈិន ទី

ខាងលិច : ទីទូច ឡូត, ពុំ ភុន, ល្បៀក ធីតូ, នួន

សិរីសោភ័ណ, ថ្ងៃទី 10 ខែ មិថុនា ឆ្នាំ 2014

ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ : ប.ជ 009018

ឃុំ-សង្កាត់ : ទឹកថ្លា

ក្រុង-ស្រុក-ខណ្ឌ : សិរីសោភ័ណ

រាជធានី-ខេត្ត : បន្ទាយមានជ័យ

បន្ទាយមានជ័យ, ថ្ងៃទី 12 ខែ មិថុនា ឆ្នាំ 2014

ត.ប រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី

# ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ទៅក្រុមបន្ទប់ [redacted]

លេខ៖ [redacted] "[redacted].ស.ល

ចុះថ្ងៃទី [redacted]

## ការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ

យើង [redacted] ក្រឡាបញ្ជីនៃដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៤៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ ដីកាសម្រេចបង្គាប់ឱ្យអនុវត្តការលក់លេខ "ខ៩" ស.វ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ។

**សូមប្រកាសថា៖**

ចំពោះរឿងក្តីអនុវត្តដោយបង្ខំលេខ០៦៩ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ លើអចលនវត្ថុ គឺផ្ទះវីឡា ទំហំ ៤៤២ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ [redacted] សង្កាត់បឹង [redacted] ខណ្ឌ [redacted] រាជធានី [redacted] មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 1[redacted] ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted] ចេញដោយមន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

តុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុតាមវិធីដូចខាងក្រោម៖

**គឺ៖**

-វិធីលក់ ៖ លក់ឡាយឡុងដោយស្រោមសំបុត្រ

-កាលបរិច្ឆេទនៃការលក់ ៖ [redacted]ព្រឹក

-ទីកន្លែងលក់ ៖ [redacted]:អធិបតី)

-តម្លៃលក់អប្បបរមា ៖ [redacted]) ដុល្លារអាមេរិក

-ប្រាក់ធានាលើសំណើរទិញ [redacted]) ដុល្លារអាមេរិក

-វិធីផ្តល់ប្រាក់ធានាលើសំណើរទិញ៖ ដោយប្រាក់សុទ្ធ ឬដោយមូលប្បទានប័ត្រ

-អំឡុងពេលសម្រាប់ឱ្យសាធារណៈជនមើលសំណុំ "ឯកសារលំអិត" និងរបាយការណ៍ស្តីពីការវាយតម្លៃជាអាទិ៍៖ គិតចាប់ពីថ្ងៃទី [redacted] ។

កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ៖ ថ្ងៃ[redacted] ។

ថ្ងៃច័ន្ទ [redacted]កើត ខែ[redacted] ឆ្នាំជូត ទោស័ក ព.ស [redacted]

រាជធានីភ្នំពេញ ថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ២[redacted]

ក្រឡាបញ្ជី

[redacted]

# ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ទៅក្រមបន្ទប់ [redacted]

លេខ៖ [redacted] [redacted]

[redacted]១

## <u>លិខិតជូនដំណឹង</u>

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ចំពោះរឿងក្តីអនុវត្តដោយបង្ខំលេខ [redacted] លើអចលនវត្ថុ ដីនិងផ្ទះវីឡា ទំហំ [redacted] មានទីតាំងស្ថិតនៅ[redacted] សង្កាត់[redacted] ខណ្ឌចំការមន រាជធានី[redacted] មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ [redacted] ចុះថ្ងៃ[redacted] ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

សូមជម្រាបជូនដំណឹងដល់ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធទាំងអស់ឲ្យបានជ្រាបថា តុលាការនឹងអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុខាងលើ តាមវិធីដូចខាងក្រោម ៖

គោល៖

- -វិធីលក់ ៖ លក់ឡាយឡុងដោយស្រោមសំបុត្រ
- -កាលបរិច្ឆេទនៃការលក់ ៖ [redacted]
- -ទីកន្លែងលក់ ៖ [redacted])
- -កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ ៖ **ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ។**
- -តម្លៃលក់អប្បបរមា ៖ USD [redacted]) ដុល្លារអាមេរិក

ថ្ងៃច័ន្ទ [redacted]កើត ខែ[redacted] ឆ្នាំ[redacted] ទោស័ក ព.ស [redacted]

រាជធានីភ្នំពេញ ថ្ងៃទី[redacted] ខែ[redacted] [redacted]

ចៅក្រម

[redacted]

[redacted]

# ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សំណុំរឿងអនុវត្តបង្គំលេខ [redacted]
ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted]
លេខ: [redacted]

# ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា

យើង [redacted] ចៅក្រមសាលាដំបូងខេត្ត [redacted] ។

-បានឃើញ មាត្រា ៤៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-បានឃើញ លទ្ធផលអង្កេតវាយតម្លៃអចលនទ្រព្យ ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted] របស់សាខាពន្ធដារខេត្ត [redacted] ។

-បានឃើញសំណុំរឿងអនុវត្តបង្គំលេខ [redacted] ចុះថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted] បានកំណត់នូវតម្លៃលក់អប្បបរមាលើអចលនវត្ថុ:

-ដីដែលមានក្បាលលេខ [redacted] មានទីតាំងស្ថិតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ។

-ដីដែលមានក្បាលលេខ [redacted] មានទីតាំងស្ថិតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ។

-ដីដែលមានក្បាលលេខ [redacted] មានទីតាំងស្ថិតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ។

-ដីដែលមានក្បាលលេខ [redacted] មានទីតាំងស្ថិតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ។

## កំណត់

| លេខកម្មវត្ថុ | តម្លៃអប្បបរមា | ប្រាក់ធានាលើសំណើទិញ |
|---|---|---|
| ០១ | [redacted]00.000 ([redacted]ម៉ឺន) ដុល្លារអាមេរិក | [redacted]0.000 ([redacted]ម៉ឺន) ដុល្លារអាមេរិក |
| សំគាល់ | | |

ថ្ងៃ [redacted] ខែ [redacted] ឆ្នាំ [redacted] សំរឹទ្ធិស័ក ព.ស [redacted]

[redacted], ថ្ងៃទី [redacted] ខែ [redacted] ឆ្នាំ [redacted]

ចៅក្រម

[redacted]

[redacted]